# សិទ្ធិទទួលបាន ការអនុគ្រោះ

## សំឡេងសហគមន៍ដីធ្លី ដែលជាប់ជំពាក់បំណុល



# សិទ្ធិទទួលបានការអន្តរាគមន៍ការអនុគ្រោះ

## សំឡេងសហគមន៍ដីធ្លីដែលជាប់ជំពាក់បំណុល

របាយការណ៍សង្ខេបចេញផ្សាយ ខែមិថុនា ឆ្នាំ២០២១

សម្រាប់ព័ត៌មានបន្ថែម៖

WWW.MFICAMBODIA.COM

ការចេញផ្សាយនេះ ត្រូវបានធ្វើឡើងក្រោមជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុរបស់សហភាពអឺរ៉ុប ។ មាតិកានៅក្នុងរបាយការណ៍នេះ គឺជាទំនួលខុសត្រូវទាំងស្រុងរបស់សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ ("អង្គការលីកាដូ") និងអង្គការសមធម៌កម្ពុជា (EC) និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបទេ ។

អង្គការ សមធម៌កម្ពុជា
equitable cambodia

អង្គការសមធម៌កម្ពុជាគឺជាអង្គការជាតិឈានមុខមួយក្នុងការស្វែងរកការគាំទ្រឲ្យមានការការពារសិទ្ធិលំនៅដ្ឋាន ដីធ្លី និងធនធានធម្មជាតិនៅកម្ពុជា។ អង្គការនេះត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១២ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ពីវិបត្តិនៃការរំលោភបំពានដីធ្លីដ៏រ៉ាំរ៉ៃ និងសិទ្ធិមនុស្ស។ តាមរយៈការស្រាវជ្រាវគោលនយោបាយ ការស្វែងរកការគាំទ្រនៅថ្នាក់ជាតិ និងអន្តរជាតិ ការបង្កើតក្រុមការងារចម្រុះ និងការរៀបចំចងក្រងសហគមន៍ អង្គការសមធម៌កម្ពុជាខិតខំប្រែក្លាយការអភិវឌ្ឍន៍ដីធ្លី និងសេដ្ឋកិច្ចរបស់ប្រទេស ឲ្យទៅជាគំរូមួយដែលគោរព ការពារ និងបំពេញសិទ្ធិប្រជាជនកម្ពុជាគ្រប់រូប។ អង្គការសមធម៌កម្ពុជានឹងសម្រេចគោលដៅរបស់ខ្លួន តាមរយៈកម្មវិធីថាមវន្តបី ដែលកម្មវិធីនីមួយៗខិតខំប្រឹងប្រែងដើរឆ្ពោះទៅរកចក្ខុវិស័យរបស់ប្រទេសកម្ពុជាមួយដែលប្រជាពលរដ្ឋទាំងអស់ អាចអាស្រ័យបានសិទ្ធិមនុស្សជាមូលដ្ឋាន ហើយធនធានធម្មជាតិរបស់ប្រទេសត្រូវបានគ្រប់គ្រងប្រកបដោយចីរភាពដើម្បីផលប្រយោជន៍រួម។

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា ។ ចាប់តាំងពីអង្គការលីកាដូត្រូវបានបង្កើត ឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិ នយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ ការគោរពសិទ្ធិទាំងនេះពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា ។ ដោយបានកសាងនូវ សមិទ្ធិផលល្អក្នុងអតីតកាល លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលស្ថានភាពសង្គមតាមរយៈកម្មវិធីឃ្លាំមើលនិងការពារសិទ្ធិមនុស្ស ពីការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងនៅតាមសាខាទាំង ១៣ ខេត្តផ្សេងទៀត ។

# មាតិកា


| | |
|---|---|
| សិទ្ធិទទួលបានការអនុគ្រោះ | ទំព័រ ១ |
| សេចក្តីផ្តើម | ទំព័រ ២ |
| ផែនទីសហគមន៍ | ទំព័រ ៤ |
| ខ្លឹមសារសង្ខេប | ទំព័រ ៥ |
| វិធីសាស្ត្រ | ទំព័រ ៨ |
| អាផ្ទាធរម្មូលដ្ឋាន | ទំព័រ ១១ |
| ព័ត៌មានអំពីសហគមន៍ | ទំព័រ ១៣ |





*ការស្រាវជ្រាវនេះ ពុំមានគោលបំណងតំណាងឱ្យតួលេខទាំងអស់នៅក្នុងប្រទេសកម្ពុជា ឬតំណាងឱ្យអតិថិជនទាំងអស់នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជានោះទេ។ របាយការណ៍សង្ខេបនេះ គ្រាន់តែបង្ហាញអំពីបញ្ហាមួយចំនួនដែលអ្នកស្រាវជ្រាវបានរកឃើញនៅតាមតំបន់គោលដៅ ដូចជា សហគមន៍រងគ្រោះដោយវិវាទដីធ្លី ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋកម្ពុជាជាច្រើន។*

# សិទ្ធិទទួលបានការអនុគ្រោះ

របាយការណ៍នេះ បង្ហាញពីរឿងរ៉ាវ និងសំឡេងរបស់សហគមន៍ចំនួន ១៤ នៅក្នុងប្រទេសកម្ពុជា អំពីការរំលោភបំពានលើសិទ្ធិរបស់ពួកគេ ពាក់ព័ន្ធនឹងបំណុលឥណទានខ្នាតតូចដ៏ច្រើនលើសលុប ។ របាយការណ៍នេះ មានគោលបំណង ជួយបន្លឺសំឡេងរបស់សហគមន៍ដែលជាប់ជំពាក់បំណុលទាំងនេះ ឱ្យបានឮទៅដល់អ្នកវិនិយោគទុន អ្នកធ្វើគោលនយោបាយ និងភាគីពាក់ព័ន្ធក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារ ដែលជាអ្នកទទួលខុសត្រូវ ដើម្បីធានាឲ្យមានការបញ្ឈប់នូវរាល់ការរំលោភបំពានសិទ្ធិមនុស្សទាំងនេះ ក៏ដូចជាធានាថាប្រាក់សំណង និងការអនុគ្រោះ ត្រូវបានផ្តល់ឱ្យអ្នកខ្ចីប្រាក់ដែលរងផលប៉ះពាល់ ។

អ្នកផ្តល់កម្ចីឥណទានខ្នាតតូច និងអ្នកវិនិយោគទុនអន្តរជាតិ ដែលរួមមានធនាគារអភិវឌ្ឍន៍ធំៗជាងគេរបស់សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប មានកាតព្វកិច្ចផ្នែកសីលធម៌ ដើម្បីដោះស្រាយការរំលោភសិទ្ធិមនុស្សទាំងនេះ ដោយផ្តល់ដំណោះស្រាយ និងសំណងឱ្យបានត្រឹមត្រូវ ។ ប្រជាពលរដ្ឋកម្ពុជាអ្នកខ្ចីប្រាក់ គួរមានសិទ្ធិទទួលបានការអនុគ្រោះ ពុំនោះទេបញ្ហាបំណុលនឹងធ្វើឱ្យពួកគេបន្តប្រឈមនឹង ភាពអត់ឃ្លាន ពលកម្មកុមារ ចំណាកស្រុក ការលក់ដីដោយបង្ខំ និងការរំលោភសិទ្ធិមនុស្សជាច្រើនទៀត ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ ។

សហគមន៍ចំនួន ១៤ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២ ដែលធ្វើការរួមគ្នាលើរបាយការណ៍នេះសូមស្នើសុំឱ្យ៖

១. ប្រគល់ប័ណ្ណ កម្មសិទ្ធិដីធ្លី ដែលបច្ចុប្បន្នត្រូវបានដាក់ជាទ្រព្យធានានៃកម្ចីឥណទានខ្នាតតូច ទៅឱ្យម្ចាស់ដើមស្របច្បាប់របស់អ្នកទាំងនោះវិញ ។

២. ស៊ើបអង្កេតឯករាជ្យ ទៅលើទំហំនៃការរំលោភសិទ្ធិមនុស្ស ដោយកម្ចីឥណទានខ្នាតតូច នៅកម្ពុជា ។

៣. អនុគ្រោះបំណុល និងផ្តល់សំណង សមរម្យ សម្រាប់អ្នកខ្ចីប្រាក់ ដែលរងគ្រោះនូវការរំលោភសិទ្ធិមនុស្សដែលកើតឡើងពីកម្ចីឥណទានខ្នាតតូចបែបកេងប្រវ័ញ្ច ។

៤. អនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព ដើម្បី៖

- បញ្ឈប់ការលក់ដី ឬផ្ទះដោយបង្ខំ ។
- ទប់ស្កាត់ការដាក់សម្ពាធខុសច្បាប់ពីសំណាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មន្ត្រីឥណទាន និងអាជ្ញាធរមូលដ្ឋាន ។
- បញ្ឈប់ការប្រើប្រាស់នូវកម្រៃសេវារដ្ឋបាល ដែលនាំឱ្យអត្រាការប្រាក់ជាក់ស្តែង ខ្ពស់ជាងអត្រាការប្រាក់គោល តាមផ្លូវច្បាប់ដែលកំណត់អតិបរមា ១៨% ។

៥. បញ្ចុះអត្រាការប្រាក់លើកម្ចីឥណទានខ្នាតតូច និងស្នើផ្តល់ ជម្រើសនៃការរៀបចំ ឥណទានឡើងវិញដែលអាចសម្របសម្រួលបាន ចំពោះអ្នកខ្ចីប្រាក់ដែលជួបទុក្ខលំបាក ក្នុងនោះមានការផ្អាកបង់សងប្រាក់ដើមនិងការប្រាក់បង្គរ ជាបណ្តោះអាសន្ន។

# សេចក្ដីផ្ដើម

របាយការណ៍នេះ បង្ហាញពីរឿងរ៉ាវរបស់សហគមន៍ចំនួន ១៤ នៅក្នុងប្រទេសកម្ពុជា ដែលភាគច្រើននៃពួកគេកំពុងជួបការលំបាកជាមួយនឹងបំណុលឥណទានខ្នាតតូចដ៏ច្រើនលើសលុប ។ សហគមន៍ទាំងអស់នេះ ក៏ជាប់ពាក់ព័ន្ធនឹងទំនាស់ដីធ្លី ដែលបានប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ អស់រយៈពេលជាច្រើនឆ្នាំ ។ អ្នកទាំងនោះមានប្រភពចំណូល បទពិសោធន៍លើបញ្ហាវិវាទដីធ្លី ជាតិសាសន៍ សាសនា និងភាសា ភូមិសាស្ត្រនិងបរិយាកាសផ្សេងៗគ្នា ប៉ុន្តែពួកគេទាំងអស់គ្នាកំពុងជួបបញ្ហាតែមួយ គឺការជាប់ជំពាក់បំណុលច្រើនលើសលុប និងរងគ្រោះ ដោយសារកម្ចីឥណទានខ្នាតតូច ។

ប្រជាពលរដ្ឋកម្ពុជា មានជាប់ជំពាក់កម្ចីឥណទានខ្នាតតូចជាង ១១,៨ ពាន់លានដុល្លារ ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) និងធនាគារ ។ ភាគច្រើននៃកម្ចីឥណទានខ្នាតតូចទាំងនេះ បានដាក់ប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លី ឬ លិខិតបញ្ជាក់ការកាន់កាប់ដីធ្លី ("ប័ណ្ណកម្មសិទ្ធិដីធ្លី") របស់អ្នកខ្ចីប្រាក់ ធ្វើជាទ្រព្យធានា ដែលនាំឱ្យមានហានិភ័យខ្ពស់ ដល់សុវត្ថិភាពកម្មសិទ្ធិដីធ្លីរបស់អ្នកខ្ចីប្រាក់ ។ កម្ចីឥណទានស្ទើរតែទាំងអស់ខាងលើ អនុវត្តអត្រាការប្រាក់ប្រចាំឆ្នាំចំនួន ១៨% ដែលជាចំនួនអតិបរមាកំណត់ដោយច្បាប់ ខណៈដែលអត្រាការប្រាក់ជាក់ស្តែងអាចនឹងខ្ពស់ខ្លាំងជាងនេះ ដោយសារការចំណាយលើសេវារដ្ឋបាលផ្សេងៗ ។

គិតជាមធ្យម កម្ចីឥណទានខ្នាតតូចនៅកម្ពុជាគឺមានប្រមាណជា ៤ ២៨០ ដុល្លារ នៅចុងឆ្នាំ ២០២០ ដែលជាចំនួនខ្ពស់ជាងគេនៅលើពិភពលោក ។ ប្រជាពលរដ្ឋចំនួន ៩៥% មានប្រាក់ចំណូលប្រចាំឆ្នាំតិចជាងចំនួនកម្ចីគិតជាមធ្យមនេះទៅទៀត ក្នុងឆ្នាំ២០២០[១] ។ ទំហំកម្ចីបានកើនឡើងលឿនជាងប្រាក់ចំណូលរបស់ពួកគាត់ នៅរយៈពេលជាងមួយទសវត្សរ៍កន្លះចុងក្រោយនេះ ។ កំណើនកម្ចីឥណទានខ្នាតតូចដោយខ្វះទំនួលខុសត្រូវនេះ បានធ្វើឱ្យប្រជាពលរដ្ឋ ជាប់ផុងយ៉ាងជ្រៅជាមួយបញ្ហាបំណុល និងភាពងាយរងគ្រោះពីការរំលោភសិទ្ធិមនុស្ស ដោយសារអ្នកខ្ចីប្រាក់ ត្រូវបានជំរុញឱ្យធ្វើសកម្មភាពមិនសមស្របមួយចំនួន ដើម្បីសងកម្ចីឥណទានវិញ ។ សកម្មភាពទាំងនេះមានដូចជា ការលក់ដីធ្លីដោយបង្ខំ ចំណាកស្រុកខុសច្បាប់ ការកាត់បន្ថយអាហារបរិភោគ ពលកម្មកុមារ និងបញ្ហាជាច្រើនទៀត ។ សកម្មភាពទាំងនេះ គឺជាលទ្ធផលផ្ទាល់នៃកំណើនយ៉ាងឆាប់រហ័សនៃវិស័យមីក្រូហិរញ្ញវត្ថុ ដែលគាំទ្រដោយការវិនិយោគរបស់បុគ្គលឯកជន និងសាធារណៈរួមមាន សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) របស់ធនាគារពិភពលោក និងភ្នាក់ងារអភិវឌ្ឍន៍របស់រដ្ឋ ដែលជាសមាជិកសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ជាដើម ។

ការកើនឡើងដោយមិនច្បាស់លាស់នេះ បានកើតឡើងនៅក្នុងវិស័យមួយដែលខ្វះកិច្ចការពារអតិថិជនឱ្យមានប្រសិទ្ធភាព ។ ជាទូទៅ ប្រទេសកម្ពុជាមានចំណាត់ថ្នាក់នៅក្បែរបាតតារាងចំពោះវិស័យមីក្រូហិរញ្ញវត្ថុទាំងអស់ បើគិតទៅលើលក្ខខណ្ឌក្នុងការការពារអតិថិជន ក្រៅពីជាប្រទេសដែលមានអត្រាកម្ចីឥណទានធំជាងគេសម្រាប់មនុស្សម្នាក់គិតជាមធ្យម[២] ។ របាយការណ៍មួយចំនួនរបស់ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិបានលើកឡើងជាបន្តបន្ទាប់ពីកង្វល់ជុំវិញបញ្ហាជាប់ជំពាក់បំណុលច្រើនលើសលុប និងចំនួនអ្នកខ្ចីប្រាក់ ហើយចុងក្រោយនេះពួកគេក៏បានបង្ហាញថា អ្នកខ្ចីប្រាក់ជាច្រើនរាយការណ៍ថា ការអនុវត្តប្រមូលប្រាក់ជាទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគឺ ការរឹបអូសទ្រព្យធានាដែលភាគច្រើនគឺជាដីធ្លី[៣] ។ របាយការណ៍ទាំងនេះជារឿយៗតែងតែត្រូវបានមើលរំលង នៅពេលដែលមានការធ្វើសេចក្តីសម្រេចអំពីការវិនិយោគថ្មីៗ ។

បន្ទាប់ពីបានស្តាប់បទពិសោធន៍របស់សហគមន៍ទាំងនេះ វាហាក់ដូចជាមិនគួរឱ្យជឿនោះទេថា វិស័យនេះដំណើរការទៅតាមអ្វីដែលវិស័យនេះគួរធ្វើ ។ អ្នកខ្ចីដែលងាយរងគ្រោះជាងគេជាច្រើនកំពុងបាត់បង់ដីធ្លីរបស់ពួកគេ ។ កុមារខ្លះត្រូវបានបញ្ឈប់ពីការសិក្សា ដើម្បីជួយធ្វើការរកប្រាក់សងបំណុល ។ សមាជិកគ្រួសារដែលពេញវ័យ ត្រូវចាកចេញពីភូមិ ដើម្បីធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសដ៏ទៃ ។ ការកាត់បន្ថយអាហារបរិភោគ បានក្លាយជារឿងទូទៅ ។ ទាល់តែមានលក្ខខណ្ឌទាំងអស់នេះ ទើបអ្នកខ្ចីដែលមានភាពភ័យខ្លាច និងភាពទីទាល់ក្រ អាចសងកម្ចីឥណទាន ដែលមិនតម្រូវឱ្យមានការស្នើសុំ ឬដាក់បញ្ចាំប័ណ្ណកម្មសិទ្ធិដីធ្លីនៅពេលដំបូង ។ ដូចគ្នាផងដែរ "មីក្រូហិរញ្ញវត្ថុ" នៅតែត្រូវបានមើលឃើញនៅក្នុងប្រទេសលោក

[១] Cambodia 2019/2020 CSES, pg 111
[២] EIU Microscope
[៣] 2017 OID, 2020 MIMOSA, 2016 MIMOSA

ខាងលិចថាជាវិស័យអភិវឌ្ឍន៍ប្រកបដោយជោគជ័យមួយនៅកម្ពុជា ។ ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើន រីករាយនឹងកំណត់ត្រាប្រាក់ចំណេញ អំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩ ខណៈដែលអ្នកខ្ចីប្រាក់រាប់សែននាក់ បានបាត់បង់ប្រាក់ចំណូល ហើយប្រជាពលរដ្ឋនៅក្នុងសហគមន៍ បានកំពុងជួបការលំបាក ក្នុងការបន្តជីវិតរស់នៅ ។ ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ បានស្នើគម្រោងថវិកាថ្មីរាប់រយលានដុល្លារ សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា អំឡុងពេលមានវិបត្តិជំងឺកូវីដ១៩ ដែលជាការគំរាមកំហែងក្នុងការជំរុញអ្នកខ្ចីប្រាក់ឱ្យជាប់ជំពាក់បំណុលកាន់តែច្រើនឡើងថែមទៀត បើមិនមានការគាំពារច្បាស់លាស់សម្រាប់កូនបំណុល។

វិស័យមីក្រូហិរញ្ញវត្ថុ ត្រូវការធ្វើកំណែទម្រង់ជាចាំបាច់ ។ ប័ណ្ណកម្មសិទ្ធិដីធ្លី គួរត្រូវបានប្រគល់ឱ្យអ្នកខ្ចីប្រាក់វិញ ។ ប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ក្នុងការសងកម្ចីឥណទានរបស់ពួកគេ ត្រូវការជម្រើសរៀបចំឥណទានឡើងវិញបែបទូលំទូលាយ និងជាលក្ខណៈប្រព័ន្ធ មិនមែនជាគម្រោងខ្វះគោលការណ៍ដូចការអនុវត្តកន្លងមកទេ ។ ប្រជាពលរដ្ឋដែលគ្មានលទ្ធភាពសងកម្ចីឥណទានរបស់ពួកគេ ត្រូវការការអនុគ្រោះបំណុលជាបន្ទាន់ ។ ការស៊ើបអង្កេតទៅលើការរំលោភសិទ្ធិមនុស្សគួរ ត្រូវបានធ្វើឡើងដោយឯករាជ្យពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុខ្លួនឯងផ្ទាល់ ។ ការស៊ើបអង្កេតទាំងនេះ ត្រូវធ្វើឡើងដោយមានយន្តការគណនេយ្យភាព ដែលមានប្រសិទ្ធភាពទាំងក្នុងលក្ខខណ្ឌនៃការផ្តល់សំណងដល់អ្នកខ្ចីប្រាក់ ដែលទទួលរងនូវការប្រព្រឹត្តិខុស និងការឱ្យជនល្មើសទទួលខុសត្រូវលើការរំលោភបំពានដែលពួកគេបានប្រព្រឹត្ត ។

ភាពខុសគ្នារវាង អ្នកវិនិយោគវិស័យមីក្រូហិរញ្ញវត្ថុ និងស្ថានភាពជាក់ស្តែងគឺមិនមានភាពច្បាស់លាស់ និងកំពុងធ្វើឱ្យមានគ្រោះថ្នាក់យ៉ាងពិតប្រាកដ ដូចដែលបានលើកមកបង្ហាញម្តងហើយម្តងទៀតនៅក្នុងការសិក្សាស្រាវជ្រាវនេះ ។ កិច្ចសម្ភាសន៍មួយនៅខេត្តរតនគិរីដែលស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា ស្ត្រីចំណាស់ជាជនជាតិដើមភាគតិចម្នាក់ បានយំ នៅពេលដែលអ្នកស្រីរៀបរាប់ពីរបៀបដែលមន្ត្រីឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំមួយ បានដាក់សម្ពាធឱ្យអ្នកស្រីលក់ដី ដើម្បីសងបំណុល ។ អ្នកស្រីបានរំលឹកទាំងទឹកភ្នែកអំពី ពេលដែលមន្ត្រីឥណទានគំរាមទាក់ទងទៅនគរបាល និងបញ្ជូនអ្នកស្រីទៅពន្ធនាគារ ក៏ដូចជាពេលដែលអ្នកស្រីមានអារម្មណ៍ភ័យខ្លាច បើមិនសងប្រាក់ទៅមន្ត្រីឥណទានភ្លាមៗវិញទេ ។ ភ្លាមៗបន្ទាប់ពីកិច្ចសម្ភាសន៍នោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដដែលនោះ ត្រូវបានប្រកាសថា គឺជាស្ថាប័នដែលត្រូវបានស្នើឱ្យទទួលបានកម្ចីរាប់លានដុល្លារពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិរបស់ធនាគារពិភពលោក ។

ស្ថានភាពនេះ មិនអាចនៅបន្តបានទេ ។ ក្រុមអាទិភាពក្នុងការអភិវឌ្ឍជាច្រើននៅកម្ពុជា កំពុងត្រូវបានរងគ្រោះដោយបំណុលឥណទានខ្នាតតូចដ៏ច្រើនលើសលុប រួមមានការបោះបង់ការសិក្សារបស់កុមារ កង្វះអាហាររូបត្ថម្ភ ចំណាកស្រុកខុសច្បាប់ អសុវត្ថិភាពកម្មសិទ្ធិដីធ្លី និងបញ្ហាជាច្រើនទៀត ។ យើងខ្ញុំ សូមស្នើសុំដល់គ្រប់ភាគីពាក់ព័ន្ធនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាដូចជា វិនិយោគិនម្ចាស់ភាគហ៊ុន ភ្នាក់ងារអភិវឌ្ឍន៍ ថ្នាក់ដឹកនាំគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលជាដៃគូរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សូមឱ្យទទួលស្គាល់នូវបញ្ហាទាំងនេះ និងធ្វើការជាមួយគ្នា ដើម្បីអនុវត្តកំណែទម្រង់ និងកិច្ចការពារអតិថិជនពិតប្រាកដ ។ កំណែទម្រង់នេះ គួររួមបញ្ចូលនូវការប្រគល់ប័ណ្ណកម្មសិទ្ធិដីធ្លីឱ្យម្ចាស់ទ្រព្យស្របច្បាប់វិញ ការអនុគ្រោះបំណុលសម្រាប់ប្រជាពលរដ្ឋដែលគ្មានលទ្ធភាពសង ដោយមិនឱ្យអ្នកទាំងនោះរងគ្រោះពីការរំលោភសិទ្ធិមនុស្ស ការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ការផ្តល់សំណងឱ្យអ្នកខ្ចីប្រាក់ដែលទទួលរងនូវការអនុវត្តបែបកេងចំណេញឬប្រព្រឹត្តិខុសច្បាប់ និងការឱ្យជនល្មើសទទួលខុសត្រូវលើការរំលោភបំពានដែលពួកគេបានប្រព្រឹត្ត ។

# ផែនទីសហគមន៍



ដោតជ័យ
កាំ និងក្រេះ
តាឡាវ និងអ៊ីន
បឹងប្រាំ
អូរវល្លិប្រេង
សហគមន៍ដីធ្លីខេត្តប៉ៃលិន
ដកពរ
ក្រាំងត្បែង
ភូមិ ១៧
មានជ័យស្ត្រីអភិវឌ្ឍន៍
ជីខលើ
ជីខក្រោម
តានូន

# ខ្លឹមសារសង្ខេប

អ្នកស្រាវជ្រាវរបស់អង្គការមិនមែនរដ្ឋាភិបាល និងសមាជិកសហគមន៍ បានសម្របសម្រួល កិច្ចពិភាក្សាជាក្រុមចំនួន ១៤ លើក ជាមួយសហគមន៍ចំនួន ១៤ ផ្សេងៗគ្នា ដើម្បីបង្ហាញពីផលវិបាកនៃភាពជំពាក់បំណុលច្រើនលើសលុប ក្នុងចំណោមប្រជាពលរដ្ឋ អ្នកខ្ចីកម្ចីឥណទានខ្នាតតូច ។ សហគមន៍ទាំងនេះ ត្រូវបានបង្កើតឡើងពីដំបូង ដើម្បីឆ្លើយតបទៅនឹងបញ្ហាវិវាទដីធ្លី ។ ជាសរុប សមាជិកសហគមន៍ចំនួន ១២៤នាក់ បានចូលរួមក្នុងកិច្ចពិភាក្សាជាក្រុមទាំងនេះ ហើយពីរភាគបីនៃពួកគេគឺជាស្ត្រី ។ លើសពីនេះ មនុស្សចន្លោះពី ១ ទៅ ៤ នាក់ មកពីសហគមន៍នីមួយៗ ត្រូវបានសម្ភាសជាលក្ខណៈបុគ្គល ។ ជាសរុប មនុស្សចំនួន ៤៧នាក់ ត្រូវបានសម្ភាសជាលក្ខណៈបុគ្គល ក្នុងនោះមាន ៨០% ជាស្ត្រី ។ កិច្ចពិភាក្សាទាំងនេះ ចំណាយពេលសរុប ជាង ១០០ ម៉ោង ដែលជាផ្នែកមួយនៃគម្រោងនេះ ។

កិច្ចពិភាក្សាទាំងនេះ ត្រូវបានរៀបចំជាលក្ខណៈបើកចំហ ដើម្បីសម្របសម្រួលការសន្ទនាអំពី បទពិសោធន៍ជីវិត របស់សមាជិកសហគមន៍ ដែលបានខ្ចីប្រាក់ និងបានបង់សងកម្ចីឥណទានខ្នាតតូចជាមួយធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា ។

កិច្ចពិភាក្សាទាំងនេះ បានលាតត្រដាងបទពិសោធន៍ និងផលវិបាកជាច្រើន នៃបំណុលឥណទានខ្នាតតូច ។ ផលវិបាកទាំងនេះ ត្រូវបានបែងចែកជាបីប្រភេទ ផ្អែកលើចំនួនសហគមន៍ដែលជួបប្រទះ ៖

**"ច្រើន"៖** ត្រូវបានកំណត់និយមន័យថា ជាការកើតឡើងនៅក្នុងសហគមន៍យ៉ាងតិច ១០ ក្នុងចំណោមសហគមន៍ទាំង ១៤ ។

**"ទូទៅ"៖** ត្រូវបានកំណត់និយមន័យថា ជាការលើកឡើង នៅក្នុងសហគមន៍ចន្លោះពី ៥ ទៅ ១០ ។

**"តិច"៖** ត្រូវបានកំណត់និយមន័យថា ជាការលើកឡើង នៅក្នុងសហគមន៍ចន្លោះពី ២ ទៅ ៤ ។

បទពិសោធន៍ដែលត្រូវបានរាយកាណ៍នៅក្នុងសហគមន៍ ចំនួនតែមួយប៉ុណ្ណោះដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងខ្លឹមសារសង្ខេបនេះ ប៉ុន្តែមានរាប់បញ្ចូលនៅក្នុងកម្រងព័ត៌មានសហគមន៍នីមួយៗ ។

ការកើតឡើងនៃបញ្ហាមួយនៅក្នុងសហគមន៍មួយ មិនឆ្លុះបញ្ចាំងពីចំនួនករណីនៅក្នុងសហគមន៍នោះទេ ។ ជាឧទាហរណ៍ សហគមន៍ខ្លះបានរាយការណ៍ថា សមាជិកសហគមន៍មួយចំនួនតូច បានលក់ដីធ្លី ដើម្បីសងកម្ចីឥណទានខ្នាតតូច ប៉ុន្តែសហគមន៍ដីធ្លីខេត្តប៉ៃលិន ត្រូវបានប៉ាន់ប្រមាណថា មានសមាជិកសហគមន៍រហូតដល់ ៦០% បានលក់ដីធ្លីដើម្បីសងបំណុល ។ ការអានកម្រងព័ត៌មានសហគមន៍នីមួយៗដោយលម្អិត នឹងផ្តល់ការយល់ដឹងពេញលេញបន្ថែមទៀតនៃរបៀបជាច្រើន ដែលបំណុលឥណទានខ្នាតតូច ធ្វើឱ្យប៉ះពាល់ដល់សហគមន៍ជាច្រើន ដែលបានពិពណ៌នានៅក្នុងរបាយការណ៍នេះ ។

## មូលហេតុនៃការខ្ចីប្រាក់

| | |
|---|---|
| ច្រើន | សងបំណុលផ្សេងៗ (១៣ សហគមន៍) • ព្យាបាលជំងឺ (១៣) • សាងសង់ផ្ទះ (១១) • ធ្វើកសិកម្ម (១១) |
| ទូទៅ | ចំណាយការសិក្សាកូន (៩) • ទិញម៉ូតូ (៨) • ទិញដី (៨) • ប្រកបរបរ (៧) • ចំណាកស្រុក (៥) • ឈូសឆាយដី (៥) |
| តិច | មង្គលការកូន (៤) • ជួសជុលផ្ទះ (៣) |

**មូលហេតុនៃការខ្ចីប្រាក់៖** មានហេតុផលជាច្រើនដែលនាំឱ្យសមាជិកសហគមន៍ សម្រេចចិត្តខ្ចីកម្ចីឥណទានខ្នាតតូច ។ កត្តាដែលសហគមន៍ជាច្រើនបានរាយការណ៍ថា សមាជិកសហគមន៍បានខ្ចីប្រាក់ ដើម្បីសងបំណុលផ្សេងទៀត (១៣ សហគមន៍) បង្ហាញថា កម្រិតបំណុលនៅក្នុងប្រទេសកម្ពុជា បានឈានដល់កម្រិតគ្មាននិរន្តរភាព ហើយការបន្តកើនឡើងនៃទំហំកម្ចីឥណទាននៅក្នុងប្រទេស អាចជាផលប៉ះពាល់យ៉ាងតិចណាស់មួយផ្នែកនៃតម្រូវការក្នុងការយកកម្ចីឥណទានថ្មី ដើម្បីយកទៅសងកម្ចីឥណទានចាស់ ។ កត្តាដែលការខ្ចីប្រាក់ត្រូវបានធ្វើឡើងជាញឹកញាប់ ដើម្បីទទួលបានសេវាថែទាំសុខភាព (១៣) និងការសិក្សារបស់កុមារ (៩) ឆ្លុះបញ្ចាំងថា ប្រជាពលរដ្ឋកម្ពុជាជាច្រើន មិនអាចទទួលបានសេវាសាធារណៈគ្រប់គ្រាន់ដូចជា ការថែទាំសុខភាព និងការអប់រំ ដែលគួរតែត្រូវបានផ្តល់ដោយរាជរដ្ឋាភិបាល ដោយឥតគិតថ្លៃ និងមិនគួរត្រូវជាប់ជំពាក់បំណុលជាមួយអ្នកផ្តល់កម្ចីឥណទានខ្នាតតូចដូចជា ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឡើយ ។

## ឥរិយាបថគ្មានក្រមសីលធម៌របស់មន្រ្តីឥណទាន

| | |
|---|---|
| ច្រើន | ការប្រមូលឥណទានដោយរំលោភបំពាន (១២) |
| ទូទៅ | ការដាក់សម្ពាធឱ្យលក់ដី (៩) • គំរាមកំហែង (៩) • ការផ្តល់កម្ចីឥណទានបែបកេងចំណេញ (៨) • ការជំរុញឱ្យខ្ចីកម្ចីឯកជន (៥) • ការរក្សាប័ណ្ណកម្មសិទ្ធិដីធ្លីក្រោយពីបង់សងផ្តាច់រួច (៥) |
| តិច | ការក្លែងបន្លំ (៤) |

**ឥរិយាបថគ្មានក្រមសីលធម៌របស់មន្រ្តីឥណទាន៖** កាអនុវត្តប្រមូលឥណទានដោយរំលោភបំពាន (១២) ត្រូវបានប្រើប្រាស់ ដើម្បីប្រព្រឹត្តឥរិយាបថជាច្រើនដូចជា ការចុះសួរនាំញឹកញាប់ ឬចំណាយពេលយូរនៅផ្ទះរបស់អ្នកខ្ចីប្រាក់ ការធ្វើទុក្ខបុកម្នេញឬស្រែកគំហកដដែលៗ ការចុះសួរនាំដោយមន្រ្តីឥណទានជាច្រើនដើម្បីដាក់សម្ពាធ និងឥរិយាបថផ្សេងទៀត ។ ការដាក់សម្ពាធឱ្យលក់ដី (៩) គឺជាហេតុការណ៍ដែលមន្រ្តីឥណទាន បានព្យាយាមបង្ខំឱ្យអ្នកខ្ចីប្រាក់លក់ដីធ្លី ដោយមិនបានប្រើប្រាស់យន្តការដកហូតតាមផ្លូវច្បាប់ដែលមានស្រាប់ ។ ការគំរាមកំហែង (៩) គឺមានខុសៗគ្នា ហើយភាគច្រើនគឺជាការគំរាមកំហែងដើម្បីលក់ដីធ្លីរបស់អ្នកខ្ចីប្រាក់ដោយការដេញថ្លៃ ឬដោយគ្មានការអនុញ្ញាត ឬដើម្បីនាំអ្នកខ្ចីប្រាក់ទៅជួបអាជ្ញាធរ ឬនគរបាលមូលដ្ឋាន ដែលនេះមិនមែនជាដំណើរការនីតិវិធីដកហូតស្ថិតក្រោមច្បាប់កម្ពុជានោះទេ ។

## ផលវិបាកនៃបំណុលឥណទានខ្នាតតូច

| | |
|---|---|
| ច្រើន | កាត់បន្ថយការបរិភោគអាហារ (១៤) • ខ្ចីប្រាក់ពីអ្នកចងការឯកជន (១៤) • លក់ទ្រព្យសម្បត្តិផ្សេងៗ (១៣) • លក់ដី (១២) • ពលកម្មកុមារ (១១) • ចំណាកស្រុក (១១) • កុមារឈប់ពីការសិក្សា (១០) • ខ្ចីឥណ ទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (១០) |
| ទូទៅ | ភាពតានតឹងក្នុងគ្រួសារ (៩) • ធ្វើការបន្ថែម (៥) • បញ្ហាជំណេក (៥) |
| តិច | |

**ផលវិបាកនៃបំណុលឥណទានខ្នាតតូច៖** សហគមន៍ទាំងអស់បានរាយការណ៍ថា ពួកគេបរិភោគអាហារតិចតួច (១៤) និងខ្ចីប្រាក់ពីអ្នកចងការឯកជន (១៤) ដើម្បីសងបំណុលឥណទានខ្នាតតូច ។ នេះគឺជារឿងគួរឱ្យព្រួយបារម្ភខ្លាំងណាស់ និងជាការដើរថយពីបេសកកម្មក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់អាជីវកម្មប្រកបដោយចីរភាព ដែលអះអាងដោយអ្នកផ្តល់កម្ចីឥណទានខ្នាតតូច និងធនាគារអភិវឌ្ឍន៍អន្តរជាតិ ។ ប្រភពរីកសាយនៃការលក់ដី (១២) ដើម្បីសងកម្ចីឥណទានខ្នាតតូច គឺគួរឱ្យព្រួយបារម្ភខ្លាំងណាស់ ។ គ្មាននរណាម្នាក់គួរបាត់បង់ដីធ្លីរបស់ខ្លួន ដើម្បីសងកម្ចីឥណទានខ្នាតតូចនោះទេ ។ ការប្រើប្រាស់ពលកម្មកុមារ (១១) ដើម្បីសងកម្ចីឥណទានខ្នាតតូចក៏កើតមានឡើងច្រើនដែរ ក៏ដូចជាកុមារដែលបោះបង់ការសិក្សា (១០) ដោយសារសម្ពាធក្នុងការសងកម្ចីឥណទានខ្នាតតូច ដែលចោទជាសំណួរសំខាន់ និងបន្ទាន់អំពី ផលប៉ះពាល់នៃវិបត្តិភាពជំពាក់បំណុលច្រើនលើសលុបនេះ ទៅលើកុមារ ។

## ការប៉ះពាល់ផ្លូវចិត្ត

| | |
|---|---|
| ច្រើន | ព្រួយបារម្ភ (១២) • ភ័យខ្លាច (១២) |
| ទូទៅ | សម្ពាធ (៦) • អៀនខ្មាស (៦) |
| តិច | កើតទុក្ខ (៤) • សោកស្តាយ (៣) • ខកចិត្ត (៣) |

**ការប៉ះពាល់ផ្លូវចិត្ត៖** ការភ័យខ្លាច (១២) គឺជាអារម្មណ៍ដែលត្រូវបានរាយការណ៍ទូទៅបំផុតមួយចំពោះបំណុលឥណទានខ្នាតតូច ។ មានហេតុផលផ្សេងៗគ្នាដែលនាំឱ្យសមាជិកសហគមន៍ភ័យខ្លាច ប៉ុន្តែជារឿយៗវាគឺពាក់ព័ន្ធជុំវិញការភ័យខ្លាចចំពោះការបាត់បង់ដីធ្លី ទោះបីជាមន្ត្រីឥណទានបានគំរាមកំហែងដើម្បីរឹបអូស ឬលក់ដី ឬមិនបានគំរាមកំហែងក៏ដោយ ។ ការណ៍នេះឆ្លុះបញ្ចាំងពីការយល់ឃើញជាទូទៅមួយក្នុងចំណោមអ្នកខ្ចីប្រាក់ថា ការខកខានមិនបានបង់សងកម្ចីឥណទានខ្នាតតូចនឹងត្រូវប្រឈមនឹងការបាត់បង់ដីធ្លី ជាការយល់ឃើញមួយដែលគួរឱ្យជឿបន្ថែមទៀត ដោយសារប័ណ្ណកម្មសិទ្ធិដីធ្លីរបស់ពួកគាត់ ត្រូវបានដាក់ជាទ្រព្យធានា ។ ការព្រួយបារម្ភ (១២) និងសម្ពាធ (៦) ជាញឹកញាប់ ត្រូវបានធ្វើឱ្យស្ថានភាពកាន់តែធ្ងន់ធ្ងរខ្លាំងថែមទៀត ដោយមន្ត្រីឥណទាន ដែលបានគំរាមកំហែង ឬចូលរួមក្នុងសកម្មភាពរំលោភបំពាន ដែលបង្កើតភាពតានតឹងផ្លូវចិត្តដល់អ្នកខ្ចីប្រាក់ ។ ភាពអៀនខ្មាស (៦) អំពីការគ្មានលទ្ធភាពបង់សងកម្ចីឥណទាន ក៏ជារឿងទូទៅមួយក្នុងចំណោមសហគមន៍ទាំងនេះ ។

## ផលប៉ះពាល់នៃជំងឺកូវីដ១៩

| | |
|---|---|
| ច្រើន | ប្រាក់ចំណូលធ្លាក់ចុះ (១៤) • មន្ត្រីឥណទានមិនបានស្នើផ្តល់រៀបចំឥណទានឡើងវិញ (១១) |
| ទូទៅ | មន្ត្រីឥណទានបដិសេធរៀបចំឥណទានឡើងវិញ (៧) |
| តិច | មន្ត្រីឥណទាននិយាយថាការរៀបចំឥណទានឡើងវិញគឺគ្មានប្រយោជន៍ (៣) |

**ផលប៉ះពាល់នៃជំងឺកូវីដ១៩៖** សហគមន៍ទាំងអស់បានរាយការណ៍ពី ការធ្លាក់ចុះនៃប្រាក់ចំណូល (១៤) ។ ក្នុងករណីមួយចំនួនប្រាក់ចំណូលមានការធ្លាក់ចុះរហូតដល់ ៩០% ។ បញ្ហាទូទៅមួយគឺ មន្ត្រីឥណទានមិនបានស្នើផ្តល់ជម្រើសក្នុងការរៀបចំឥណទានឡើងវិញទេ (១១) ហើយការណែនាំពីសំណាក់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងជម្រើសរៀបចំឥណទានឡើងវិញ បានផ្តល់អំណាចនៃការសម្រេចចិត្តដ៏ធំធេងក្នុងដៃរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ និងមន្ត្រីឥណទាន ។ អ្នកខ្ចីប្រាក់ក្នុងសហគមន៍មួយចំនួន មិនបានដឹងអំពីជម្រើសក្នុងការរៀបចំឥណទានឡើងវិញ ខណៈដែលករណីផ្សេងទៀត ពួកគេបានដឹងតាមរយៈការមើលទូរទស្សន៍ ឬបណ្តាញសង្គម ប៉ុន្តែមិនបានដឹងពីមន្ត្រីឥណទាននោះទេ ។

ការបដិសេធសំណើរៀបចំឥណទានឡើងវិញពីសំណាក់មន្ត្រីឥណទាន ក៏កើតមានឡើងញឹកញាប់ផងដែរ ។ មន្ត្រីឥណទានក្នុងករណីមួយចំនួនបាននិយាយថា ការរៀបចំឥណទានឡើងវិញគឺគ្មានប្រយោជន៍ទេ (៣) ។ អ្នកខ្ចីប្រាក់មួយចំនួនដែលបានទទួលការរៀបចំឥណទានឡើងវិញក៏បានបញ្ចេញទស្សនៈដូចគ្នាដោយនិយាយថា ជម្រើសរៀបចំឥណទានឡើងវិញ ជារឿយៗបានបង្កើនចំនួនបំណុលសរុបរបស់ពួកគេក្នុងរយៈពេលវែង ។ នេះក៏ព្រោះតែការប្រាក់បង្គរ មិនធ្លាប់ត្រូវបានព្យួរទេ នៅពេលដែលកម្ចីឥណទានត្រូវបានរៀបចំឡើងវិញ ដូច្នេះការថយចុះនៃការបង់ប្រចាំខែ នាំឱ្យកើនឡើងបន្ទុកបំណុលសរុប ។

# វិធីសាស្ត្រ

អង្គការសមធម៌កម្ពុជា (EC) និងសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ ("អង្គការលីកាដូ") គឺជាអង្គការសិទ្ធិមនុស្សក្នុងស្រុក ដែលបានបង្កើតឡើងស្ថិតលើគោលការណ៍ នៃការសិក្សាស្រាវជ្រាវដោយផ្អែកលើសហគមន៍ និងការតស៊ូមតិដែលនាំផ្លូវដោយប្រជាពលរដ្ឋនៅមូលដ្ឋាន ។ គោលដៅចម្បងនៃសកម្មភាពរបស់ពួកយើងគឺ ដើម្បីបន្លឺសំឡេងរបស់សហគមន៍ និងបង្ហាញពីការរំលោភសិទ្ធិមនុស្ស ដែលសហគមន៍ទាំងនេះបានជួបប្រឈម ទាំងពីសំណាក់អាជ្ញាធររដ្ឋ និងអ្នកដែលមិនមែនជាអាជ្ញាធររដ្ឋ ។

របាយការណ៍នេះ ត្រូវបានបង្កើតឡើង និងអនុវត្ត ដោយប្រើប្រាស់គោលការណ៍ ការសិក្សាស្រាវជ្រាវដោយផ្អែកលើការចូលរួមរបស់សហគមន៍ និងការព្យាយាមវែកញែកភាពខុសប្លែកគ្នារវាង "អ្នកសិក្សាស្រាវជ្រាវ" មកពីអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ដែលជា "អ្នកឆ្លើយតបសំណួរ" ។ លើសពីនេះ ទាំងការធ្វើការប្រកបដោយសមធម៌ ក្នុងនាមជាអ្នកសហការស្រាវជ្រាវ និងជាអ្នកសហការបង្កើតនូវ "ចំណេះដឹង" ពួកយើងតែងតែផ្តល់តម្លៃ និងលើកកម្ពស់បទពិសោធន៍រស់នៅរបស់សមាជិកសហគមន៍ ។

អ្នកសិក្សាស្រាវជ្រាវចំនួន ៤នាក់ មកពីអង្គការសមធម៌កម្ពុជា និងអង្គការលីកាដូ បានរៀបចំកិច្ចពិភាក្សាជាក្រុមចំនួន ១៤លើក ជាមួយប្រជាពលរដ្ឋសរុបចំនួន ១២៤នាក់ មកពីសហគមន៍ផ្សេងៗចំនួន ១៤ ដោយមានអ្នកចូលរួមប្រមាណជា ១០នាក់ ក្នុងកិច្ចពិភាក្សានីមួយៗ ។ សហគមន៍ទាំង ១៤ ដែលត្រូវបានជ្រើសរើស ធ្លាប់បានធ្វើការទាំងជាមួយអង្គការសមធម៌កម្ពុជា និងអង្គការលីកាដូ ពាក់ព័ន្ធនឹងបញ្ហាវិវាទដីធ្លីរបស់ពួកគេ ។ ការពិភាក្សាជាក្រុម និងបទសម្ភាសន៍ដំបូង ត្រូវបានធ្វើឡើងនៅចន្លោះខែមិថុនា និងខែកញ្ញា ឆ្នាំ២០២០ ព្រមទាំងមានកិច្ចប្រជុំបញ្ជាក់ និងប្រជុំឯកភាពនៅក្នុងឆ្នាំ២០២១ ។ អ្នកចូលរួមត្រូវបានជ្រើសរើសនៅក្នុងការប្រឹក្សាយោបល់ជាមួយតំណាងសហគមន៍[៤] ដោយឈរលើមូលដ្ឋានថា ពួកគេយល់ដឹងពីស្ថានភាពរបស់សហគមន៍ពាក់ព័ន្ធនឹងបញ្ហាបំណុល។ ការណ៍នេះ បានផ្តល់ឱ្យសមាជិកសហគមន៍នូវទំនុកចិត្ត និងផាសុកភាព ដែលមានស្រាប់នៅពេលពិភាក្សាគ្នាអំពីបញ្ហាបំណុល ជាបញ្ហាមួយដែលជារឿយៗត្រូវបានចាត់ទុកថាជា រឿងផ្ទាល់ខ្លួន ឯកជន និងអៀនខ្មាស នៅក្នុងប្រទេសកម្ពុជា ។

អ្នកសិក្សាស្រាវជ្រាវរបស់អង្គការមិនមែនរដ្ឋាភិបាល បានរៀបចំឱ្យមានកម្រងសំណួរមួយ ក្នុងគោលបំណងសម្របសម្រួលបើកកិច្ចពិភាក្សាអំពីប្រធានបទពីរធំៗដូចជា បញ្ហាវិវាទដីធ្លីរបស់សហគមន៍ដែលនៅបន្តកើតមាន និងស្ថានភាពបំណុលរបស់សមាជិកសហគមន៍ ដែលភាគច្រើនជាបំណុលមីក្រូហិរញ្ញវត្ថុ ។ សមាជិកសហគមន៍ត្រូវបានលើកទឹកចិត្តឱ្យចូលរួមនៅក្នុងកិច្ចពិភាក្សាដោយសេរី និងគ្មានការភ័យខ្លាចពីការវិនិច្ឆ័យណាមួយឡើយ ។ អ្នកសិក្សាស្រាវជ្រាវនៃអង្គការមិនមែនរដ្ឋាភិបាល តែងលើកទឹកចិត្តឱ្យមានកិច្ចពិភាក្សាជាក្រុម បន្ទាប់ពីអ្នកចូលរួមម្នាក់ៗលើកឡើងពីគំនិតយោបល់ ឬបទពិសោធន៍របស់ពួកគេ ពីបញ្ហាសំខាន់ៗ ឬការរំលោភសិទ្ធិមនុស្ស ដើម្បីស្វែងរកមតិជាឯកច្ឆន្ទថា បញ្ហាដែលបានលើកឡើងគឺពិតជាកើតមាននៅក្នុងសហគមន៍របស់ពួកគេពិតមែន ក៏ដូចជាប្រមូលទស្សនៈផ្សេងៗទៀតចំពោះបញ្ហាទាំងនេះ ។

ក្រៅពីកិច្ចពិភាក្សាជាក្រុម អ្នកសិក្សាស្រាវជ្រាវក៏បានសម្ភាសជាមួយប្រជាពលរដ្ឋមកពីសហគមន៍នីមួយៗចន្លោះពី ២ ទៅ ៤ នាក់ ដែលមិនបានចូលរួមនៅក្នុងកិច្ចពិភាក្សាជាក្រុម ។ អ្នកសិក្សាស្រាវជ្រាវបានសួរសំណួរជាច្រើនអំពីស្ថានភាពសេដ្ឋកិច្ច និងទំនាក់ទំនងបំណុល របស់បុគ្គលម្នាក់ៗ ។ កិច្ចសម្ភាសន៍លក្ខណៈបុគ្គលទាំងនេះ ត្រូវបានរៀបចំតាមបែបបទក្នុងកម្រិតមធ្យម និងបានចំណាយពេលប្រហែលមួយម៉ោង ហើយលទ្ធផលនៃកិច្ចសម្ភាសន៍របស់ពួកគេ ត្រូវបានប្រើប្រាស់ ដើម្បីបញ្ជាក់ ឬបំពេញបន្ថែមទៅលើសេចក្តីសន្និដ្ឋាន ដែលបានមកពីកិច្ចពិភាក្សាជាក្រុម ។

សរុបមក អ្នកសិក្សាស្រាវជ្រាវ ដែលមានស្ត្រី២នាក់ និងបុរស២នាក់ បានសម្របសម្រួលឱ្យមានកិច្ចពិភាក្សាជាក្រុមចំនួន ១៤លើក ដោយមានអ្នកចូលរួមចំនួន ១២៤នាក់ (ស្ត្រី៨៣នាក់ និងបុរស៤១នាក់) ក៏ដូចជាកិច្ចសម្ភាសន៍ជាលក្ខណៈបុគ្គលចំនួន ៤៧លើក (ស្ត្រី៣៩នាក់ និងបុរស៨នាក់) ។ ជារួម កិច្ចពិភាក្សាបានចំណាយពេលសរុបជាង ១០០ម៉ោង ។ បន្ទាប់មក អ្នកសិក្សាស្រាវជ្រាវ បានវិភាគទៅលើកិច្ចពិភាក្សាទាំងនោះ ដើម្បីបង្កើត "កម្រងព័ត៌មានសហគមន៍" ចំនួន ១៤ ។ កម្រងព័ត៌មានទាំងនេះ បង្ហាញពីបញ្ហាសំខាន់ៗ ដែលប្រឈមដោយសហគមន៍នីមួយៗក្នុងចំណោមសហគមន៍ទាំង ១៤ និងផ្តល់ព័ត៌មានលម្អិតអំពី បទពិសោធន៍របស់សមាជិកសហគមន៍ជាមួយបំណុលមីក្រូហិរញ្ញវត្ថុ ។

[៤] សហគមន៍ចំនួន១២ ក្នុងចំណោមសហគមន៍ទាំង១៤ តួនាទីរបស់តំណាងសហគមន៍ត្រូវបានឯកភាព និងសម្រេចដោយការបោះឆ្នោតរៀបចំដោយសមាជិកទាំងអស់នៅក្នុងសហគមន៍ ។ នៅក្នុងសហគមន៍ពីរដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ ពុំមានតំណាងសហគមន៍ដែលត្រូវបានបោះឆ្នោតឱ្យកាន់តួនាទីផ្លូវការនៅក្នុងសហគមន៍ទេ ប៉ុន្តែមានជនបង្គោលដែលគ្រប់គ្រងជាមួយការគាំទ្រពីសមាជិកសហគមន៍ និងជារឿយៗសម្របសម្រួលការងារជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរ ប្រមូលឯកសារ និងសកម្មនៅក្នុងបញ្ហាតស៊ូមតិ ។

បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវ បានជួបផ្ទាល់ដោយឡែកជាមួយសមាជិកពីរនាក់របស់សហគមន៍នីមួយៗ យ៉ាងតិចណាស់មានសមាជិកសហគមន៍ម្នាក់ក្នុងចំណោមពួកគេទាំងពីរនាក់ ជាតំណាងសហគមន៍ និងបានចូលរួមក្នុងកិច្ចពិភាក្សាជាក្រុម ហើយបានពិនិត្យមើលសេចក្ដីព្រាងនៃកម្រងព័ត៌មានសហគមន៍ ដើម្បីធានាថាព័ត៌មានគឺគ្រប់ជ្រុងជ្រោយ ត្រឹមត្រូវ និងឆ្លុះបញ្ចាំងពីបទពិសោធន៍ពិតប្រាកដរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ។ ការកែសម្រួល ការផ្លាស់ប្ដូរ និងការបន្ថែមព័ត៌មាន ត្រូវបានធ្វើឡើង នៅក្នុងដំណើរការនៃកិច្ចសហការនេះ ។

បន្ទាប់ពីមានការរៀបចំកិច្ចពិភាក្សាជាក្រុមចំនួន១៤លើក និងកិច្ចប្រជុំផ្ទៀងផ្ទាត់ចំនួន ១៤ដងរួចមក អ្នកសិក្សាស្រាវជ្រាវបានសម្របសម្រួលឱ្យមានកិច្ចប្រជុំឯកភាពជាមួយតំណាងសហគមន៍ ដើម្បីពិនិត្យមើលកម្រងព័ត៌មានសហគមន៍ចុងក្រោយ ដើម្បីស្ដាប់ការធ្វើបទបង្ហាញពីលទ្ធផលរបស់សហគមន៍ដទៃទៀត និងដើម្បីពិភាក្សាចែករំលែកចំណេះដឹង និងលើកជាសំណួរ ឬកង្វល់ ដែលពួកគេមានអំពីផ្នែកណាមួយនៃគម្រោងស្រាវជ្រាវ ឬផែនការចេញផ្សាយនៃការស្រាវជ្រាវនេះ ។

កិច្ចប្រជុំទាំងនេះ បានបង្កើតទិដ្ឋភាពសុវត្ថិភាព និងសន្តិសុខ ដ៏សំខាន់មួយ ទៅលើការសិក្សាស្រាវជ្រាវនេះ ។ ការសិក្សាស្រាវជ្រាវកាលពីមុន បាននាំឱ្យមានការធ្វើទុក្ខបុកម្នេញពីសំណាក់បុគ្គលជាមន្ត្រីឥណទានមួយចំនួននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទៅលើអ្នកខ្ចីប្រាក់ដែលបានរៀបរាប់ពីការរំលោភបំពានទៅកាន់ សារព័ត៌មាន ឬអង្គការមិនមែនរដ្ឋាភិបាល ។ អ្វីដែលគួរឱ្យកត់សម្គាល់ខ្លាំងជាងគេ គឺសមាគមមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បានសម្រេចតាមដាននិងបង្ហាញជាសាធារណៈនូវអត្តសញ្ញាណរបស់អ្នកដែលបានផ្ដល់ព័ត៌មានឱ្យអ្នកសិក្សាស្រាវជ្រាវរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងលក្ខខណ្ឌលាក់បាំងអត្តសញ្ញាណ ។

ដើម្បីការពារហេតុការណ៍នេះកុំឱ្យកើតឡើងម្ដងទៀត អ្នកសិក្សាស្រាវជ្រាវបានសម្រេចចិត្ត មិនលាក់បាំងអត្តសញ្ញាណអ្នកចូលរួម ឬបញ្ចូលករណីសិក្សាដែលគ្មានឈ្មោះ នៅក្នុងការសិក្សាស្រាវជ្រាវទេ ដើម្បីជៀសវាងការព្រួយបារម្ភថា បុគ្គលមួយចំនួននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនេះអាចស្វែងរកនិងលាតត្រដាងពួកគាត់ម្ដងទៀត ។ ប៉ុន្តែសមាជិកសហគមន៍បានឯកភាពឱ្យមានការចែករំលែករឿងរ៉ាវរបស់ពួកគាត់ភ្ជាប់ជាមួយនឹងឈ្មោះសហគមន៍ ហើយតំណាងសហគមន៍ក៏បានឯកភាពឱ្យផ្សព្វផ្សាយជាសាធារណៈ នូវឈ្មោះរបស់ពួកគាត់នៅក្នុងការសិក្សាស្រាវជ្រាវនេះដែរ ។ ទាំងអង្គការសមធម៌កម្ពុជា និងអង្គការលីកាដូ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សមាជិកសហគមន៍ដែលហ៊ានប្រឈមនឹងហានិភ័យផ្ទាល់ខ្លួន ក្នុងការនិយាយជាសាធារណៈអំពីបញ្ហាសំខាន់នៃបំណុលមីក្រូហិរញ្ញវត្ថុ ហើយយើងខ្ញុំសូមស្នើសុំដល់ភាគីពាក់ព័ន្ធទាំងអស់ឱ្យជៀសវាងពីការផ្ចាញ់ផ្ចាល់ ឬការធ្វើទុក្ខបុកម្នេញ ចំពោះអ្នកខ្ចីប្រាក់ដែលបានចែករំលែកបទពិសោធន៍របស់ពួកគេ កាលពីមុន ។

## កំណត់ចំណាំលើវិធីសាស្ត្ររបស់យើងខ្ញុំ

ចាប់តាំងពី ខែសីហា ឆ្នាំ២០១៩ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បានចេញផ្សាយជាសាធារណៈនូវរបាយការណ៍ចំនួនបី ដើម្បីបង្ហាញពីការរំលោភសិទ្ធិមនុស្សក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ។ ការរកឃើញនៅក្នុងរបាយការណ៍ទាំងនេះ បង្ហាញពីករណីជាច្រើននៃការលក់ដីដោយបង្ខំដើម្បីសងបំណុល ពលកម្មកុមារ ចំណាកស្រុកដោយសារបញ្ហាបំណុល និងការកាត់បន្ថយអាហារបរិភោគនៅក្នុងគ្រួសារដើម្បីគេចចេញពីភាពអាម៉ាស់ ពីឥរិយាបថរបស់មន្ត្រីឥណទាននៅមូលដ្ឋាន នៅពេលដែលពួកគាត់ដល់ពេលបង់សងកម្ចីឥណទាន ។

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទាំងពីរ នៅតែគាំទ្រលើការរកឃើញទាំងនេះ និងប្ដេជ្ញា ដើម្បីបន្លឺសំឡេងប្រជាពលរដ្ឋ និងសហគមន៍ដែលរងផលប៉ះពាល់ដោយបញ្ហាជាប់ជំពាក់បំណុលច្រើនលើសលុប ។ ប៉ុន្តែរបាយការណ៍ទាំងនេះ ក៏ប្រឈមនឹងការរិះគន់ចំពោះគុណភាពនៃការប្រើប្រាស់វិធីសាស្ត្រ ដោយមានបុគ្គលមួយចំនួនដែលមានទំនាក់ទំនងនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុសួរថា "ហេតុអ្វីអ្នកមិនសិក្សាស្រាវជ្រាវជាមួយអតិថិជនឱ្យបានទូលំទូលាយជាងនេះ"?

**ប្រសិនបើអ្នកផ្ដល់កម្ចីឥណទានខ្នាតតូច និងវិនិយោគិនរបស់ពួកគេពិតជាចង់ ផ្ដល់តម្លៃនៃសំឡេងរបស់អតិថិជន ឬយល់ដឹងពី ការយល់ឃើញរបស់អតិថិជន ដូចអ្វីដែលពួកគេជាច្រើនបានអះអាងថា ពួកគេត្រូវតែយកចិត្តទុកដាក់ឱ្យបានខ្លាំងទៅលើ រឿងរ៉ាវ សំឡេង និងបទពិសោធន៍ដែលបានរាយការណ៍នៅក្នុងគម្រោងនេះ ។**

ចម្លើយគឺថា ដោយសារការរៀបចំកិច្ចពិភាក្សាអំពីបញ្ហាបំណុលឱ្យបានហ្មត់ចត់ដោយផ្អែកលើសហគមន៍ជាមូលដ្ឋានគឺមានតម្លៃជាង ហើយជារឿយៗ កិច្ចពិភាក្សាទាំងនេះ តែងតែអាចលើកឡើងនូវបញ្ហាមួយចំនួន ដែលត្រូវបានមើលរំលងនៅក្នុងការសិក្សាស្រាវជ្រាវបែបទូលំទូលាយ ។ យើងខ្ញុំ បន្តស្នើសុំឱ្យមានការសិក្សាស្រាវជ្រាវគ្រប់ប្រភេទបន្ថែមទៀត ទៅលើបញ្ហាជាប់ជំពាក់បំណុលច្រើនលើសលុប និងការរំលោភសិទ្ធិមនុស្ស នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ប៉ុន្តែក៏មាន ឧទាហរណ៍មួយចំនួនស្ដីពីរបៀបដែលការសិក្សាស្រាវជ្រាវបែបទូលំទូលាយ ដោយផ្អែកលើការសន្មតមិនត្រឹមត្រូវមួយចំនួនអំពីជីវភាពរស់នៅរបស់អ្នកខ្ចីប្រាក់ អាចបង្កើតឱ្យមានសេចក្ដីសន្និដ្ឋានខុស ។

ឧទាហរណ៍មួយអាចរកបាននៅក្នុងរបាយការណ៍ស្ដីពី "ទស្សនៈរបស់អតិថិជនស្ដីពីកិច្ចការពារសម្រាប់អ្នកប្រើប្រាស់" ចេញផ្សាយកាលពីខែសីហា ឆ្នាំ២០២០ ដោយមជ្ឈមណ្ឌលសម្រាប់ការដាក់

បញ្ចូលហិរញ្ញវត្ថុ ("មជ្ឈមណ្ឌល CFI") ដែលជាស្ថាប័នប្រឹក្សាយោបល់លើបញ្ហាមីក្រូហិរញ្ញវត្ថុដ៏ល្បីឈ្មោះ មានទីស្នាក់ការនៅសហរដ្ឋអាមេរិក[៥] ។ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបង្កើតឡើងជាការឆ្លើយតបទៅនឹង របាយការណ៍ "ការខូតខាតទ្រព្យបញ្ចាំ" ដែលចេញផ្សាយកាលពីខែសីហា ឆ្នាំ២០១៩ ដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនៅកម្ពុជា ដែលធ្វើការលើវិស័យសិទ្ធិមនុស្ស[៦] ។

នៅក្នុងការបង្ហោះសារមួយនៅលើប្លក់ (blog) ក្នុងឆ្នាំ២០១៩ "មជ្ឈមណ្ឌល CFI" បានសួរថា "តើការដកហូតទ្រព្យធានានៃបំណុលជាបញ្ហាកំពុងវិវត្តន៍គួរឱ្យព្រួយបារម្ភ ឬការសិក្សាស្រាវជ្រាវរបស់អង្គការលីកាដូឆ្លុះបញ្ចាំងពីការច្បិចយកតែករណីដែលមានបញ្ហា ? យើងសង្ឃឹមថា ការសិក្សាស្រាវជ្រាវថ្មីមួយដោយ "មជ្ឈមណ្ឌល CFI" នឹងបកស្រាយលើបញ្ហានេះ"។

ជាផ្នែកមួយនៃការសិក្សាស្រាវជ្រាវរបស់ពួកគេ "មជ្ឈមណ្ឌល CFI" បានស្ទង់មតិជាមួយមនុស្សជាង ១០០០នាក់ ។ ពួកគេប្រើប្រាស់មន្ត្រីឥណទានមីក្រូហិរញ្ញវត្ថុ ដើម្បីរៀបចំអ្នកខ្ចីប្រាក់និងពន្យល់ពីការស្ទង់មតិ ទោះបីជាមន្ត្រីឥណទានទាំងនេះជាមនុស្សដដែល ដែលត្រូវបានចោទប្រកាន់ដោយអង្គការមិនមែនរដ្ឋាភិបាលចំពោះការដាក់សម្ពាធ និងរួមចំណែកក្នុងការរំលោភបំពាន ។ ទោះបីជាការលក់ដីត្រូវបានចែងជាគោលបំណងចម្បងនៅក្នុងការសិក្សាស្រាវជ្រាវ "មជ្ឈមណ្ឌល CFI"បានសាកសួរអ្នកឆ្លើយសំណួរចំនួន ១៥៩នាក់ តែប៉ុណ្ណោះ ថាតើពួកគេបានលក់ទ្រព្យ ដើម្បីសងបំណុល ឬទេ ។ នេះដោយសារតែ "មជ្ឈមណ្ឌល CFI" បានសម្រេចចិត្តបង្រួមសំណួរសម្រាប់ក្រុមអ្នកឆ្លើយសំណួរ ដោយផ្អែកលើថាតើអ្នកខ្ចីប្រាក់បានរាយការណ៍អំពី "បញ្ហាលំបាក" ក្នុងការសងកម្ចីឥណទានវិញ ឬទេ ។

ប៉ុន្តែការរកឃើញរបស់យើងខ្ញុំបានបង្ហាញថា នៅពេលដែលអ្នកខ្ចីប្រាក់ណាម្នាក់លក់ដីដោយបង្ខំឬមិនបង្ខំក្តី ហើយគាត់មានប្រាក់ក្នុងដៃ វាទំនងជាមិន "ពិបាក" សម្រាប់ពួកគេក្នុងការសងកម្ចីឥណទានវិញនោះទេ ។ នេះជាសម្រង់សម្តីរបស់សមាជិកសហគមន៍ម្នាក់ ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវក្នុងរបាយការណ៍នេះ៖ "ទេ ខ្ញុំគ្មានបញ្ហាលំបាកក្នុងការសងកម្ចីមីក្រូហិរញ្ញវត្ថុទេ ។ ខ្ញុំលក់ដី ដើម្បីសងកម្ចីទាំងនោះ" ។ ការលក់ដី និងការរងសម្ពាធផ្នែកសេដ្ឋកិច្ចនៅពីក្រោយទំនងជាមិនអាចបង្ហាញនៅក្នុងការស្ទង់មតិរបស់ "មជ្ឈមណ្ឌល CFI" ទេ ។

នេះជាឧទាហរណ៍ល្អមួយបញ្ជាក់ពីសារៈសំខាន់នៃការសិក្សាស្រាវជ្រាវផ្អែកលើសហគមន៍ជាមូលដ្ឋាន ដែលត្រូវបានធ្វើឡើងដោយក្រុមដែលបានចំណាយពេលវេលាក្នុងការបង្កើតទំនាក់ទំនងនៃទំនុកចិត្ត និងការយល់ពីគ្នាទៅវិញទៅមកជាមួយសហគមន៍ ។ វាក៏ជាឧទាហរណ៍បញ្ជាក់ពីមូលហេតុ ដែលការសិក្សាស្រាវជ្រាវក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ត្រូវតែធ្វើឡើងដោយឯករាជ្យ និងមិនពឹងផ្អែកទាំងស្រុងទៅលើមន្ត្រីឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬថ្នាក់ដឹកនាំគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីណែនាំ ឬសម្របសម្រួលបទសម្ភាសជាមួយអតិថិជនទេ ។

យើងខ្ញុំជឿជាក់យ៉ាងមុតមាំថាមានតម្រូវការជាក់ស្តែងសម្រាប់ការសិក្សាស្រាវជ្រាវឱ្យមានបរិមាណច្រើន ចំពោះការលើកឡើងពីបញ្ហាជំពាក់បំណុលច្រើនលើសលុប ដោយសារកម្ចីឥណទានខ្នាតតូច ។ ប៉ុន្តែប្រសិនបើគ្មានឬសគល់នៃការសិក្សាស្រាវជ្រាវក្នុងការយល់ដឹងស៊ីជម្រៅពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមពីមួយថ្ងៃទៅមួយថ្ងៃនៃបំណុលមីក្រូហិរញ្ញវត្ថុ ទៅលើអ្នកខ្ចីប្រាក់ គ្រួសារនិងសហគមន៍របស់ពួកគេ ការស្ទង់មតិទាំងនេះនឹងមិនអាចក្តោបយកឱ្យបានពេញលេញនូវបញ្ហា និងការរំលោភសិទ្ធិមនុស្សពាក់ព័ន្ធនឹងបំណុលឥណទានខ្នាតតូចនោះទេ ។

បទពិសោធន៍របស់អ្នកខ្ចីកម្ចីឥណទានខ្នាតតូចនៅកម្ពុជា គឺមានភាពស្មុគស្មាញ ។ ទាំងនេះពាក់ព័ន្ធនឹងបញ្ហាប្រទាក់ក្រឡាគ្នាដូចជាការធ្លាក់ចុះនៃតម្លៃកសិផល គ្រោះរាំងស្ងួត សម្ពាធពីអាជ្ញាធររដ្ឋនិងការធ្លាក់ចុះចំណូល ដោយសារបញ្ហាជំងឺកូវីដ១៩ ។ ពួកគេក៏មានបញ្ហាផ្លូវចិត្តផងដែរដូចជា ភាពអៀនខ្មាសជុំវិញការជំពាក់កម្ចីឥណទាន ឬគ្មានលទ្ធភាពសងកម្ចីឥណទាន ឬភាពភ័យខ្លាចអាជ្ញាធរមូលដ្ឋាន ក៏ដូចជាដំណើររាំងស្ទះនៃកង្វះប្រព័ន្ធយុត្តិធម៌ ដែលស្មើភាពនិងឥតលំអៀង ក្នុងការទាមទារសំណង ។ មួយចំនួននៃកត្តាទាំងនេះ គឺប្លែកពីគេ ក្នុងបរិបទប្រទេសកម្ពុជា ប៉ុន្តែកត្តាផ្សេងៗទៀតគឺទំនងជាមានលក្ខណៈសកលដូចគ្នា ក្នុងចំណោមអ្នកខ្ចីនៅជុំវិញពិភពលោក ។

ប្រសិនបើអ្នកផ្តល់កម្ចីឥណទានខ្នាតតូច និងវិនិយោគិនរបស់ពួកគេពិតជាចង់ "ផ្តល់តម្លៃនៃសំឡេងរបស់អតិថិជន" ឬយល់ដឹងពី "ការយល់ឃើញរបស់អតិថិជន" ដូចអ្វីដែលពួកគេជាច្រើនបានអះអាងថា ពួកគេត្រូវតែយកចិត្តទុកដាក់ឱ្យបានខ្លាំងទៅលើ រឿងរ៉ាវ សំឡេង និងបទពិសោធន៍ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍នេះ ។

[៥] "ទស្សនៈរបស់អតិថិជនស្តីពីកិច្ចការពារសម្រាប់អ្នកប្រើប្រាស់៖ បទវិភាគនៃការស្ទង់មតិមួយជាមួយអតិថិជននៅកម្ពុជា" ចេញផ្សាយថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ ។ អាចរកបាននៅ៖ https://www.centerforfinancialinclusion.org/client-perspectives-on-consumer-protection-analysis-of-a-client-survey-in-cambodia

[៦] "ការរឹបអូសដីធ្លី និងការរំលោភបំពានដែលត្រូវបានរាយការណ៍នៅក្នុងប្រទេសកម្ពុជា៖ ការឆ្លើយតបរបស់មជ្ឈមណ្ឌល CFI" ចេញផ្សាយថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៩ ។ អាចរកបាននៅ៖ https://www.centerforfinancialinclusion.org/land-seizures-and-reported-abuses-in-cambodia-the-center-for-financial-inclusion-responds

# អាជ្ញាធរមូលដ្ឋាន

ជាញឹកញាប់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការជាមួយអាជ្ញាធរមូលដ្ឋាន (ជាទូទៅមេភូមិនិងមេឃុំ) ដើម្បីស្នើផ្តល់កម្ចីឥណទានខ្នាតតូចផង និងជានាឱ្យមានការបង់សងផង ។ ផ្នែកនេះ គឺជាការរួមបញ្ចូលគ្នានៃការពាក់ព័ន្ធរបស់អាជ្ញាធរមូលដ្ឋានជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅគ្រប់សហគមន៍ទាំងអស់ក្នុងរបាយការណ៍នេះ ។ ឯកសារយោងទៅនឹងអាជ្ញាធរមូលដ្ឋាន ត្រូវបានលុបចេញពីកម្រងព័ត៌មានសហគមន៍នីមួយៗ និងអាចរកបាននៅទីនេះជំនួសវិញ ដើម្បីការពារសមាជិកសហគមន៍ឱ្យកាន់តែប្រសើរពីការធ្វើទុក្ខបុកម្នេញរបស់អាជ្ញាធរមូលដ្ឋាន ក៏ដូចជាអនុញ្ញាតឱ្យពួកគាត់បញ្ចេញមតិដោយគ្មានការភ័យខ្លាចអំពីប្រធានបទពាក់ព័ន្ធនឹងអំពើពុករលួយ និងឥរិយាបថមិនសមរម្យនៅក្នុងចំណោមអាជ្ញាធរមូលដ្ឋាន ។

លទ្ធផលទាំងនេះ ធ្វើឡើងបន្ថែមលើការសិក្សាស្រាវជ្រាវកន្លងមកដែលបានបង្ហាញថា អ្នកផ្តល់កម្ចីឥណទានខ្នាតតូចជាញឹកញាប់ ប្រើប្រាស់អាជ្ញាធរមូលដ្ឋាន ដើម្បីសម្រួលឱ្យមានការបង់សង ហើយហេតុនេះធ្វើឱ្យអ្នកផ្តល់កម្ចីឥណទានខ្នាតតូច ប្រើប្រាស់អំពើពុករលួយដ៏ទូលំទូលាយ ដើម្បីបង្ខំអ្នកខ្ចីប្រាក់បង់សងទាន់ពេលវេលា ។[៧] ការអនុវត្តបែបនេះ នៅតែបន្តកើតមានឡើង ទោះបីជាមានលិខិតពីក្រសួងមហាផ្ទៃ កាលពីខែមីនា ឆ្នាំ២០១៧ ដែលបានបញ្ជាឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិទាំងស៊ីវិល នគរបាល និងកងរាជអាវុធហត្ថឱ្យបញ្ឈប់ និងដកខ្លួនជាបន្ទាន់ ពីការចូលរួមសកម្មភាពជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលនាំឱ្យមានការយល់ច្រឡំថាជារបស់រដ្ឋតែតាមពិតគឺជារបស់ឯកជនសុទ្ធសាធ ។[៨]

## "លិខិតបញ្ជាក់ពីមេភូមិ មេឃុំគឺឱ្យអាជ្ញាធរឃើញ និងទទួលស្គាល់ការខ្ចីប្រាក់ហើយងាយស្រួលដាក់សម្ពាធអ្នកខ្ចី និងរឹបអូសទ្រព្យបញ្ចាំបើអ្នកខ្ចីអត់សង"

នៅគ្រប់សហគមន៍ទាំងអស់ដែលត្រូវបានសម្ភាសនៅក្នុងគម្រោងនេះ សមាជិកសហគមន៍បានរៀបរាប់ថា មេភូមិ និងមេឃុំ បានជាប់ពាក់ព័ន្ធនឹងដំណើរការនៃកម្ចីឥណទានខ្នាតតូច ។ នៅពេលដែលដីធ្លីត្រូវបានប្រើប្រាស់ជាទ្រព្យធានា អ្នកខ្ចីប្រាក់ត្រូវមានការយល់ព្រមជាមុន ពីមេភូមិ និងមេឃុំ ។ ស្ទើរតែគ្រប់ពេលនៃការយល់ព្រមគឺត្រូវបង់ប្រាក់ក្រៅផ្លូវការ ដែលពេលខ្លះមើលទៅដូចជាការសូកប៉ាន់ និងពេលខ្លះទៀតមើលទៅដូចជាកម្រៃសេវា ។ ជារឿយៗ "កម្រៃ" នេះក៏ត្រូវបានប្រមូល នៅពេលដែលអ្នកខ្ចីប្រាក់ ត្រូវលក់ដីរបស់ពួកគេដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ ជាដំណើរការមួយដែលត្រូវការការយល់ព្រមពីអាជ្ញាធរមូលដ្ឋាន ។

នៅក្នុងសហគមន៍ចំនួន ៨ នៃសហគមន៍ទាំង ១៤ អាជ្ញាធរបានជាប់ពាក់ព័ន្ធក្នុងការដាក់សម្ពាធអ្នកខ្ចីប្រាក់ដើម្បីឱ្យសងកម្ចីឥណទានខ្នាតតូច ក្នុងនោះមានសហគមន៍ចំនួន ៤ ដែលការលក់ដីត្រូវបានដាក់សម្ពាធដោយផ្ទាល់ពីសំណាក់មន្ត្រីរដ្ឋាភិបាល ។ ជាងនេះទៅទៀត អាជ្ញាធរឃុំ អាចនឹងកោះហៅបុគ្គលដែលយឺតយ៉ាវក្នុងការបង់សងដើម្បីជួបប្រជុំគ្នារវាងមន្ត្រីឥណទាន អាជ្ញាធរមូលដ្ឋាន និងអ្នកខ្ចីប្រាក់ ។ អ្នកគ្រប់គ្រងនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ ធ្លាប់បានពិពណ៌នាការអនុវត្តបែបនេះថាជា ការប្រជុំ "សម្របសម្រួល" និងបានលើកឡើងថា ជាញឹកញាប់ អាជ្ញាធរមូលដ្ឋានបានទទួលប្រាក់ពីអ្នកផ្តល់កម្ចីខ្នាតតូច សម្រាប់សេវាសម្របសម្រួលនេះ ។

## "ភូមិឃុំទទួលដឹងឮ និងជាសាក្សី ពេលយើងអត់សងគេ ស្រួលគេរឹបអូសទ្រព្យ។"

នៅក្នុងកិច្ចប្រជុំទាំងនេះ អាជ្ញាធរបានប្រើប្រាស់មធ្យោបាយផ្សេងៗគ្នា ដើម្បីដាក់សម្ពាធទៅកាន់អ្នកខ្ចីប្រាក់ ។ អ្នកខ្ចីប្រាក់ក្នុងករណីមួយចំនួន ត្រូវបានដាក់សម្ពាធដោយផ្ទាល់ ដូចជា ករណីមួយដែលមេឃុំបាននិយាយថា "អ្នកនឹងត្រូវលក់ដីដើម្បីបង់សង" ។ ករណីផ្សេងទៀត ការប្រជុំ (ឬសូម្បីតែពេលខ្លះមានការគំរាមកំហែងនៅក្នុងការប្រជុំ) បានបង្កើតការភ័យខ្លាចចំពោះអ្នកខ្ចីប្រាក់ និងបង្ខំឱ្យពួកគេលក់ដី ដើម្បីសងកម្ចីឥណទាន ។ អ្នកខ្ចីប្រាក់ជាច្រើនបានលើកឡើងថា អ្នកផ្តល់កម្ចីឥណទានខ្នាតតូច បានរាយការណ៍ពីការយឺតយ៉ាវក្នុងការបង់សងទៅកាន់មេឃុំ ជាប្រចាំ ហើយការកោះហៅទៅការិយាល័យរដ្ឋទាំងនេះ ជារឿយៗគឺជាប្រភពនៃ ការកើតទុក្ខ និងភាពភ័យខ្លាច ។ នៅក្នុងសហគមន៍យ៉ាងតិចមួយ មន្ត្រីឃុំក៏ដើរតួជាអ្នកចងការឯកជនផងដែរ ។ គាត់បានរៀបចំកិច្ចប្រជុំសម្រាប់ប្រជាពលរដ្ឋ

[៧] "ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពានក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" របស់អង្គការលីកាដូ និងអង្គការសមាគមធាងត្នោត ចេញផ្សាយខែសីហា ឆ្នាំ២០១៩ ដែលអាចរកបាននៅតំណភ្ជាប់នេះ: https://www.licadho-cambodia.org/reports.php?perm=228&khmer
[៨] សេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃ លេខ ៥៥៦ សជណ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៧.

ក្នុងមូលដ្ឋានដើម្បីចូលរួម ជាពេលដែលគាត់បាននិយាយថា គាត់ដឹងថាគ្រប់គ្នាជាប់ជំពាក់បំណុលមីក្រូហិរញ្ញវត្ថុច្រើន ហើយប្រសិនបើពួកគេត្រូវការប្រាក់កម្ចីឯកជន ពួកគេអាចយកប្រាក់កម្ចីពីគាត់បាន ។

បន្ថែមពីលើការដាក់សម្ពាធឱ្យបង់សង អាជ្ញាធរមូលដ្ឋានគឺមានជាប់ពាក់ព័ន្ធក្នុងការស្នើផ្តល់កម្ចីឥណទានខ្នាតតូចផងដែរ ។ សហគមន៍ ៥ ក្នុងចំណោមសហគមន៍ទាំង ១៤ ដែលបានផ្តល់បទសម្ភាសន៍ អាជ្ញាធរមូលដ្ឋាន បានជួយស្នើផ្តល់កម្ចីឥណទាន និងបានដើរតួជាអ្នកសម្របសម្រួលរវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអ្នកខ្ចីប្រាក់ ។ កាលពីប៉ុន្មានឆ្នាំមុនមានករណីមួយ ដែលមេភូមិ គឺជាមេក្រុមនៃកម្ចីឥណទាន ហើយអ្នកខ្ចីប្រាក់ត្រូវបានបង្កើតឡើង ដើម្បីបង់សងផ្ទាល់ទៅគាត់ជាជាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ក្នុងករណីចំនួន ៣ មេភូមិ បានផ្សព្វផ្សាយយ៉ាងសកម្មសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងសម្របសម្រួលអ្នកខ្ចីប្រាក់ឱ្យយកកម្ចីឥណទាន ដោយរៀបចំជាព្រឹត្តិការណ៍នៅផ្ទះ ឬចែកចាយព័ត៌មានរបស់ពួកគេ ជាដើម ។

អាជ្ញាធរមូលដ្ឋានក្នុងសហគមន៍ចំនួនពីរ បានចាត់វិធានការ ដែលត្រូវបានមើលឃើញថាជា ការជួយ ឬការតស៊ូមតិក្នុងនាមជាអ្នកខ្ចីប្រាក់ ។ អ្នកខ្ចីប្រាក់ក្នុងករណីមួយ បានទៅផ្ទះរបស់មេភូមិ ដើម្បីស្នើសុំការយល់ព្រមទៅលើកម្ចីឥណទានមួយ ហើយមេភូមិបានប្រាប់ទៅអ្នកខ្ចីប្រាក់ថា ការប្រាក់នៃកម្ចីឥណទានគឺខ្ពស់ណាស់ ដូច្នេះអ្នកខ្ចីប្រាក់គួរចរចាដើម្បីឱ្យមានអត្រាការប្រាក់ទាបជាងនេះ ។ អ្នកខ្ចីប្រាក់ក្នុងករណីមួយទៀត បានគេចខ្លួនទៅប្រទេសថៃ ហើយមន្ត្រីឥណទាននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានកោះហៅសាក្សីដែលបានផ្តិតមេដៃលើកម្ចីឥណទាននោះ ឱ្យមកជួបជាមួយអាជ្ញាធរឃុំ ។ មេឃុំបានប្រាប់មន្ត្រីឥណទាន កុំឱ្យដាក់សម្ពាធខ្លាំងលើសាក្សី ពុំនោះទេពួកគេនឹងគេចខ្លួនទៅប្រទេសថៃ ដូចជាអ្នកខ្ចីប្រាក់ដែរ ។

# ព័ត៌មានអំពីសហគមន៍



សហគមន៍ក្រាំងត្បែង
កំពង់ស្ពឺ
ទំព័រ ១៤ ដល់ ១៥



សហគមន៍បឹងប្រាំ
បាត់ដំបង
ទំព័រ ២៨ ដល់ ២៩



សហគមន៍ដកពរ
កំពង់ស្ពឺ
ទំព័រ ១៦ ដល់ ១៧



សហគមន៍ខ្ទុំ
ឧត្តរមានជ័យ
ទំព័រ ៣០ ដល់ ៣១



សហគមន៍ជីខក្រោម
កោះកុង
ទំព័រ ១៨ ដល់ ១៩



សហគមន៍ជោគជ័យ
ព្រះវិហារ
ទំព័រ ៣២ ដល់ ៣៣



សហគមន៍ជីខលើ
កោះកុង
ទំព័រ ២០ ដល់ ២១



សហគមន៍កាំ និងក្រេះ
រតនគិរី
ទំព័រ ៣៤ ដល់ ៣៥



សហគមន៍តានូន
កោះកុង
ទំព័រ ២២ ដល់ ២៣



សហគមន៍តាឡាវ និងអ៊ីន
បាត់ដំបង
ទំព័រ ៣៦ ដល់ ៣៧



សហគមន៍ដីធ្លីខេត្តប៉ៃលិន
ប៉ៃលិន
ទំព័រ ២៤ ដល់ ២៥



សហគមន៍មានជ័យស្រ្តីអភិវឌ្ឍន៍
ភ្នំពេញ
ទំព័រ ៣៨ ដល់ ៣៩



សហគមន៍អូរល្ហីប្រេង
បាត់ដំបង
ទំព័រ ២៦ ដល់ ២៧



សហគមន៍ភូមិ១៧
ភ្នំពេញ
ទំព័រ ៤០ ដល់ ៤១




# សហគមន៍ក្រាំងតៀង

៣៦ គ្រួសារ
វិវាទដីធ្លីចាប់ផ្តើមនៅឆ្នាំ ២០១០

**ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ (ប៉ាន់ប្រមាណ)**

១០០%

**ទំហំកម្ចីជាមធ្យម**

៤០០០ ដុល្លារ

**គ្រឹះស្ថានដែលផ្តល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍**

អេស៊ីលីដា • អេអឹមខេ • អម្រឹត • អិលអូអិលស៊ី • ប្រាសាក់ • ដាប់ប៊ែលយូប៊ី ហ្វាយនែន

## ព័ត៌មានអំពីសហគមន៍

សហគមន៍ក្រាំងតៀង ស្ថិតនៅក្នុងស្រុកឱរ៉ាល់ ខេត្ត កំពង់ស្ពឺ ។ សមាជិកសហគមន៍ បានចូលមករស់នៅទីនេះមុនរបប ខ្មែរក្រហម ហើយពួកគាត់ ទទួលបានដីតាំងពីឆ្នាំ ១៩៩៦ ។ ជាងពាក់កណ្តាល នៃចំនួនគ្រួសារសរុប មានសមាជិកគ្រួសារយ៉ាងតិចម្នាក់ ដែលកំពុង ឬធ្លាប់បានធ្វើការនៅក្នុងរោងចក្រកាត់ដេរ ។ គ្រួសារមួយចំនួន រកប្រាក់តាមរយៈ ការលក់ដូរទំនិញ ឬ ធ្វើជាកម្មករស៊ីឈ្នួល និង អ្នកផ្សេងទៀត ដើរបេះផ្សិត និងបន្លែផ្សេងៗទៀតពីព្រៃនៅក្បែរនោះ ។

នៅឆ្នាំ ២០១០ ក្រុមហ៊ុនភ្នំពេញ ស៊ូហ្គើរ របស់លោក លី យ៉ុងផាត់ សមាជិកព្រឹទ្ធសភាគណបក្សកាន់អំណាច បានចាប់ផ្តើមឈូសឆាយដីរបស់ពលរដ្ឋនៅក្នុងសហគមន៍ ដែលកំពុងបង្កបង្កើនផល ។ ទោះបីជាគ្រួសារខ្លះ បានរស់នៅទីនោះតាំងពីមុនរបបខ្មែរក្រហមក៏ដោយ ក៏ពួកគាត់នៅតែរងការបំភិតបំភ័យដោយសន្តិសុខប្រដាប់អាវុធ ហើយផ្ទះរបស់ពលរដ្ឋខ្លះទៀត ត្រូវបានដុតបំផ្លាញ ។ បន្ទាប់ពីរឹបអូសយកដីធ្លីរបស់គ្រួសារនីមួយៗក្នុងសហគមន៍ចន្លោះពី ១,៥ ទៅ ៥ហិកតា ក្រុមហ៊ុនបានចាក់ដីលុបទំនប់ទឹកចំនួន ៣ និងធ្វើឱ្យមានការបំពុលក្នុងអូរមួយ ។

## ប្រភពនៃប្រាក់ចំណូល

កម្មករស៊ីឈ្នួល • សិប្បកម្មត្បាញស្លឹក • កសិកម្មដាំដុះ • ចិញ្ចឹមសត្វ • ប្រមូលអនុផលព្រៃឈើ • កម្មករ-កម្មការិនីកាត់ដេរ • កម្មករសំណង់ • នេសាទ

## ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

បាត់បង់ប្រាក់ចំណូល • ផលប៉ះពាល់បរិស្ថាន • បញ្ហាសុខភាពផ្លូវចិត្ត • បាត់បង់ប្រភពទឹក

## បញ្ហាដែលមិនទាន់មានដំណោះស្រាយ

ការផ្តល់សំណង់មិនសមរម្យ

## បំណុលមីក្រូហិរញ្ញវត្ថុ

ប្រមាណ ១០០% នៃគ្រួសារសរុបបានខ្ចីប្រាក់ ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ មូលហេតុចម្បងនៃការខ្ចីប្រាក់មានដូចជា ដើម្បីប្រកបអាជីវកម្ម ព្យាបាលជំងឺ ទិញម៉ូតូ សង់ផ្ទះ ចំណាយលើពិធីមង្គលការ ឬសងបំណុលផ្សេងទៀត ។ សមាជិកសហគមន៍ បានកត់សម្គាល់ថារឿងតែមួយគត់ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសួរ មុនពេលផ្តល់ប្រាក់កម្ចី គឺថាតើអ្នកខ្ចីមានប័ណ្ណកម្មសិទ្ធិដីធ្លីឬទេ ។ ប្រហែលជាមួយភាគបីនៃគ្រួសារសរុប បានលក់ដីដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ ហើយអ្នកខ្ចីមួយចំនួន បានឱ្យកូនមិនទាន់គ្រប់អាយុទៅធ្វើការរកប្រាក់ ដើម្បីសងបំណុល ។ កម្ចីឯកជនពីអ្នកចងការប្រាក់ក្រៅផ្លូវការ ជាបញ្ហាធ្ងន់ធ្ងរមួយ ដែលជាធម្មតាត្រូវបានប្រើដើម្បីដោះបំណុលមីក្រូហិរញ្ញវត្ថុ ។

### សម្រង់ពាក្យសម្តីពីប្រជាពលរដ្ឋសហគមន៍

“ខ្ញុំអត់មានលុយសងទេ អ៊ីចឹងហើយខ្ញុំលក់ដី... ខ្ញុំខ្លាចថាបើខ្ញុំអត់លុយសងគេ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) គេនឹងលក់ដីខ្ញុំ”

“អត់មានវិធីណា ក្រៅពីលក់ដី លក់របស់ ឬ ខ្ចីពីគេ ដើម្បីសងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទេ ”

“មន្ត្រីឥណទាននិយាយថា ‘ខ្ចីពីណាខ្ចីទៅ ឱ្យតែបានលុយឱ្យខ្ញុំ’”

“កម្រិតបំណុលក្នុងគ្រួសារមួយៗ គឺច្រើនណាស់ ដល់ចឹងយើងគិតអីលែងចេញហើយ លែងទៅវត្តទៅវ៉ា ដោយសារអត់លុយទិញចង្ហាន់ប្រគេនព្រះសង្ឃ”

“ឥឡូវមានត្រឹម៣០០០៛ ទិញត្រីម្តងហូប២ពេល ។ កាលមិនទាន់ជំពាក់គេ យើងចេះតែបានហូបឆ្ងាញ់”

“មន្ត្រីឥណទានបាននិយាយថា “មីង! មីងលក់ដីមែន? បើលក់ដីលក់ឱ្យឆាប់ទៅ អាងមានលុយសងខ្ញុំ”

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

ធ្វើកសិកម្ម • សាងសង់ផ្ទះ • ប្រកបអាជីវកម្ម • ទិញម៉ូតូ • ការសិក្សាកូន • មង្គលការកូន • ព្យាបាលជំងឺ • សងបំណុលផ្សេងទៀត

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

ការវាយតម្លៃលើប្រាក់ចំណូល • មន្ត្រីឥណទានស្នើឱ្យដាក់ប័ណ្ណកម្មសិទ្ធិដីធ្លីទាំងអស់

- មន្ត្រីឥណទានចង់ឱ្យអ្នកខ្ចី ដាក់ប្លង់ដីលំនៅដ្ឋាន ដោយសារវាជាដីមានប្លង់រឹងចេញដោយក្រុមយុវជនស្ម័គ្រចិត្តសម្តេចតេជោ ។
- ករណីខ្លះ មន្ត្រីឥណទានផ្តល់ "ប្រាក់កម្ចីបន្ថែម" ថ្មី ឬធំជាងមុន ដោយគ្មានការវាយតម្លៃលើលទ្ធភាព បង់សងត្រឡប់ទៅវិញ របស់អ្នកខ្ចី ។ ករណីខ្លះទៀត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្នើផ្តល់ កម្ចីធំជាងមុនទៅអ្នកខ្ចីដើម្បីអូសទាញអតិថិជនពីគ្រឹះស្ថានផ្សេង ។

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទាន បានចុះតាមផ្ទះរបស់សមាជិកសហគមន៍ ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និង គោលការណ៍នៃកម្ចីដែរឬទេ?

- អ្នកខ្ចីភាគច្រើន មិនអាចអាន ឬសរសេរអក្សរទេ ដូច្នេះពួកគាត់ពឹងលើមន្ត្រីឥណទាន ឱ្យពន្យល់ពួកគាត់អំពី លក្ខខណ្ឌនៃកម្ចី ។ អ្នកខ្ចីជាច្រើន មិនយល់អំពីអត្រាការប្រាក់របស់ពួកគេទេ ។

> "បើយើងដាក់ប្លង់ដីស្រែចំការ គេអាចនឹងឱ្យខ្ចីតិច ឬ មិនឱ្យតែម្តង។ បើអ្នកដែលអត់មានប្លង់ដី គេមិនឱ្យខ្ចីទេ"

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការប្រមូលឥណទានដោយរំលោភបំពាន • ការផ្តល់កម្ចីឥណទានបែបកេងចំណេញ • ជំរុញឱ្យមានការខ្ចីកម្ចីឯកជន • ដាក់សម្ពាធឱ្យលក់ដី • គំរាមកំហែង

- មន្ត្រីឥណទាន ជំរុញអ្នកខ្ចីដែលយឺតក្នុងការបង់សង ឱ្យលក់ដី ។
- ករណីខ្លះ មន្ត្រីឥណទានរង់ចាំនៅផ្ទះអតិថិជនច្រើនម៉ោង(៩ព្រឹកដល់៦ល្ងាច) ដើម្បីទារប្រាក់ ។ ករណីខ្លះទៀត មន្ត្រី ឥណទានមកម្តង ៦នាក់ ។ ករណីមួយទៀត មន្ត្រីឥណទាន ចោទអ្នកខ្ចីថា ចង់គេចពីការសងប្រាក់ បន្ទាប់ពីគាត់មិននៅផ្ទះ ប៉ុន្មានថ្ងៃ ។ អ្នកខ្ចីឆ្លើយតបថា "ខ្ញុំគេចទៅណា បើផ្ទាំងបាយខ្ញុំនៅហ្នឹង" ។
- ករណីផ្សេងទៀត មន្ត្រីឥណទាន ណែនាំអ្នកខ្ចីទៅរកអ្នកចងការឯកជន ដែលអាចផ្តល់កម្ចីថ្មីដល់ពួកគេ ដើម្បីសងបំណុលខ្លួន ។

### ផលវិបាកនៃបំណុល

ធ្វើការបន្ថែម • ខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ • ខ្ចីប្រាក់ពីអ្នកចងការឯកជន • ពលកម្មកុមារ • កុមារបោះបង់ការសិក្សា • កាត់បន្ថយអាហារបរិភោគ • ភាពតានតឹងក្នុងគ្រួសារ • លក់ដី • លក់ទ្រព្យសម្បត្តិផ្សេងៗ

- ក្មេងស្រីម្នាក់ បោះបង់ការសិក្សា ដើម្បីធ្វើការជួយដោះបំណុល ។ ក្មេងស្រីម្នាក់ទៀតមិនទាន់គ្រប់អាយុធ្វើការ បានខ្ចីអត្តសញ្ញាណប័ណ្ណបងប្អូនជីដូនមួយ ដើម្បីចូលធ្វើការនៅរោងចក្រ ដែលជាការអនុវត្តទូទៅនៅក្នុងសហគមន៍ ។ នាងមិនចង់ឈប់ពីការសិក្សាទេ ប៉ុន្តែគ្រួសារនាងជំពាក់បំណុល និងកាតព្វកិច្ចចំណាយផ្សេងៗ ។
- អ្នកចងការឯកជនខ្លះ បានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីយកទៅចងការបន្ត ។ ពួកគេគិតអត្រាការប្រាក់ពី ១៥% ទៅ ២០% ក្នុងមួយខែ ហើយពេលខ្លះទាមទារឱ្យដាក់បញ្ចាំទាំងម៉ូតូ និងប័ណ្ណសម្គាល់ទោចក្រយាន្តយន្ត (កាតគ្រី)។

### ការប៉ះពាល់ផ្លូវចិត្ត

ភ័យខ្លាច • សម្ពាធ • អៀនខ្មាស • ព្រួយបារម្ភ

- អ្នកខ្ចីមាមានសម្ពាធផ្លូវចិត្តជុំវិញបញ្ហាអនាគតកូនៗរបស់ពួកគាត់ និង កង្វះអាហារហូបចុក ។
- អ្នកខ្ចីមានអារម្មណ៍អៀនខ្មាស ដោយសារជំពាក់បំណុលច្រើន ជាពិសេសនៅពេលដែលនិយាយជាមួយកូនៗអំពីបំណុល ។

> "ខ្ញុំជំពាក់គេច្រើន អ៊ីចឹងក៏ឱ្យកូនពីរនាក់ឈប់រៀន ។ កូនទី១ ឈប់រៀន អាយុ ១៣ឆ្នាំ និង កូនទី២ ឈប់រៀន អាយុ ១៤ឆ្នាំ"
>
> "ខ្ញុំខ្លាចថា គេនឹងយកដីខ្ញុំ "

## អំឡុងពេល ជំងឺកូវីដ១៩

### ការប្រែប្រួលនៃប្រាក់ចំណូល

ប្រាក់ចំណូលធ្លាក់ចុះ អំឡុងពេលជំងឺកូវីដ១៩

- តម្លៃកសិផលបានធ្លាក់ថ្លៃ ដោយសារតែមិនសូវមានទីផ្សារ និងរោងចក្រជាច្រើនត្រូវបានបិទ ឬ ព្យួររយៈពេលជាច្រើនខែ ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានមិនបានស្នើផ្តល់រៀបចំឥណទានឡើងវិញ • មន្ត្រីឥណទានបដិសេធរៀបចំឥណទានឡើងវិញ • មន្ត្រីឥណទាននិយាយថា ការរៀបចំឥណទានឡើងវិញគឺគ្មានប្រយោជន៍

- មិនមានសមាជិកសហគមន៍ណាម្នាក់ទទួលបានព័ត៌មានអំពីការរៀបចំឥណទានឡើងវិញពីមន្ត្រីឥណទានឡើយ ។ អ្នកខ្លះបានដឹងតាមរយៈទូរទស្សន៍ ។
- អ្នកខ្ចីម្នាក់ សងបំណុលតាមការផ្ញើប្រាក់ ហើយមិនដឹងថាគួរសួរអ្នកណាអំពីការរៀបចំឥណទានឡើងវិញ ។
- មន្ត្រីឥណទានមួយចំនួនពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងៗគ្នា បានឆ្លើយ តបនឹងការស្នើសុំបង់តែការប្រាក់ថា ការបង់បែបនេះគឺខាតទាំងស្រុងដល់អ្នកខ្ចីប្រាក់ ដោយសារតែប្រាក់ដើមគឺនៅដដែល ។ មាន ករណីមួយដែល អ្នកខ្ចីសម្រេចចិត្តខ្ចីប្រាក់ពីអ្នកចងការឯកជន ដើម្បីយកទៅបង់សងទាំងដើមទាំងការប្រាក់ ។

### មតិយោបល់ផ្សេងៗ

- សមាជិកសហគមន៍មានអារម្មណ៍ថា កម្រិតបំណុលរបស់ពួកគាត់អាចនឹងកាន់តែកើនឡើងនាពេលខាងមុខ ។
- ពួកគាត់ សំណូមពរឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ ពន្យារពេលក្នុងការបង់សងទាំងប្រាក់ដើម និងការប្រាក់ រយៈពេល ៦ខែ ដើម្បីជួយសម្រាលបន្ទុកពួកគាត់ ។



# សហគមន៍ដកពរ

**៥០ គ្រួសារ**

**វិវាទដីធ្លីកើតឡើងនៅឆ្នាំ ២០១១**

ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ (ប៉ាន់ប្រមាណ)

**៩០%**

ទំហំកម្ចីជាមធ្យម

**១ ៥០០ ដុល្លារ**

គ្រឹះស្ថានដែលផ្តល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍

អេស៊ីលីដា • អេអឹមខេ • អម្រឹត • អិលអូអិលស៊ី • ប្រាសាក់ • ដាប់ប៊ែលយូប៊ី ហ្វាយនែន

## ព័ត៌មានអំពីសហគមន៍

គ្រួសារជាច្រើននៅសហគមន៍ដកពរ បានចូលមករស់នៅក្នុងភូមិតាំងពីមុនរបបខ្មែរក្រហម ។ សមាជិកសហគមន៍ បានចាប់ផ្តើមដាំដុះដំណាំ ពោត ដំឡូង ដំណាំហូបផ្លែ និងស្រូវ និងប្រមូលអនុផលព្រៃឈើដូចជា បន្លែ ត្រី ពី ព្រៃ និងអូរ នៅជិតនោះ ។ ប៉ុន្តែក្រុមហ៊ុនមួយដែលជាប់ពាក់ព័ន្ធនឹងលោក លី យ៉ុងផាត់ សមាជិកព្រឹទ្ធសភាគណបក្សកាន់អំណាច បានរំលោភយកដីធ្លីរបស់ពួកគាត់ និងបង្កឱ្យមានការបំពុល ចេញពីប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលធ្វើឱ្យអូរប្រើប្រាស់លែងបាន ។ ផលប៉ះពាល់នៃបញ្ហាដីធ្លីនេះ គួបផ្សំជាមួយបញ្ហាបំណុលធ្ងន់ធ្ងរ បានធ្វើឱ្យសមាជិកសហគមន៍ជាច្រើនចំណាកស្រុកដើម្បីរកការងារធ្វើ ។ ច្រើនជាង ៦០% នៃគ្រួសារសរុបមានសមាជិកគ្រួសារយ៉ាងតិចម្នាក់កំពុងធ្វើការនៅក្នុងរោងចក្រ ។

នៅឆ្នាំ ២០១១ ក្រុមហ៊ុន ភ្នំពេញ ស៊ូហ្គើរ បានចូលឈូសឆាយដីសហគមន៍ និងបំផ្លាញដំណាំរបស់ពលរដ្ឋ ។ ពលរដ្ឋភាគច្រើន បានបាត់បង់ដីស្រែចម្ការពី ១ ទៅ ៥ ហិកតា ទៅក្រុមហ៊ុន ហើយភាគច្រើននៃដីសហគមន៍នៅជិតអូរ ដែលអ្នកភូមិបានប្រើប្រាស់ដើម្បីប្រមូលអនុផលព្រៃឈើ ត្រូវបានបំពុលយ៉ាងខ្លាំង ។ តាំងពីពេលនោះមក សមាជិកសហគមន៍បានធ្វើការតស៊ូមតិ តាមរយៈអាជ្ញាធរមូលដ្ឋាន ព្រឹទ្ធសភានិងរដ្ឋសភា និងក្រសួងមួយចំនួន ក៏ដូចជាអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីស្វែងរកយុត្តិធម៌ និងសំណងសមរម្យ ។ ទោះបីជាមានការសន្យាជាច្រើនក្នុងការដោះស្រាយបញ្ហាឱ្យពួកគាត់ ប៉ុន្តែនៅតែមិនទាន់មានដំណោះស្រាយនៅឡើយ ។

### ប្រភពនៃប្រាក់ចំណូល

កសិកម្មដាំដុះ • កម្មករស៊ីឈ្នួល • កម្មករ-កម្មការិនីកាត់ដេរ • ចំណាកស្រុក • កម្មករសំណង់ • ចិញ្ចឹមសត្វ

### ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

បាត់បង់ប្រាក់ចំណូល • ផលប៉ះពាល់បរិស្ថាន • ចំណាកស្រុក • ពលកម្មកុមារ • បំណុលច្រើនជាងមុន

### បញ្ហាដែលមិនទាន់មានដំណោះស្រាយ

គ្មានការផ្តល់សំណង

## បំណុលមីក្រូហិរញ្ញវត្ថុ

សមាជិកសហគមន៍ បាននិយាយថាកម្រិតបំណុលនៅក្នុងភូមិគឺ “ច្រើនលើសលុប” និងប្រមាណ ៩០% នៃគ្រួសារសរុបបានខ្ចីកម្ចីឥណទានខ្នាតតូច ។ អ្នកខ្ចីបាននិយាយថា ពួកគេមានអារម្មណ៍ថាមានបន្ទុកនៃបំណុលនេះ និងការរងសម្ពាធខ្លាំងពីមន្ត្រីឥណទាន ដែលបង្ហាញឱ្យឃើញជាក់ស្តែងនូវការលក់ដីដោយសារបំណុល ចំណាកស្រុក ពលកម្មកុមារ និងការអនុវត្តបែបកេងចំណេញរបស់មន្ត្រីឥណទាន ។ អ្នកខ្ចីភាគច្រើន មិនអាចអាន ឬសរសេរអក្សរទេ និងមិនបានយល់ច្បាស់លាស់អំពី គោលការណ៍ និង លក្ខខណ្ឌនៃប្រាក់កម្ចីទាំងនេះឡើយ ។ អំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩ មន្ត្រីឥណទាន មិនបានផ្តល់ជម្រើសនៃការរៀបចំឥណទានឡើងវិញ ឬ ការពន្យារពេលបង់សងទេ ។ ករណីខ្លះ មន្ត្រីឥណទានបានប្រាប់អ្នកខ្ចីប្រាក់ថា ការរៀបចំឥណទានឡើងវិញនឹងបង្កើនបន្ទុកបំណុលសម្រាប់ពួកគេ និងមិនមានប្រយោជន៍ទេ ។

### សម្រង់ពាក្យសម្ដីពីប្រជាពលរដ្ឋសហគមន៍

“មន្ត្រីឥណទានបាននិយាយទៅកាន់អ្នកខ្ចីប្រាក់ម្នាក់ថា មានអីប៉ុន្មាន(ប្លង់ដី) ដាក់ទាំងអស់ទៅ គេខ្លាចយើងទៅខ្ចីកន្លែងផ្សេង’”

“ដោយសារមានសម្ពាធហើយ បើអត់មានសម្ពាធគឺអត់លក់ដីទេ”

“ខ្ញុំឃើញ(លក្ខខណ្ឌ) ពេលអានទៅគួរឱ្យខ្លាច ធ្លាប់មើលអានម្តងដែរហ្នឹង លក្ខខណ្ឌគេហ្នឹង”

“យើងបង់ផ្តាច់ហើយ អាប្លង់យើងហ្នឹងក៏មិនងាយឱ្យដែរ គេចង់ទុកឱ្យយើងខ្ចីបន្តទៀត”

“ពេលយើងរកអីបង់អត់បាន យើងទៅខ្ចីឯកជន ដល់អ៊ីចឹង យើងខ្ចីពីនេះផង ពីនោះផង ការប្រាក់កាន់តែច្រើន”

“ខំប្រឹងធ្វើការគ្មានបានសម្រាក ទោះឈឺក៏ដោយ ។ ពេលយើងមិនជំពាក់គេ យើងអាចគេងសម្រាកបានស្រួលពេលយើងឈឺ តែឥឡូវយើងអត់មានពេលសម្រាកទេ ទោះឈឺក៏ដោយ”

“ពេលខ្ញុំឃើញ អ្នកដែលគេបង់អត់ទាន់ ហើយមន្ត្រីឥណទានច្រើន មកទារលុយអ៊ីចឹង ខ្ញុំខ្លាចថាថ្ងៃមុខទៅ អ៊ីចឹងដែរ”

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

ធ្វើកសិកម្ម • សាងសង់ផ្ទះ • ធ្វើអាជីវកម្ម • ទិញដី • ការសិក្សាកូន • ព្យាបាលជំងឺ • សងបំណុលផ្សេងទៀត

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

ការវាយតម្លៃលើប្រាក់ចំណូល • ពិនិត្យមើលប័ណ្ណកម្មសិទ្ធិដីធ្លី និងតម្លៃ • មន្ត្រីឥណទានស្នើឱ្យដាក់ប្លង់ដីទាំងអស់

- បន្ទាប់ពីអ្នកខ្ចីបង់ផ្តាច់កម្ចីរួច ពេលខ្លះមន្ត្រីឥណទានរក្សាទុកប្លង់ដីលើសពីធម្មតា ដើម្បីជាសម្ពាធដល់អ្នកខ្ចី ឱ្យខ្ចីកម្ចីម្តងទៀត ។

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទាន បានចុះតាមផ្ទះរបស់អ្នកខ្ចី ដើម្បីស្នើផ្តល់កម្ចី ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និង គោលការណ៍នៃកម្ចីដែរឬទេ?

- អ្នកខ្ចីភាគច្រើន មិនអាចអាន ឬសរសេរអក្សរទេ និងពឹងលើមន្ត្រីឥណទាន ដើម្បីពន្យល់ពួកគាត់អំពីលក្ខខណ្ឌនៃកម្ចី ។ មិនមានករណី ដែលត្រូវបានរាយការណ៍ថា មន្ត្រីឥណទានបោកបញ្ឆោតអ្នកខ្ចី នៅពេលដែលផ្តល់ប្រាក់កម្ចីឡើយ ។

> “ពឹងលើអ្នកធ្វើ (មន្ត្រីឥណទាន) មិនដឹងថាគេមានកិច្ចសន្យាអីខ្លះ មិនដឹងទេ គេឱ្យផ្តិតមេដៃ ដឹងតែផ្តិត”

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការប្រមូលឥណទានដោយរំលោភបំពាន • ការរក្សាទុកប័ណ្ណកម្មសិទ្ធិដីធ្លីបន្ទាប់ពីបង់សងរួច • ការដាក់សម្ពាធឱ្យលក់ដី • ការផ្តល់កម្ចីឥណទានបែបកេងចំណេញ

- បើអ្នកខ្ចីយឺតបង់សង មន្ត្រីឥណទាន៣ឬ៤នាក់នឹងមកផ្ទះគាត់ ។
- អ្នកខ្ចីម្នាក់ផ្លាស់ប្តូរការងារ ដូច្នេះថ្ងៃបើកប្រាក់បៀវត្សរ៍បានប្តូរទៅក្រោយថ្ងៃ ដែលគាត់ត្រូវបង់សងបំណុលមីក្រូហិរញ្ញវត្ថុ ។ គាត់បានស្នើសុំផ្លាស់ប្តូរថ្ងៃបង់ប្រាក់ ទៅក្រោយថ្ងៃដែលគាត់បើកប្រាក់បៀវត្សរ៍ ប៉ុន្តែមន្ត្រីឥណទានបានបដិសេធ ។ ក្រោយមកគាត់បានបង់យឺត ០៣ ខែជាប់គ្នា មន្ត្រីឥណទានបានប្រាប់ឱ្យគាត់លក់ដី ។

### ផលវិបាកនៃបំណុល

ធ្វើការបន្ថែម • ខ្ចីប្រាក់ពីអ្នកចងការឯកជន • ពលកម្មកុមារ • កុមារបោះបង់ការសិក្សា • កាត់បន្ថយអាហារបរិភោគ • ភាពតានតឹងក្នុងគ្រួសារ • លក់ដី • ចំណាកស្រុក • លក់ទ្រព្យសម្បត្តិផ្សេងៗ

- ប្រហែល ១០គ្រួសារ បានលក់ដីដើម្បីសងបំណុល និង២គ្រួសារទៀត គ្រោងនឹងលក់ដីដើម្បីសងបំណុលដែរ ។
- វាមិនចម្លែកពេកទេ ដែលកុមារអាយុ ១៣ ទៅ ១៥ឆ្នាំត្រូវឈប់សិក្សា ដើម្បីធ្វើការជួយសងបំណុល ។ តាមការប៉ាន់ស្មានច្រើនជាង ២០% នៃគ្រួសារសរុប មានកូនបោះបង់ការសិក្សាដើម្បីធ្វើការជួយដោះបំណុល ។
- សមាជិកសហគមន៍រាប់សិបនាក់ បានចំណាកស្រុកទៅធ្វើការនៅរាជធានីភ្នំពេញ និង ខេត្តដទៃទៀត ដើម្បីដោះបំណុល ។

### ការប៉ះពាល់ផ្លូវចិត្ត

ភ័យខ្លាច • សម្ពាធ • សោកស្តាយ • អៀនខ្មាស • ព្រួយបារម្ភ

- ការគ្មានលទ្ធភាពបញ្ជូនកូនទៅសាលារៀន ដោយសារបញ្ហាបំណុល ជាប្រភពចម្បងនៃភាពតានតឹងផ្លូវចិត្ត ។

> “សម្ពាធទី១ គេ(មន្ត្រីឥណទាន) ត្រូវការកំណត់របស់គេថា ខែថ្ងៃទីប៉ុន្មានត្រូវបង់ គេពិន័យចេះៗ ។ អ៊ីចឹងដល់អ្នកខ្ចី រកដោះស្រាយលែងចេញហើយ គេដាក់សម្ពាធខ្លាំងរហូត ប្រាប់ថា "បងឯង! បើសិនអត់មានប្រាក់បង់ឱ្យខ្ញុំ ការប្រាក់ឡើង មានលទ្ធភាពបង់អត់ បើអត់នឹងចាត់វិធានការខាងធនាគារ" ដល់ចឹងគ្នាភ័យ! រកដោះស្រាយលែងបាន ក៏អំពាវនាវលក់របស់ មិនថាដី មិនថាអីឱ្យតែបានឱ្យគេ ។”

## អំឡុងពេល ជំងឺកូវីដ១៩

### ការប្រែប្រួលនៃប្រាក់ចំណូល

ប្រាក់ចំណូលធ្លាក់ចុះ អំឡុងពេលជំងឺកូវីដ១៩

- កម្មករ កម្មការិនីរោងចក្រជាច្រើន ត្រូវបានកាត់បន្ថយម៉ោងធ្វើការ ឬ ការងារត្រូវបានបាត់បង់ទាំងស្រុង ។ តម្លៃកសិផលធ្លាក់ថ្លៃ និងកម្មករស៊ីឈ្នួល មិនមានការងារច្រើនដូចមុនទេ ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានមិនបានស្នើផ្តល់រៀបចំឥណទានឡើងវិញ • មន្ត្រីឥណទាននិយាយថាការរៀបចំឥណទានឡើងវិញគឺគ្មានប្រយោជន៍

- មិនមានសមាជិកសហគមន៍ណាម្នាក់ទទួលបានព័ត៌មានអំពីការរៀបចំឥណទានឡើងវិញពីមន្ត្រីឥណទានឡើយ ។
- មន្ត្រីឥណទានឆ្លើយតបទៅអ្នកខ្ចី ដែលស្នើសុំរៀបចំឥណទានឡើងវិញថា ការធ្វើបែបនេះមិនជួយអ្វីទេដោយសារ "បើបង់តែការប្រាក់ចឹង ប្រាក់ដើមនៅដដែល ចឹងការសងនឹងកាន់តែយូរ" ។
- អំឡុងពេលជំងឺកូវីដ១៩ មន្ត្រីឥណទានជាច្រើន មិនបានផាកពិន័យចំពោះការបង់សងយឺតនោះទេ ។

### មតិយោបល់ផ្សេងៗ

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគិតកម្រៃ បើអ្នកខ្ចីចង់បង់សងផ្តាច់កម្ចីឥណទានរបស់ពួកគេមុនកាលកំណត់ ។ នេះមិនយុត្តិធម៌ទេ ។
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តែងតែទាមទារឱ្យមានទ្រព្យធានា ប៉ុន្តែអ្នកចងការឯកជន វាយតម្លៃអ្នកខ្ចីប្រាក់ផ្អែកលើទំនុកចិត្ត និងលទ្ធភាពនៃការបង់សងមកវិញ ដូច្នេះប្រាក់កម្ចីបែបនេះគឺងាយទទួលបានជាង ។
- សមាជិកសហគមន៍បានស្នើសុំឱ្យអង្គការក្រៅរដ្ឋាភិបាល សិក្សាបន្ថែមអំពីកម្ចីមីក្រូហិរញ្ញវត្ថុ និងចែករំលែកព័ត៌មាននេះជាមួយសមាជិកសហគមន៍ ។



# សហគមន៍ជីខក្រោម

**១៧៥ គ្រួសារ**
**វិវាទដីធ្លីកើតឡើងនៅឆ្នាំ ២០០៦**

ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ (ប៉ាន់ប្រមាណ)

**ច្រើនជាង ៨០%**

ទំហំកម្ចីជាមធ្យម

**៥.០០០ ដុល្លារ**

គ្រឹះស្ថានដែលផ្តល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍

អេស៊ីលីដា • អេអឹមខេ • អេអឹមខេ • ហត្ថា • និវន្ត • ប្រាសាក់ • ស្ថាបនា • ដាប់ប៊លយូប៊ី ហ្វាយណាន់

## ព័ត៌មានអំពីសហគមន៍

សហគមន៍ជីខក្រោម មានប្រជាពលរដ្ឋមកពីភូមិចំនួន ៦ ផ្សេងគ្នា ក្នុងស្រុកចំនួន ២ នៃខេត្តកោះកុង ។ ពលរដ្ឋទាំងនេះ ធ្លាប់ពឹងផ្អែកលើ បរេចាប់ត្រី និងដាំដុះដំណាំ ដើម្បីបរិភោគក្នុងគ្រួសារ និងលក់យកកម្រៃ ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ បរេចាប់ត្រី មានការធ្លាក់ចុះយ៉ាងខ្លាំង ហើយការប្រែប្រួលអាកាសធាតុ បានរំខានដល់ការធ្វើកសិកម្មបែបប្រពៃណី ដែលបានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ ជីវភាពរស់នៅរបស់ពួកគាត់ ។ ប្រជាពលរដ្ឋច្រើនជាង ៦០% នៃគ្រួសារសរុប ពឹងផ្អែកលើសមាជិកគ្រួសារយ៉ាងតិចម្នាក់ ដែលចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ និងបណ្តាខេត្តនានា ។

នៅឆ្នាំ ២០០៦ ក្រុមហ៊ុនកោះកុងស៊ូហ្គើរ ដែលជាប់ពាក់ព័ន្ធនឹងលោក លី យ៉ុងផាត់ សមាជិកព្រឹទ្ធសភា បានចាប់ផ្តើមឈូសឆាយដីចម្ការ និងផ្ទះសមាជិកសហគមន៍ ដែលដីមួយចំនួនមានការដាំដុះរួចទៅហើយ ។ ការបាត់បង់ដីធ្លី នាំឱ្យប្រាក់ចំណូលគ្រួសារធ្លាក់ចុះយ៉ាងគំហុក កុមារបោះបង់ការសិក្សា អំពើហិង្សាក្នុងគ្រួសារកើនឡើង និងការប៉ះពាល់ផ្លូវចិត្ត ។ បន្ទាប់ពីចាប់ផ្តើមតស៊ូមតិជាសហគមន៍ក្នុងឆ្នាំ ២០០៧ ពួកគាត់បានបន្តតស៊ូមតិ និងតវ៉ារហូតដល់ឆ្នាំ ២០១៧ ជាពេលដែលក្រុមហ៊ុនព្រមព្រៀងផ្តល់សំណង ២៥០០ ដុល្លារ និងផ្តល់ដីចំនួន ០៣ ហិកតា ក្នុងមួយគ្រួសារ នៅឆ្នាំ ២០១៨ ។ ដីនោះត្រូវការឈូសឆាយសម្អាត ដែលតម្រូវឱ្យចំណាយប្រាក់បន្ថែម ។ អ្នកភូមិរាប់សិបនាក់ មានវិវាទដីធ្លីផ្សេងទៀតជាមួយ ឧកញ៉ា ហេង ហ៊ុយ ក្នុងឆ្នាំ ២០០៩ ។ ពួកគាត់បារម្ភពីសុវត្ថិភាពដីធ្លី ដោយសារដីលំនៅឋានរបស់ពួកគាត់មិនទាន់ទទួលបានប្លង់រឹង។

## ប្រភពនៃប្រាក់ចំណូល

កសិកម្មដាំដុះ • នេសាទ • ចិញ្ចឹមសត្វ • ចំណាកស្រុក • កម្មករសំណង់ • កម្មករ-កម្មការិនីកាត់ដេរ • កម្មករស៊ីឈ្នួល

## ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

ការបាត់បង់ប្រាក់ចំណូល • កុមារបោះបង់ការសិក្សា • បញ្ហាសុខភាពផ្លូវចិត្ត • អំពើហិង្សាលើស្ត្រីសកម្មជនដីធ្លី • ការចាប់ខ្លួន • ចំណាកស្រុក • ការធ្វើទុក្ខបុកម្នេញតាមផ្លូវច្បាប់

## បញ្ហាដែលមិនទាន់មានដំណោះស្រាយ

កង្វះហេដ្ឋារចនាសម្ព័ន្ធ

## បំណុលមីក្រូហិរញ្ញវត្ថុ

ច្រើនជាង ៨០% នៃគ្រួសារសរុប ត្រូវបានប៉ាន់ប្រមាណថា ជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ ដោយគ្រួសារជាច្រើនខ្ចីប្រាក់ពីអ្នកចងការឯកជនមិនផ្លូវការ ។ ប្រហែលពាក់កណ្តាល នៃចំនួនគ្រួសារសរុប បានលក់ដីរបស់ពួកគាត់ ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ ។ ដីនេះត្រូវបានផ្តល់ឱ្យអ្នកភូមិ ជាសំណង ដើម្បីដោះស្រាយវិវាទដីធ្លី ។ ចំនួន "ច្រើនលើសលុប" នៃបំណុលនៅក្នុងសហគមន៍ បានធ្វើឱ្យអ្នកភូមិធ្វើការលើសកំណត់ ធ្វើការទាំងយប់ដោយគ្មានពេលសម្រាក ។ ពួកគាត់ត្រូវកាត់បន្ថយអាហារបរិភោគ ដើម្បីសន្សំទុកសម្រាប់សង ឬខ្ចីប្រាក់បន្ថែមដើម្បីសងបំណុលចាស់ ។ អ្នកភូមិបាននិយាយថា "ភាពភ័យខ្លាច" បង្កដោយមន្ត្រីឥណទាននៅក្នុងសហគមន៍ បណ្តាលឱ្យក្មេងៗដែលមានអាយុតិចបំផុតត្រឹម ១២ ឆ្នាំ បានឈប់ពីការសិក្សា និងត្រូវធ្វើការ ដើម្បីជួយគ្រួសារសងបំណុល ។

### សម្រង់ពាក្យសម្តីពីប្រជាពលរដ្ឋសហគមន៍

"ខ្ញុំភ័យ ពេលឃើញគេ (មន្ត្រីឥណទាន) មកដល់ផ្ទះចឹង ខ្លាចគេរឹបអូសដី"

"ពេលគេទៅសុំពន្យារពេលបង់យឺត ៧ថ្ងៃ មន្ត្រីឥណទានប្រាប់ថាបានតែបើបង់យឺតហួសខែ គេនឹងលក់ឡៃឡុងដីហើយ។"

"កូនខ្ញុំឈប់រៀនពីរបីនាក់ សុទ្ធតែអាយុ១៤ ១៥ ១៦ឆ្នាំ ទៅជួយលក់គុយទាវគេនៅភ្នំពេញ យកលុយផ្ញើសងគេ។"

"ខ្លាចកូនឈឺ អត់បានធ្វើការអត់អីសងគេ"

"ឮតែពន្យារពេលសងៗ ប៉ុន្តែពេលគេទៅសួរគេថាអត់មានផង។"

"ពីមុនមកយើងមានកូនធ្វើការដល់កូរ៉េហ្នឹងទៅ កូនអត់មានការងារធ្វើ យើងអត់មានលុយបង់ឱ្យគេ ចេះតែភ័យ ចឹងរកលុយឯកជនទៅបង់អង្គការ ខ្លាចគេរឹបអូសប្លង់។"

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

ធ្វើកសិកម្ម • សាងសង់ផ្ទះ • ប្រកបអាជីវកម្ម • ទិញម៉ូតូ • ការសិក្សាកូន • ឈូសឆាយដី • ព្យាបាលជំងឺ • សងបំណុលផ្សេងទៀត

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

វាយតម្លៃលើប្រាក់ចំណូល • ពិនិត្យមើលប័ណ្ណកម្មសិទ្ធិដីធ្លីនិងតម្លៃដី • មន្ត្រីឥណទានមួយចំនួនក្លែងបន្លំ "គោលបំណងនៃកម្ចី"

- អ្នកខ្ចីមិនអាចទទួលបានកម្ចីផ្ទាល់ខ្លួន ដោយសារគ្មានប័ណ្ណកម្មសិទ្ធិដីធ្លី ។ តម្លៃដីត្រូវខ្ពស់ជាងទំហំកម្ចី យ៉ាងតិចពីរដង។
- ករណីមួយ អ្នកខ្ចីបានប្រាប់ទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថា គាត់យកកម្ចីឥណទាន ដើម្បីទៅទិញម្ហូបអាហារសម្រាប់បរិភោគ និងគាត់និយាយថា មិនអីទេឱ្យតែគាត់មានលទ្ធភាពបង់សងវិញ ។

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទាន បានចុះតាមផ្ទះរបស់អ្នកខ្ចី ដើម្បីស្នើផ្តល់កម្ចី ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និង គោលការណ៍នៃកម្ចីដែរឬទេ?

- អ្នកខ្ចីភាគច្រើន មិនអាចអាន ឬ សរសេរអក្សរ និងពឹងលើមន្ត្រីឥណទាន ឱ្យពន្យល់ពួកគាត់អំពី លក្ខខណ្ឌនៃកម្ចី ។

> "ទៅរកខ្ចីឯណាក៏គេអត់ឱ្យខ្ចីដែរ ខ្ញុំអត់មានប្លង់។"

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការប្រមូលឥណទានដោយរំលោភបំពាន • ការផ្តល់កម្ចីឥណទានបែបកេងចំណេញ • ការរក្សាទុកប័ណ្ណកម្មសិទ្ធិដីធ្លីក្រោយទូទាត់សងរួច • ការដាក់សម្ពាធឱ្យលក់ដី

- មន្ត្រីឥណទានព្រមានអ្នកខ្ចីថា ដីពួកគាត់នឹងត្រូវដាក់លក់ដីក្នុងតម្លៃទាបជាងទីផ្សារ បើពួកគាត់គ្មានលទ្ធភាពសងកម្ចីវិញទេ ។
- ករណីមួយ ក្រោយអ្នកខ្ចីបង់ផ្តាច់រួចមួយខែ ទើបទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី ហើយអ្នកខ្ចីត្រូវបានជំរុញឱ្យខ្ចីកម្ចីថ្មីទៀត ។

### ផលវិបាកនៃបំណុល

ធ្វើការបន្ថែម • ខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ • ខ្ចីប្រាក់ពីអ្នកចងការឯកជន • ពលកម្មកុមារ • កុមារបោះបង់ការសិក្សា • កាត់បន្ថយអាហារបរិភោគ • ភាពតានតឹងក្នុងគ្រួសារ • ការលក់ដី • ចំណាកស្រុក • លក់ទ្រព្យសម្បត្តិផ្សេងៗ • បញ្ហាជំណេក

- សមាជិកគ្រួសារមួយចំនួន បានជាប់វល់នឹងការតស៊ូមតិលើបញ្ហាសិទ្ធិដីធ្លី និងគ្មានលទ្ធភាពសងបំណុលទេ ហើយពួកគាត់ជាច្រើនបានទៅខ្ចីប្រាក់បន្ថែម ដើម្បីសងបំណុល ។
- អ្នកខ្ចីមួយចំនួន បានឱ្យដឹងថា ការកាត់បន្ថយចំណាយពាក់កណ្តាលលើថ្លៃអាហារ អាចជួយពួកគាត់ក្នុងការសងបំណុល ។
- អ្នកខ្ចីភាគច្រើនក្នុងសហគមន៍ជាស្ត្រី ហើយជីវភាពពួកគាត់កាន់តែពិបាកជាងមុនពេលដែលពួកគាត់ខ្ចីកម្ចីពីមីក្រូហិរញ្ញវត្ថុ ។

### ការប៉ះពាល់ផ្លូវចិត្ត

ភ័យខ្លាច • សម្ពាធ • អៀនខ្មាស • ព្រួយបារម្ភ

- បំណុលមីក្រូហិរញ្ញវត្ថុ នាំឱ្យមានភាពតានតឹងដល់សហគមន៍ ហើយគ្រួសារមួយចំនួនបានបែកបាក់គ្នា ដោយសារមួយផ្នែកនៃភាពតានតឹងនៃកម្ចីមីក្រូហិរញ្ញវត្ថុ ។
- នេះប៉ះពាល់ខ្លាំងទៅលើស្ត្រី ដែលជាធម្មតាពួកគាត់ជាអ្នកខ្ចីកម្ចីឥណទាននៅក្នុងគ្រួសារ ។

> "ទោះជាគាត់ឈឺក៏ដោយ គ្រុនក៏ដោយ ក៏គាត់ត្រូវតែធ្វើការដែរ ព្រោះដល់ថ្ងៃបង់ធនាគារ"

## អំឡុងពេល ជំងឺកូវីដ១៩

### ការប្រែប្រួលនៃប្រាក់ចំណូល

ប្រាក់ចំណូលធ្លាក់ចុះ អំឡុងពេលជំងឺកូវីដ១៩

- តម្លៃគ្រាប់ស្វាយចន្ទី និងស្វាយធ្លាក់ថ្លៃខ្លាំង ។
- បរិមាណត្រីបានថយចុះ និងជារឿយៗ អ្នកនេសាទមិនអាចចាប់ត្រីបានច្រើនសម្រាប់លក់នោះទេ បានត្រឹមបរិភោគប៉ុណ្ណោះ ។
- កម្មករកម្មការិនីរោងចក្រជាច្រើន ត្រូវបានព្យួរ ឬបញ្ឈប់ពីការងារ ហើយពលករចំណាកស្រុកជាច្រើននៅប្រទេសថៃ កំពុងកាត់បន្ថយអាហារបរិភោគ ឬត្រូវត្រឡប់មកស្រុកកំណើតវិញ ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានមិនបានស្នើផ្តល់រៀបចំឥណទានឡើងវិញ • មន្ត្រីឥណទានបដិសេធរៀបចំឥណទានឡើងវិញ • មន្ត្រីឥណទាននិយាយថា ការរៀបចំឥណទានឡើងវិញគឺគ្មានប្រយោជន៍

- គ្មានសមាជិកសហគមន៍ណាម្នាក់ទទួលបានព័ត៌មានពីការរៀបចំឥណទានឡើងវិញពីមន្ត្រីឥណទានឡើយ ។ អ្នកខ្លះបានដឹងតាមរយៈ បណ្តាញសង្គមហ្វេសប៊ុក ។
- មន្ត្រីឥណទានខ្លះនិយាយថា ការរៀបចំឥណទានឡើងវិញមិនអាចជួយអតិថិជនទេ ពីព្រោះបន្ទុកបំណុលរួម នឹងកើនឡើង ។

### មតិយោបល់ផ្សេងៗ

- ជីវភាពរស់នៅ បានធ្លាក់ចុះ ចាប់តាំងពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានចាប់ផ្តើមផ្តល់កម្ចីឥណទាន នៅក្នុងសហគមន៍។
- អ្នកចងការឯកជន ក៏ជាបញ្ហា និងសម្ពាធទៅលើអ្នកខ្ចីផងដែរ ។ ពួកគេយកការប្រាក់ថ្លៃ ជាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៉ុន្តែតម្រូវការថ្លៃសេវានិងឯកសារគឺតិចជាង ។
- សមាជិកសហគមន៍ស្នើសុំទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឱ្យឈប់បង្ខំសាក្សីដែលផ្តិតមេដៃក្នុងកិច្ចសន្យា សងប្រាក់ជំនួសអ្នកខ្ចីនៅពេលដែលអ្នកខ្ចីមិនអាចបង់សងបាន ។




# សហគមន៍ជីខលើ

២០០ គ្រួសារ

វិវាទដីធ្លីកើតឡើងនៅឆ្នាំ ២០០៦

ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ (ប៉ាន់ប្រមាណ)

៩០%

ទំហំកម្ចីជាមធ្យម

១ 000 ដុល្លារ

គ្រឹះស្ថានដែលផ្ដល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍

អេស៊ីលីដា • អេអឹមខេ • អម្រឹត • ហត្ថា • និរន្តន៍ • ប្រាសាក់ • ស្ថាបនា • ដាប់បែលយូប៊ីហ្វាយនែន • ចន្ទរះ

## ព័ត៌មានអំពីសហគមន៍

សហគមន៍ជីខលើ មានប្រជាពលរដ្ឋចំនួន ២០០គ្រួសារមកពី ៣ភូមិក្នុងស្រុកស្រែអំបិល ខេត្តកោះកុង ។ ប្រជាពលរដ្ឋក្នុង សហគមន៍នេះ ពឹងផ្អែកលើដីចម្ការ និងអាស្រ័យផលពីព្រៃឈើ ដើម្បីរកប្រាក់ចំណូល ។ ប៉ុន្តែចាប់តាំងពីវិវាទដីធ្លីកើតឡើង ជាពិសេសអំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩ ចំណូលគ្រួសារបានធ្លាក់ចុះជាខ្លាំង ។ អ្នកភូមិជាច្រើនបានធ្វើចំណាកស្រុក ក្រោយបាត់បង់ដីធ្លី ដើម្បីរកមធ្យោបាយដោះស្រាយការកើនឡើងនៃភាពជាប់ជំពាក់បំណុល ។

ក្នុងឆ្នាំ២០០៦ កម្មករក្រុមហ៊ុនស្ករអំពៅកោះកុង និងក្រុមហ៊ុនកោះកុងផ្លានថេហ្សិន ដែលជាប់ពាក់ព័ន្ធនឹងលោក លី យ៉ុងផាត់ សមាជិកព្រឹទ្ធសភាព បានវាយប្រហារសមាជិកសហគមន៍ ដែលកំពុងការពារដីធ្លីពួកគាត់ ។ កម្មករទាំងនោះបានបើកគ្រឿងចក្រឈូសឆាយដី និងគ្រឿងចក្រកាយដី ក្រោមការការពារពីសមត្ថកិច្ចមូលដ្ឋាន និងកងរាជអាវុធហត្ថផងដែរ ។ កងកម្លាំងចម្រុះជាច្រើនបានបំផ្លាញដីស្រែចម្ការប្រជាពលរដ្ឋ ក៏ដូចជាព្រៃសមូហភាព ។ ផ្ទះសម្បែងប្រហែលជា ១០ខ្នង ត្រូវបានដុតបំផ្លាញ និងផ្ទៃដីសហគមន៍ ប្រមាណជា ១ ៣៦៥,៧ ហិកតា ត្រូវបានក្រុមហ៊ុនឈូសឆាយ ។ ក្រៅពីការរំលោភយកដីធ្លី ក្រុមហ៊ុនបានបំពុលទឹកអូរដោយសារធាតុគីមី និងធនធានធម្មជាតិចាំបាច់មួយចំនួនត្រូវបានបាត់បង់ ។ សមាជិកសហគមន៍មួយចំនួនបានទទួលសំណងតិចតួច (សំណងភាគច្រើនជាដីចំនួន ១,៥ហិកតា) ហើយ២៤គ្រួសារទៀតមិនទាន់ទទួលបានដីធ្លីជាសំណងនៅឡើយ ។

## ប្រភពនៃប្រាក់ចំណូល

កសិកម្មដាំដុះ • ចិញ្ចឹមសត្វ • ប្រមូលអនុផលព្រៃឈើ • នេសាទ • កម្មករសំណង់ • ចំណាកស្រុក • កម្មករ-កម្មការិនីកាត់ដេរ

## ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

អំពើហិង្សាលើរូបរាងកាយ • ផ្ទះត្រូវបានដុត • បាត់បង់ប្រាក់ចំណូល • ចំណាកស្រុក • អំពើហិង្សាផ្លូវចិត្ត • កុមារបោះបង់ការសិក្សា • ប៉ះពាល់បរិស្ថាន

## បញ្ហាដែលមិនទាន់មានដំណោះស្រាយ

សំណងមិនពេញលេញ • កង្វះហេដ្ឋារចនាសម្ព័ន្ធ

## បំណុលមីក្រូហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានចូលមកក្នុងសហគមន៍ជីខលើ មិនយូរប៉ុន្មានបន្ទាប់ពីវិវាទដីធ្លីកើតឡើង និងបំណុលក្នុងសហគមន៍ចាប់ផ្ដើមកើនឡើងលឿនខ្លាំងនៅក្នុងឆ្នាំ ២០១៨ និង ២០១៩ ។ គ្រួសារប្រមាណជា ៩០% ជំពាក់កម្ចីឥណទានខ្នាតតូច និងប្រហែលជា ៥០ គ្រួសារ (២៥%)នៅក្នុងសហគមន៍ បានលក់ដីធ្លីរបស់ពួកគាត់ដើម្បីសងបំណុល ។ ជាទូទៅ មន្ត្រីឥណទានមិនបានបង្ហាញឥរិយាបថមិនសមរម្យទៅកាន់អ្នកខ្ចីក្នុងសហគមន៍ទេ ប៉ុន្តែអ្នកខ្ចីយល់ថា ប្រសិនបើគ្មានលទ្ធភាពសងបំណុល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនឹងរឹបអូសយកដីធ្លី និងផ្ទះរបស់ពួកគាត់ ។ ភាពភ័យខ្លាចនេះបានធ្វើឱ្យពួកគាត់ជាច្រើនបានលក់ដីសងបំណុល ។ តាមការប៉ាន់ស្មាន កុមារមិនទាន់គ្រប់អាយុប្រមាណជា ៨០នាក់ ដែលកុមារខ្លះអាយុត្រឹម ១៤ឆ្នាំ ត្រូវបោះបង់ការសិក្សា និងត្រូវធ្វើការដើម្បីសងបំណុល ។ ភាពតានតឹងផ្លូវចិត្ត និងផ្លូវកាយ គួបផ្សំនឹងការជំពាក់បំណុលធ្ងន់ធ្ងរបានធ្វើឱ្យស្ត្រីមេម៉ាយម្នាក់ ដែលមានកូនពីរនាក់បានស្លាប់ ដោយសារជំងឺ បន្ទាប់ពីជួបបញ្ហាតានតឹង និងសម្ពាធខ្លាំងមួយរយៈ ក្រោយពីគាត់គ្មានលទ្ធភាពសងបំណុលមីក្រូហិរញ្ញវត្ថុចំនួនពីរកម្ចី ។

### សម្រង់ពាក្យសម្ដីពីប្រជាពលរដ្ឋសហគមន៍

“ខ្ញុំមានអារម្មណ៍ថាពិបាកខ្លាំង ពេលសងគេមិនបានយើងត្រូវតែលក់ដីដើម្បីសង ហើយអ៊ីចឹងយើងលែងមានផ្ទះនៅទៀត”

“យើងអត់ដឹងសិទ្ធិខ្លួនឯងមានអីខ្លះ ពេលយើងអត់មានលទ្ធភាពសង”

“សហគមន៍របស់ខ្ញុំ មានផលវិបាកច្រើនណាស់ជាមួយបំណុល ។ ហើយក៏អត់មានវិធីណាដើម្បីកុំឱ្យខ្ចីទៀតដែរ”

“ខ្ញុំអត់ដែលឃើតទេ ដល់ខ្ញុំអត់អីសងចឹង ខ្ញុំខ្លាចថាគេនឹងមកផ្ទះខ្ញុំ អ៊ីចឹងយើងនឹងមានបញ្ហា អ៊ីចឹងខ្ញុំត្រូវលក់ដី ”

“គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនឹង គេមានលក្ខខណ្ឌច្រើន ចឹងវាដូចជាការគំរាមអ៊ីចឹង”

“អ្នកខ្ចីភាគច្រើនដឹងថាអាចនឹងបាត់បង់ដី បើសងគេមិនបាន តែអត់ដឹងពីសិទ្ធិទេ ”

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

កសិកម្ម • សាងសង់ផ្ទះ • ទិញម៉ូតូ • ការសិក្សាកូន • ឈូសឆាយដី • ព្យាបាលជំងឺ • សងបំណុលផ្សេងទៀត

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

មន្ត្រីឥណទានសួរនាំពីប័ណ្ណកម្មសិទ្ធិដីធ្លី ទ្រព្យសម្បត្តិ និងចំណូល

- សមាជិកសហគមន៍កត់សម្គាល់ឃើញថា ការខ្ចីកម្ចីឥណទានងាយស្រួលណាស់ ហើយមន្ត្រីឥណទានជួយឆ្លើយសំណួរទៀតផងប៉ុន្តែនៅពេលដែលអ្នកខ្ចីគ្មានលទ្ធភាពបង់សងមន្ត្រីឥណទានមិនបានផ្តល់ការប្រឹក្សាយោបល់ ឬជំបូន្មានពីរបៀបរកប្រាក់ទេ ។

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទាន បានចុះតាមផ្ទះរបស់អ្នកខ្ចី ដើម្បីស្នើផ្តល់កម្ចី ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និង គោលការណ៍នៃកម្ចីដែរឬទេ?

- អ្នកខ្ចីភាគច្រើន មិនអាចអាន ឬសរសេរអក្សរទេ និងពឹងលើមន្ត្រីឥណទានឱ្យពន្យល់ពួកគាត់អំពីលក្ខខណ្ឌនៃកម្ចី ។

> "យើងដឹងពីការប្រាក់ និងលក្ខខណ្ឌ តាមមន្ត្រីឥណទាន ។ គេនិយាយថាបើអត់បង់ប្រាក់ គេនឹងរឹបអូសយកទ្រព្យបញ្ចាំ ឬអ្នកធានាត្រូវសងជំនួស "

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការដាក់សម្ពាធឱ្យលក់ដី • គំរាមកំហែង

- មន្ត្រីឥណទានមួយចំនួនបានគំរាមកំហែង ដើម្បីរឹបអូស និងលក់ដីនៅពេលអ្នកខ្ចីយឺតយ៉ាវក្នុងការបង់សង ។

### ផលវិបាកនៃបំណុល

ខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ • ខ្ចីប្រាក់ពីអ្នកចងការឯកជន • ពលកម្មកុមារ • កុមារបោះបង់ការសិក្សា • កាត់បន្ថយអាហារបរិភោគ • ភាពតានតឹងក្នុងគ្រួសារ • លក់ដី • ចំណាកស្រុក • បញ្ហាជំណោក

- ករណីខ្លះ ប្តីលើកឡើងថាពួកគាត់មិនបានដឹងថា ប្រពន្ធបានខ្ចីឥណទានទេ ទើបនាំឱ្យលែងលះគ្នា ឬមានបញ្ហារវាងប្តីប្រពន្ធ ។
- មានករណីមួយ ស្ត្រីមេម៉ាយដែលមានកូនពីរនាក់ កើតទុក្ខ និងភ័យខ្លាចជាខ្លាំង ដោយសារបំណុលមីក្រូហិរញ្ញវត្ថុច្រើនលើសលុបរបស់គាត់ ដែលនាំឱ្យគាត់ធ្លាក់ខ្លួនឈឺរហូតដល់ស្លាប់ ។
- ពលកម្មកុមារ គឺជាបញ្ហាចម្បងទីពីរ បន្ទាប់ពីការលក់ដីសងបំណុល ពាក់ព័ន្ធនឹងបំណុលមីក្រូហិរញ្ញវត្ថុនៅក្នុងសហគមន៍ ។

### ការប៉ះពាល់ផ្លូវចិត្ត

ភ័យខ្លាច • ព្រួយបារម្ភ • កើតទុក្ខ • មានសម្ពាធ

- អ្នកខ្ចីជាច្រើន ភ័យខ្លាចការស្តីបន្ទោសពីមន្ត្រីឥណទាន និងភ័យខ្លាចមានបំណុលច្រើនជាងនេះ ។
- អ្នកខ្ចីជាច្រើនបានឱ្យដឹងថា ពួកគាត់ភ័យខ្លាចមន្ត្រីឥណទានរឹបអូស យកដីធ្លីរបស់ពួកគាត់ ដោយសារការគំរាមចំៗថាពួកគេនឹងរឹបអូសយកទ្រព្យសម្បត្តិ ប្រសិនបើយឺតក្នុងការបង់សង ។
- អ្នកខ្ចីដែលបានធ្វើចំណាកស្រុកដើម្បីសងបំណុល ពេលខ្លះកើតទុក្ខដែលត្រូវចាកចេញពីផ្ទះដើម្បីរកប្រាក់សងបំណុល ។

> "ខ្ញុំខ្លាចថា បើខ្ញុំអត់មានលុយសងគេ គេនឹងមករកខ្ញុំហើយស្តីឱ្យខ្ញុំ"

## អំឡុងពេល ជំងឺកូវីដ១៩

### ការប្រែប្រួលនៃប្រាក់ចំណូល

ប្រាក់ចំណូលធ្លាក់ចុះ អំឡុងពេលជំងឺកូវីដ១៩

- តម្លៃកសិផលធ្លាក់ចុះយ៉ាងតិច ៥០% បើធៀបនឹងឆ្នាំ ២០១៩ ។
- អ្នកចំណាកស្រុកត្រូវកាត់បន្ថយម៉ោងធ្វើការ ឬត្រូវវិលត្រឡប់ពីប្រទេសថៃ និងពីខេត្តផ្សេងៗវិញ ។
- ប្រជាពលរដ្ឋជាច្រើន ប្រមូលអនុផលព្រៃឈើ ដូច្នេះ បរិមាណនៃការប្រមូលអនុផលយកទៅលក់គឺកាន់តែតិចសម្រាប់គ្រួសារ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានមិនបានស្នើផ្តល់រៀបចំឥណទានឡើងវិញ • មិនមានព័ត៌មានពីអ្នកខ្ចីដែលទទួលបានការរៀបចំឥណទានឡើងវិញ

- សមាជិកជិកសហគមន៍ម្នាក់គត់ ដែលបានឮពីសាពចររបស់ធនាគារជាតិនៃកម្ពុជា ស្តីពីការរៀបចំឥណទានឡើងវិញ ។
- សមាជិកសហគមន៍ប្រមាណ ១៧នាក់ បានលក់ដី អំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩ ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ ។

### មតិយោបល់ផ្សេងៗ

- សមាជិកសហគមន៍បានស្នើឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កុំផាកពិន័យ ចំពោះប្រជាពលរដ្ឋដែលយឺតក្នុងការបង់សង២ ឬ៣ថ្ងៃ និងផ្តល់ការយោគយល់ ។
- អំឡុងពេលរីករាលដាលជំងឺកូវីដ១៩ គួរពន្យារពេលសងចំនួន ៦ខែ ដល់អ្នកខ្ចីដែលត្រូវការជាចាំបាច់ ។
- អត្រាការប្រាក់គួរទាបជាងបច្ចុប្បន្ន ដែលមាន ១៨% ក្នុង១ឆ្នាំ ។
- កិច្ចសន្យា និងការវាយតម្លៃលើប្រាក់ចំណូលគួរពន្យល់ឱ្យបានច្បាស់លាស់ មុននឹងផ្តល់កម្ចី ។
- មន្ត្រីឥណទានគួរឈ្វេងយល់បន្ថែមលើអតិថិជន អំពីការប្រើប្រាស់កម្ចី និងដំណើរការអាជីកម្មរបស់ពួកគាត់ ។



# សហគមន៍តានួន

**៣៣ គ្រួសារ**

**វិវាទដីធ្លីកើតឡើងនៅឆ្នាំ ២០១០**

**ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ (ប៉ាន់ប្រមាណ)**

១០០%

**ទំហំកម្ចីជាមធ្យម**

៣.០០០ ដុល្លារ

**គ្រឹះស្ថានដែលផ្តល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍**

អេស៊ីលីដា • អេអឹមខេ • និរន្តរ • ប្រាសាក់

## ព័ត៌មានអំពីសហគមន៍

មុនឆ្នាំ២០១០ សមាជិកសហគមន៍តានួនជាច្រើន អាចបើកទ្វារផ្ទះមកមើលឃើញសមុទ្រ ។ បច្ចុប្បន្នសហគមន៍ត្រូវបានរុញច្រានឱ្យទៅរស់នៅ ចំងាយប្រមាណ ១៣គីឡូម៉ែត្រ ពីកំពង់ផែដែលពួកគាត់ចតទូកនេសាទ ដោយសារវិវាទដីធ្លី ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់អ្នកនេសាទនិងកសិករ នៅក្នុងភូមិ ។ ប្រជាពលរដ្ឋរាប់រយគ្រួសារនៅក្នុងខេត្ត បានរងផងប៉ះពាល់ពីគម្រោងទេសចរណ៍របស់ក្រុមហ៊ុនមួយ ក្នុងនោះមាន ៣៣គ្រួសារ បានបង្កើតជាសហគមន៍តានួន ។ នៅឆ្នាំ២០១០ ពួកគាត់បានសម្រេចចិត្តតស៊ូមតិជាសហគមន៍ នៅពេលការសន្យាមួយចំនួននៃការផ្តល់សំណងសមរម្យ ដោយរដ្ឋាភិបាល និងក្រុមហ៊ុន មិនត្រូវបានអនុវត្ត ។

ក្នុងឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ដីសម្បទាន ទំហំ ៣៦.០០០ហិកតា នៅតាមឆ្នេរសមុទ្រខេត្តកោះកុងឱ្យទៅក្រុមហ៊ុន យូញៀន ឌីវេឡុបមេន គ្រុប ដែលមានម្ចាស់ជាជនជាតិចិន ។ ការចរចានិងការសន្យាផ្តល់សំណងត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០០៩ ប៉ុន្តែបន្ទាប់ពីសហគមន៍តានួន ត្រូវបានផ្លាស់ទៅរស់នៅទីតាំងថ្មី ក្នុងឆ្នាំ២០១០ ការសន្យាមួយចំនួននោះ នៅមិនត្រូវបានអនុវត្តទេ ។ អ្នកភូមិត្រូវបានផ្លាស់ប្តូរទៅភូមិមួយ ដែលមានចម្ងាយប្រហែល ០៦គីឡូម៉ែត្រ ពីលំនៅឋានចាស់ ដោលគ្មានអគ្គិសនី ផ្លូវពិបាក គ្មានមធ្យោបាយទៅសមុទ្រ ដីគ្មានដីជាតិ ខ្វះប្រព័ន្ធធារាសាស្ត្រ និងគុណភាពផ្ទះសំណងមិនសូវល្អ បើធៀបនឹងអ្វីដែលបានសន្យា ។ សមាជិកសហគមន៍ខ្លះមិនបានទទួលសំណងជាប្រាក់ទេ ហើយសូម្បីតែអ្នកដែលទទួលបានសំណងនោះ ក៏មិនត្រូវបានផ្តល់នូវចំនួនទឹកប្រាក់ ឬសំណងដែលមានគុណភាព តាមការសន្យាដែរ ។

### ប្រភពនៃប្រាក់ចំណូល

នេសាទ • ចំណាកស្រុក • ការចិញ្ចឹមសត្វ • កម្លាំងសន្តិសុខ • កម្មករស៊ីឈ្នួល • កម្មករសំណង់ • ដុតធ្យូង

### ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

បាត់បង់ជីវភាពរស់នៅ • ចំណាកស្រុក

### បញ្ហាដែលមិនទាន់មានដំណោះស្រាយ

សំណងមិនសមរម្យ • ខ្វះហេដ្ឋារចនាសម្ព័ន្ធ

## បំណុលមីក្រូហិរញ្ញវត្ថុ

តាមការប៉ាន់ស្មានគ្រួសារប្រមាណ ១០០% នៅសហគមន៍តានួនជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ ដែលអ្នកខ្ចីជាច្រើនដាក់ប័ណ្ណកម្មសិទ្ធិដីធ្លីច្រើនជាទ្រព្យធានា ។ គ្មាននរណាម្នាក់ ទទួលបានព័ត៌មានពីហានិភ័យនៃកម្ចីឥណទានទេ ហើយបញ្ហាដូចជា ការធ្លាក់ចុះប្រាក់ចំណូល អំឡុងពេលបង់សងមិនត្រូវបានមន្ត្រីឥណទានអើពើឡើយ ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានចូលមកសហគមន៍ដំបូងក្នុងឆ្នាំ២០១០ បន្ទាប់ពីវិវាទដីធ្លីកើតឡើង ហើយចំនួនកម្ចីឥណទានបានកើនឡើងខ្លាំងនៅឆ្នាំ២០១៧ និង២០១៨ ។ មន្ត្រីឥណទានខ្លះបានគំរាមយកអ្នកខ្ចីទៅប៉ុស្តិ៍នគរបាល ឬជួបជាមួយមេឃុំ បើពួកគាត់យឺតក្នុងការបង់សងច្រើនថ្ងៃ ។ អ្នកខ្ចីជាច្រើនមានអារម្មណ៍ភ័យខ្លាចចំពោះការប្រឈមនឹងវិធានការផ្លូវច្បាប់ ឬការរឹបអូសយកដីធ្លីពួកគាត់ បើគ្មានលទ្ធភាពបង់សងកម្ចីបង់សងទេ ។ អ្នកខ្ចីមួយចំនួនប្រាប់ថាពួកគាត់បានកាត់បន្ថយអាហារបរិភោគ និងតានតឹងផ្លូវចិត្តខ្ពស់ដែលធ្វើឱ្យពួកគាត់ជួបបញ្ហាជំណោក និងភ័យខ្លាច ដោយសារមន្ត្រីឥណទានមកដល់ផ្ទះ ។ គ្រួសារខ្លះ ត្រូវលក់ផលនេសាទស្ទើរតែទាំងអស់ដែលពួកគាត់រកបាន ដើម្បីបង់សងបំណុល និងទុកបន្តិចបន្តួចប៉ុណ្ណោះសម្រាប់បរិភោគ ។ អ្នកខ្លះទៀតធ្វើចំណាកស្រុក លក់ទ្រព្យសម្បត្តិ ឬឱ្យកូនបោះបង់ការសិក្សា ។ ពួកគាត់ប្រហែល ៨ គ្រួសារបានលក់ដី ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ ។

### សម្រង់ពាក្យសម្តីពីប្រជាពលរដ្ឋសហគមន៍

“ទៅដល់គេសួររកប្លង់មុនគេបង្អស់ ”

“បើយើងអត់មានមុខរបរពិតប្រាកដ គេឱ្យដាក់ប្លង់ដីចំការថែមមួយទៀត។ ”

“កាបាត់បង់ត្រី និងខូចខាតឧបករណ៍នេសាទ ធ្វើឱ្យយើងបារម្ភចំពោះការបង់សងទៅវិញ មន្ត្រីឥណទានគេអត់ដឹងពីបញ្ហាហ្នឹងទេ គេដឹងតែដល់ខែគេមកប្រមូល។ ”

“មានអារម្មណ៍ខ្លាច! ខ្ញុំគ្មានប្រាក់សងគេ! ខ្ញុំខ្លាចពួកគេរឹបអូសដីធ្លីរបស់ខ្ញុំ បើខ្ញុំគ្មានប្រាក់សងគេ! ”

“គេឱ្យខ្ចី តែទាល់តែមានប្លង់ដាក់បញ្ចាំគេ ”

“ចាស់ មេម៉ាយ គេអត់ឱ្យធានាទៀត ”

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

សាងសង់ផ្ទះ • ធ្វើអាជីវកម្ម • ទិញទូក • ទិញម៉ូតូ • ទិញឧបករណ៍នេសាទ • ព្យាបាលជំងឺ • ចំណាកស្រុក • ជួសជុលផ្ទះ • សងបំណុលផ្សេងទៀត

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

មន្ត្រីឥណទានទាមទារប័ណ្ណកម្មសិទ្ធិដីធ្លី • កម្រិតអ្នកធានា • ការវាយតម្លៃប្រាក់ចំណូលប៉ុន្តែគ្មានការប្រឹក្សាពីហានិភ័យ

- ជាធម្មតា ស្ត្រីមេម៉ាយ និងមនុស្សចាស់ត្រូវបានបដិសេធមិនឱ្យធ្វើជាអ្នកធានាសម្រាប់កម្ចីមីក្រូហិរញ្ញវត្ថុទេ ។
- ប័ណ្ណកម្មសិទ្ធិដីធ្លី ត្រូវបានមើលឃើញថាជាលក្ខខណ្ឌសំខាន់បំផុតសម្រាប់សិទ្ធិទទួលបានកម្ចីមីក្រូហិរញ្ញវត្ថុ ។

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទាន បានចុះតាមផ្ទះរបស់អ្នកខ្ចី ដើម្បីស្នើផ្តល់កម្ចី ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និង គោលការណ៍នៃកម្ចីដែរឬទេ? ?

- អ្នកខ្ចីភាគច្រើន មិនអាចអាន ឬសរសេរអក្សរទេ និងពឹងលើមន្ត្រីឥណទានឱ្យពន្យល់ពួកគាត់អំពី លក្ខខណ្ឌនៃកម្ចី ។ ពួកគាត់ភាគច្រើនដឹងថា ពួកគាត់ត្រូវមានប័ណ្ណកម្មសិទ្ធិដីធ្លី និងមិនអាចយកកម្ចីលើសពី ៣ ឡើយ ។

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការប្រមូលឥណទានដោយរំលោភបំពាន • ការគំរាមកំហែង

- អ្នកខ្ចីបានប្រាប់ឱ្យដឹងថា មន្ត្រីឥណទានបានធ្វើទុក្ខបុកម្នេញ និងចោទពួកគាត់ថា ពិបាក ឬខ្ជិលច្រអូស និងបានគំរាមកំហែងដោយយកអាជ្ញាធរមូលដ្ឋាន ឬនគរបាលពាក់ព័ន្ធផងដែរ។

### ផលវិបាកនៃបំណុល

ខ្ចីប្រាក់ពីអ្នកចងការឯកជន • កុមារបោះបង់ការសិក្សា • កាត់បន្ថយអាហារបរិភោគ • ភាពតានតឹងក្នុងគ្រួសារ • ការលក់ដី • ចំណាកស្រុក • លក់ទ្រព្យសម្បត្តិផ្សេងៗ • បញ្ហាជំណេក

- ប្រហែល ០៨ គ្រួសារ បានលក់ដីដើម្បីសងបំណុល ។
- កុមារខ្លះ អាយុត្រឹម ១៤ឆ្នាំ ត្រូវបានបញ្ឈប់ពីការសិក្សា ដោយសារសម្ពាធហិរញ្ញវត្ថុដែលបណ្តាលមកពីបំណុល ។
- គ្រួសារមួយចំនួន កើនឡើងភាពតានតឹង និងការឈ្លោះប្រកែកគ្នាជាពាក្យសម្តី ដោយសារភាពតានតឹងផ្លូវចិត្តនៃបញ្ហាបំណុល ។

### ការប៉ះពាល់ផ្លូវចិត្ត

ភ័យខ្លាច • សម្ពាធ • សោកស្តាយ • ព្រួយបារម្ភ

- សមាជិកសហគមន៍ជាច្រើនភ័យខ្លាចចំពោះវិធានការផ្លូវច្បាប់ដែលបណ្តាលមកពីបំណុល ។
- អ្នកខ្ចីជាច្រើនក៏បានប្រាប់ឱ្យដឹងពីការភ័យខ្លាចចំពោះការរឹបអូសដីធ្លីដោយមន្ត្រីឥណទាន ដែលបានគំរាមច្បាស់ៗក្នុងការរឹបអូសទ្រព្យសម្បត្តិ ប្រសិនបើពួកគាត់យឺតយ៉ាវក្នុងការបង់សង ។
- អារម្មណ៍សោកស្តាយខ្លាំងចំពោះកុមារ ដែលត្រូវបោះបង់ការសិក្សា ឬទៅធ្វើការ ដោយសារផលវិបាកនៃបំណុល ។

> “មន្ត្រីឥណទាននិយាយថា! ខ្ញុំមិនខ្វល់ថារកលុយពីណាទេ ឱ្យតែមានលុយសងខ្ញុំ ”
>
> “គេនិយាយថា បើខ្ញុំមិនបង់ប្រាក់ទាន់ពេលទេ គេនឹងហៅខ្ញុំទៅប៉ុស្តិ៍ប៉ូលីស ឬឃុំ ”

## អំឡុងពេល ជំងឺកូវីដ១៩

### ការប្រែប្រួលនៃប្រាក់ចំណូល

ប្រាក់ចំណូលធ្លាក់ចុះ អំឡុងពេលជំងឺកូវីដ១៩

- តម្លៃផលនេសាទបាន ធ្លាក់ចុះ ហើយបរិមាណត្រីក៏ទាបជាងមុនដែរ ដែលជាហេតុនាំឱ្យប្រាក់ចំណូលបានធ្លាក់ចុះប្រមាណ ៨០% បើធៀបនឹងកម្រិតមុនពេលមានវិបត្តិជំងឺកូវីដ ១៩ ។
- ពលករចំណាកស្រុកត្រូវបានកាត់បន្ថយម៉ោងធ្វើការ ឬត្រូវវិលត្រឡប់ពីប្រទេសថៃវិញ ឬខេត្តផ្សេងទៀត ។
- យុវជនដែលធ្លាប់ធ្វើការនៅរោងចក្រពីមុន ឥឡូវពួកគេមកជាអ្នករើសអេតចាយនៅក្នុងភូមិ ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានមិនបានស្នើផ្តល់រៀបចំឥណទានឡើងវិញ • ការផាកពិន័យពេលបង់ប្រាក់យឺតនៅតែត្រូវបានអនុវត្តអំឡុងពេលកូវីដ ១៩

- សមាជិកសហគមន៍ខ្លះ បានដឹងពីសេចក្តីប្រកាសរបស់ធនាគារជាតិនៃកម្ពុជាទាក់ទងនឹងការរៀបចំឥណទានឡើងវិញ ប៉ុន្តែគ្មាននរណាម្នាក់ មានអារម្មណ៍ក្លាហានក្នុងការនិយាយជាមួយមន្ត្រីឥណទានរបស់ពួកគេអំពីបញ្ហានេះឡើយ ។

### មតិយោបល់ផ្សេងៗ

- បំណុលច្រើនលើសលុបគឺជាបញ្ហាធំមួយនៅក្នុងសហគមន៍ ហើយ អ្នកខ្ចីមួយចំនួនមិនអាចរកប្រាក់បានគ្រប់គ្រាន់ ដើម្បីសងមីក្រូហិរញ្ញវត្ថុឱ្យទាន់ពេលវេលាទេ ។
- សមាជិកសហគមន៍ស្នើសុំសំណងពីរាជរដ្ឋាភិបាល ដូចជាមានផ្លូវចូលទៅសមុទ្រ ។
- សមាជិកសហគមន៍ បានស្នើសុំឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជួយសម្រាល បន្ទុកបំណុល និងបញ្ឈប់ភាពតឹងរឹងអំឡុងពេលជំងឺកូវីដ ១៩ ជាពិសេសពន្យារពេលសង និងគ្មានការផាកពិន័យ ។

> “អំឡុងពេលផ្ទុះកូវីដ១៩! យើងលក់អីទាំងអស់ដែលយើងមាន ”



# សហគមន៍ដីធ្លីខេត្តប៉ៃលិន

១៤៧ គ្រួសារ
វិវាទដីធ្លីកើតឡើងនៅឆ្នាំ ២០០៦

ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ
(ប៉ាន់ប្រមាណ)
**៩៧%**

ទំហំកម្ចីជាមធ្យម
**៣.០០០ ដុល្លារ**

គ្រឹះស្ថានដែលផ្តល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍

- អេស៊ីលីដា
- ហត្ថា
- អិលអូអិលស៊ី
- មហានគរ
- ហ្វីលីព
- ប្រាសាក់
- ជាប់បៃលយូប៊ីហ្វាយនែន

## ព័ត៌មានអំពីសហគមន៍

សហគមន៍ដីធ្លីខេត្តប៉ៃលិន នៅតែបន្តប្រឈមនឹងវិវាទដីធ្លី និងការផ្លាស់ប្តូរភោគីទំនាស់តាំងពីឆ្នាំ២០០៦ ។ សហគមន៍នេះត្រូវបានបង្កើតឡើងដោយកសិករភាគច្រើន ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះ អត្រាអ្នកធ្វើចំណាកស្រុកបានកើនឡើងយ៉ាងគំហុក ។ បច្ចុប្បន្នប្រហែល៧០% នៃចំនួនគ្រួសារសរុប មានសមាជិកគ្រួសារយ៉ាងតិចម្នាក់ជាពលករចំណាកស្រុក ដែលភាគច្រើនទៅប្រទេសថៃ ប៉ុន្តែក៏មានទៅធ្វើការរោងចក្រកាត់ដេរនៅកម្ពុជាដែរ ។ ជីវភាពរស់នៅរបស់ពួកគាត់ ជួបការគំរាមកំហែងធ្ងន់ធ្ងរបិត្តិជំងឺកូវីដ១៩ វិវាទដីធ្លីដែលអូសបន្លាយពេលច្រើនឆ្នាំ និងបំណុលមីក្រូហិរញ្ញវត្ថុដ៏ច្រើនលើសលុប ។

ដំបូងឡើយ មន្ត្រីរដ្ឋាភិបាលម្នាក់បានទាមទារដីធ្លីរបស់សហគមន៍ជាកម្មសិទ្ធិរបស់ខ្លួននៅឆ្នាំ២០០៦ ដោយបានព្យាយាមឈូសឆាយដំណាំរបស់ប្រជាពលរដ្ឋលើដីទំហំជាង ២.០០០ ហិកតា ។ ក្រោយមកមន្ត្រីរដ្ឋាភិបាលនេះបានបោះបង់ការទាមទារ ។ នៅឆ្នាំ២០១២ ដីដដែលនេះត្រូវបានទាមទារដោយអតីតអភិបាលខេត្ត និងក្រោយមកដោយភរិយានៃអតីតអភិបាលខេត្តដែលជាអភិបាលខេត្តបច្ចុប្បន្ន ។ តំណាងសហគមន៍០៣នាក់ ត្រូវបានឃុំខ្លួន និងចោទប្រកាន់ពីបទរំលោភយកដីសាធារណៈ និងប្រើប្រាស់អំពើហិង្សាលើអាជ្ញាធរក្នុងឆ្នាំ២០១៤ ហើយក្រោយមកតំណាងម្នាក់ទៀតត្រូវបានចាប់ខ្លួនដោយសារការអំពាវនាវឱ្យដោះលែងអ្នកទាំងនោះ ។ ដោយមានការតវ៉ា និងដាក់ញត្តិទៅស្ថាប័នជាតិ និងអន្តរជាតិ តំណាងសហគមន៍ទាំង០៤នាក់ ត្រូវបានដោះលែងវិញ ។ បច្ចុប្បន្នគ្រួសារភាគច្រើនបានទទួលសំណងមួយចំនួនជាដីធ្លី ចន្លោះពី២ ទៅ ១២ហិកតា ។ ទោះបីជាយ៉ាងណា គ្រួសារខ្លះមិនទាន់ទទួលបានសំណងគ្រប់គ្រាន់ ហើយគ្រួសារទាំងអស់មិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅឡើយទេ ។

## ប្រភពនៃប្រាក់ចំណូល

កសិកម្មដាំដុះ • ចិញ្ចឹមសត្វ • ប្រមូលអនុផលព្រៃឈើ • ចំណាកស្រុក • កម្មករស៊ីឈ្នួល

## ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

បាត់បង់ប្រាក់ចំណូល • បំណុលកាន់តែច្រើន • ភាពតានតឹងផ្លូវចិត្ត • ជាប់ពន្ធនាគារ • ការរើសអើង និងការធ្វើទុក្ខបុកម្នេញតាមផ្លូវច្បាប់

## បញ្ហាដែលមិនទាន់មានដំណោះស្រាយ

កង្វះសំណងសមរម្យ • កង្វះប័ណ្ណកម្មសិទ្ធិដីធ្លី

## បំណុលមីក្រូហិរញ្ញវត្ថុ

បំណុលមីក្រូហិរញ្ញវត្ថុ កំពុងបំផ្លាញជីវិតរស់នៅ ក្រុមគ្រួសារ និងជីវភាពក្នុងសហគមន៍ដីធ្លីខេត្តប៉ៃលិន ។ ប្រហែលជា ៩៧% នៃគ្រួសារសរុបនៅក្នុងសហគមន៍ ជាប់ជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ និងភាគច្រើននៃពួកគាត់បានលក់ដី ដើម្បីសងបំណុល ។ ជាធម្មតា មន្ត្រីឥណទាននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានជាប់ពាក់ព័ន្ធក្នុងការគំរាមកំហែង ការក្លែងបន្លំ ការបំភិតបំភ័យ និងការបង្ខិតបង្ខំឱ្យសងប្រាក់ ។ អ្នកខ្ចីប្រាក់ជារឿយៗ មានការភ័យខ្លាច សូម្បីតែការពិភាក្សាអំពីប្រាក់កម្ចីរបស់ពួកគាត់ជាមួយមន្ត្រីឥណទាន ក្នុងករណីដែលការពិភាក្សានោះនាំឱ្យមានការគំរាមកំហែង ឬការចាត់វិធានការផ្លូវច្បាប់បន្ថែមទៀត ។ អ្វីដែលកាន់តែធ្វើឱ្យព្រួយបារម្ភថែមទៀត គឺការកើនឡើងនៃបំណុលក៏នាំឱ្យមានផលវិបាកកាន់តែអាក្រក់ឡើង ចំពោះបញ្ហាចំណាកស្រុកមិនស្របច្បាប់ ពលកម្មកុមារ សេវាផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារផងដែរ ។

### សម្រង់ពាក្យសម្តីពីប្រជាពលរដ្ឋសហគមន៍

"យើងតាំងពីជំពាក់មីក្រូហិរញ្ញវត្ថុមក ពីមុនយើងធ្លាប់ហូបបានពេញមាត់ ឥឡូវយើងលែងហូបបានពេញមាត់ដូចមុនហើយ"

"មន្ត្រីឥណទាន បានកត់ត្រាទ្រព្យអ្នកខ្ចីទាំងអស់ ទាំងគ្រាក់ទ័រ ទាំងម៉ូតូ ដល់ពេលអត់លុយសង គេឱ្យលក់របស់អស់ហ្នឹង "

"គេមកម្តងពីរនាក់ បីនាក់ ហើយគំរាមថា "មីង! បើមីងឯងរកលុយមិនបានសងខ្ញុំ ខ្ញុំហៅទៅភូមិ ឃុំហើយ""

"ពេលខ្លះ យើងអត់ចង់ខ្ចីផង តែគេនៅជំរុញឱ្យយើងយកទៀត"

"បើយើងអត់លក់ដីសងគេទេ គេនឹងមករាល់ថ្ងៃ អ៊ីចឹងហើយយើងអត់ចង់ខ្មាសគេ"

"យើងមិនសូវចេះដឹង អត់មានអីប្រកែកជាមួយគេទេ គេថាមិចក៏ត្រូវ គេស្តីឱ្យមិចស្តីទៅ គេគំរាមមិចគំរាមទៅ យើងមិនហ៊ានជាមួយគេទេ"

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

កសិកម្ម • សាងសង់ផ្ទះ • ទិញម៉ូតូ • ទិញដី • ការសិក្សារបស់កូន • មង្គលការកូន • ព្យាបាលជំងឺ • ចំណាយក្នុងគ្រួសារ • ចំណាកស្រុក • សងបំណុលផ្សេងៗ

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

វាយតម្លៃលើប្រាក់ចំណូលជាប្រចាំ • មន្ត្រីឥណទានខ្លះក្លែងបន្លំមូលហេតុសម្រាប់ការខ្ចីប្រាក់

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទាន បានចុះតាមផ្ទះរបស់អ្នកខ្ចី ដើម្បីស្នើផ្តល់កម្ចី ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និង គោលការណ៍នៃកម្ចីដែរឬទេ?

- អ្នកខ្ចីភាគច្រើន មិនអាចអាន ឬ សរសេរអក្សរទេ និងពឹងលើមន្ត្រីឥណទាន និងកូនៗ ឱ្យពន្យល់ពួកគាត់អំពី លក្ខខណ្ឌនៃកម្ចី ។

> "ដីកន្លែងហ្នឹងធ្វើឱ្យវណ្ណកលុយមីក្រូហិរញ្ញវត្ថុ ដោយសារវាអត់អំណោយផល ។ យើងយកលុយគេមកដាំដុះ ប៉ុន្តែចុងបញ្ចប់យើងអស់ដីដោយសារដីអត់មានជីវជាតិ"
>
> "មន្ត្រីឥណទានម្នាក់និយាយថា បើដាក់គោលបំណងខ្ចីយកទៅធ្វើចំការ បងអាចទទួលកម្ចីបានតែ២លានទេ តែបើថែមធ្វើបង្គន់ បងអាចខ្ចីដល់៤លាន ទោះបីដាក់ស្តែងមិនធ្វើបង្គន់ក៏មិនអីដែរ"

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការប្រមូលឥណទានដោយរំលោភបំពាន • ការផ្តល់កម្ចីឥណទានបែបកេងចំណេញ • ការក្លែងបន្លំ • ការរក្សាប័ណ្ណកម្មសិទ្ធិដីធ្លីក្រោយពីបង់សងផ្តាច់រួច • ការដាក់សម្ពាធឱ្យលក់ដី • គំរាមកំហែង

- សមាជិកសហគមន៍ បានប្រាប់ឱ្យដឹងថា មន្ត្រីឥណទានបានគំរាមកំហែងពួកគាត់ឱ្យលក់ដី ឬទាក់ទងទៅអាជ្ញាធរមូលដ្ឋាន ឬចាត់វិធានការផ្លូវច្បាប់ នៅពេលពួកគាត់បង់សងយឺត ។
- មន្ត្រីឥណទានខ្លះ គិតថ្លៃសេវាច្រើនហួសហេតុ រហូតដល់៩% នៃប្រាក់កម្ចី មុនពេលពួកគេផ្តល់កម្ចី ។ មន្ត្រីឥណទានខ្លះ បានរក្សាទុកប្លង់ដីរបស់អ្នកខ្ចី រហូតដល់ពីរខែ បើទោះជាអ្នកខ្ចីបានបង់ផ្តាច់ប្រាក់កម្ចីទាំងអស់ហើយក៏ដោយ ។
- មន្ត្រីឥណទានខ្លះ ជំរុញឱ្យអ្នកខ្ចីទៅខ្ចីពីអ្នកចងការឯកជន ដើម្បីសងបំណុលខ្លួន និងករណីខ្លះទៀតអ្នកចងការឯកជនបានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើម្បីចងការបន្តដល់សហគមន៍ ។

### ផលវិបាកនៃបំណុល

ខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ • ខ្ចីប្រាក់ពីអ្នកចងការឯកជន • ពលកម្មកុមារ • កុមារបោះបង់ការសិក្សា • កាត់បន្ថយអាហារបរិភោគ • ភាពតានតឹងក្នុងគ្រួសារ • ព្យាបាលជំងឺ • លក់ដី • ចំណាកស្រុក • លក់ទ្រព្យសម្បត្តិផ្សេងៗ • បម្រើសេវាផ្លូវភេទ

- ប្រហែលជា ៦០% នៃអ្នកខ្ចីបានលក់ដីរបស់ពួកគាត់ ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ ។
- ការចំណាកស្រុក កើតឡើងជាទូទៅ ដោយប្រហែល៧០% នៃគ្រួសារសរុប យ៉ាងតិចណាស់មានសមាជិកគ្រួសារម្នាក់ បានចំណាកស្រុកទៅធ្វើការ ។ ពេលខ្លះ អ្នកចំណាកស្រុកទាំងនេះ គឺមិនទាន់គ្រប់អាយុនៅឡើយ ឬ ឪពុកម្តាយចំណាកស្រុកដើម្បី រកការងារធ្វើ ហើយទុកកូនតូចៗនៅផ្ទះ ។ កុមារជាច្រើនបោះបង់ការសិក្សា ហើយក្រោយមកចំណាកស្រុកទៅធ្វើការ ។
- ប្រជាពលរដ្ឋមួយចំនួនប្រាប់ពី ការកាត់បន្ថយអាហារប្រចាំថ្ងៃពី៣ពេល មកត្រឹម ២ពេល ដើម្បីសន្សំប្រាក់បង់សងបំណុល ។
- ការលក់ដី គឺជាវិធីទូទៅមួយសម្រាប់អ្នកខ្ចីប្រាក់ ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ ។
- សមាជិកសហគមន៍ម្នាក់ បានប្រាប់មនុស្សមួយចំនួនថា គាត់បម្រើសេវាផ្លូវភេទ ដើម្បីរកប្រាក់សងបំណុលមីក្រូហិរញ្ញ វត្ថុ ។ គ្រួសារមួយចំនួន បានបែកបាក់ ឬលែងលះគ្នា ជា លទ្ធផលនៃភាពតានតឹងផ្លូវចិត្តនៃការជំពាក់កម្ចីឥណទានខ្នាតតូច ។

### ការប៉ះពាល់ផ្លូវចិត្ត

ភ័យខ្លាច • អៀនខ្មាស

- ភាពភ័យខ្លាចភាគច្រើន ពាក់ព័ន្ធជុំវិញនឹងការគំរាមកំហែងរបស់មន្ត្រីឥណទានថា នឹងយកអ្នកខ្ចីទៅជួប អាជ្ញាធរមូលដ្ឋាន នគរបាល ឬចាត់ការតាមផ្លូវច្បាប់ នៅពេលដែលអ្នកខ្ចីបង់សងយឺត ។

> "បើសិនជាយើងអត់លក់ផ្ទះសងគេទេ គេនឹងមករាល់ថ្ងៃ អ៊ីចឹងហើយយើងអត់ចង់ខ្មាសគេទេ"
>
> "ខ្ញុំអត់មានបញ្ហាអីជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទេ តែខ្ញុំលក់ផ្ទះដើម្បីយកទៅសងពួកគេ"

## អំឡុងពេល ជំងឺកូវីដ១៩

### ការប្រែប្រួលនៃប្រាក់ចំណូល

ប្រាក់ចំណូលធ្លាក់ចុះ

- ការបិទព្រំដែននិង និងផ្អាកដំណើរការរោងចក្រ នាំឱ្យប្រាក់ចំណូលប្រជាពលរដ្ឋធ្លាក់ចុះជាខ្លាំង អំឡុងពេលជំងឺកូវីដ១៩ ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានមិនបានស្នើផ្តល់រៀបចំឥណទានឡើងវិញ

- អ្នកខ្ចីមួយចំនួនបានស្នើសុំ និងទទួលបានការរៀបចំឥណទានឡើងវិញ ប៉ុន្តែពួកគាត់បានបង្ហាញពីការព្រួយបារម្ភថា បន្ទាប់ពីការពន្យារពេលបញ្ចប់ គាត់អាចនឹងលក់ដីដើម្បីសងបំណុល ។

### មតិយោបល់ផ្សេងៗ

- កម្រិតបំណុលនៅក្នុងសហគមន៍គឺ ច្រើនលើសលុប ។ អត្រាការប្រាក់ និងថ្លៃសេវា គឺខ្ពស់ពេក និងបានធ្វើឱ្យប៉ះពាល់ទៅដល់ការរស់របស់ប្រជាពលរដ្ឋជាច្រើន ។



# សហគមន៍អូរល្វីប្រេង

១៦ គ្រួសារ
វិវាទដីធ្លីកើតឡើងនៅឆ្នាំ ១៩៩៨

ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ (ប៉ាន់ប្រមាណ)

៥៦%

ទំហំកម្ចីជាមធ្យម

១.០០០ ដុល្លារ

គ្រឹះស្ថានដែលផ្តល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍

អេស៊ីលីដា • អម្រឹត • អិលអូអិលស៊ី

## ព័ត៌មានអំពីសហគមន៍

សហគមន៍អូរល្វីប្រេង ស្ថិតក្នុងស្រុកបវេល ខេត្តបាត់ដំបង ដែលសមាជិកសហគមន៍ជាច្រើន បានចូលមករស់នៅតាំងពីដើមឆ្នាំ ១៩៩០ ។ សហគមន៍ដីធ្លីបង្កើតឡើងដំបូង នៅពេលដែលប្រជាពលរដ្ឋចំនួន ៣៨ គ្រួសារ ត្រូវបានបង្ខំឱ្យចាកចេញពីដីពួកគាត់ដោយអ្នកមានឥទ្ធិពលម្នាក់ ក្នុងនោះ១៦គ្រួសារមិនទាន់ទទួលបានសំណងនៅឡើយ និងកំពុងតស៊ូមតិទាមទារសិទ្ធិរបស់ពួកគាត់ ។ ចាប់តាំងពីវិវាទដីធ្លីបានកើតឡើង សមាជិកសហគមន៍មិនអាចដាំដុះដំណាំ ឬស្រូវ គ្រប់គ្រាន់សម្រាប់ការចិញ្ចឹមជីវិតឡើយ ។ ដូច្នេះការចំណាកស្រុក ការខ្ចីប្រាក់ និងការធ្វើជាកម្មករស៊ីឈ្នួល ជាមធ្យោបាយតែមួយគត់ក្នុងការរកប្រាក់ចំណូល ។

ក្នុងឆ្នាំ១៩៩៨ អ្នកជំនួញមានទ្រព្យស្តុកស្តម្ភម្នាក់ឈ្មោះ អៀង អឿន បានចូលមកឈូសឆាយ និងរំលោភយកដីសហគមន៍ក្រោមការជ្រោមជ្រែងពីកម្លាំងប្រដាប់អាវុធ ។ មួយឆ្នាំក្រោយមកគាត់បានប្តឹងប្រជាពលរដ្ឋ ១៤គ្រួសារ តំណាងដោយតំណាងសហគមន៍ម្នាក់ដោយបានចោទប្រកាន់ថា បានរំលោភយកដីចំនួន ១១០ហិកតា ដែលគាត់បានអះអាងថាជាកម្មសិទ្ធិរបស់ខ្លួន ។ តុលាការបានសម្រេចឱ្យលោក អៀង អឿន ឈ្នះក្តី ប៉ុន្តែប្រជាពលរដ្ឋនៅតែបន្តទាមទាររកយុត្តិធម៌ និងតស៊ូមតិ ដើម្បីសិទ្ធិដីធ្លីពួកគាត់ ។ នៅឆ្នាំបន្តបន្ទាប់មានពាក្យបណ្តឹងកាន់តែច្រើន ហើយកម្លាំងប្រដាប់អាវុធជាច្រើនត្រូវបានហៅមក ដើម្បីបំភិតបំភ័យ និងបញ្ឈប់សមាជិកសហគមន៍ពីការប្រើប្រាស់ដីធ្លីរបស់ពួកគាត់ ។ នៅឆ្នាំ ២០១៦ អៀង អឿន បានបង្ហាញវត្តមានជាមួយអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ច ដើម្បីឈូសឆាយដីដែលមានវិវាទ និងជីកប្រឡាយព័ន្ធជុំវិញដី ដើម្បីរារាំងសមាជិកសហគមន៍មិនឱ្យចូលទៅទីនោះ ដើម្បីបង្កបង្កើនផល ។

### ប្រភពនៃប្រាក់ចំណូល

កសិកម្មដាំដុះ • ចិញ្ចឹមសត្វ • កម្មករស៊ីឈ្នួល • ចំណាកស្រុក

### ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

បាត់បង់ប្រាក់ចំណូល • តំណាងសហគមន៍ជាប់ពន្ធនាគារ • កុមារបោះបង់ការសិក្សា • ការកើនឡើងចំណាកស្រុក

### បញ្ហាដែលមិនទាន់មានដំណោះស្រាយ

គ្មានសំណង • ការធ្វើទុក្ខបុកម្នេញតាមផ្លូវច្បាប់លើតំណាងសហគមន៍

## បំណុលមីក្រូហិរញ្ញវត្ថុ

ប្រជាពលរដ្ឋប្រហែលជា ៥៦% នៃគ្រួសារសរុបក្នុងសហគមន៍អូរល្វីប្រេង ជាប់ជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ ប៉ុន្តែសហគមន៍មួយនេះមិនមានបញ្ហាជំពាក់បំណុលច្រើនលើសលុប ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូចសហគមន៍ផ្សេងទេ ។ នេះក៏ព្រោះតែមានពលរដ្ឋតិចតួចណាស់ មានប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លី ដូច្នេះហើយទើបពួកគាត់មិនអាចខ្ចីកម្ចីផ្ទាល់ខ្លួនបាន ។ អ្នកដែលបានទទួលកម្ចីផ្ទាល់ខ្លួន ក៏ដូចជាអ្នកខ្ចីកម្ចីជាក្រុមដែលមិនតម្រូវឱ្យដាក់ទ្រព្យធានា ពួកគាត់នៅតែប្រឈមនឹងផលវិបាកនៃបំណុលដូចសហគមន៍ផ្សេងដូចជា ការកាត់បន្ថយអាហារបរិភោគ ការខ្ចីពីអ្នកចង់ការឯកជន និងការលក់ទ្រព្យសម្បត្តិ ដើម្បីសងបំណុល ។ អ្នកខ្ចីក៏ប្រឈមនឹងការអៀនខ្មាស ការបំភិតបំភ័យ និងអ្នកខ្ចីខ្លះបានលក់ដីរបស់ពួកគាត់ ដើម្បីសងបំណុលឯកជនដែលអ្នកចងការឯកជនមួយចំនួននោះ បានខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីផ្តល់ប្រាក់កម្ចីឯកជនបន្ត ។ លើសពីនេះទៀត ក្នុងចំណោមអតីតសមាជិកសហគមន៍ ២២គ្រួសារ ដែលចាកចេញពីសហគមន៍ក្រោយទទួលបានដីជាសំណង មានយ៉ាងតិច ៥គ្រួសារ ដែលបានលក់ដីមួយផ្នែក ឬ ទាំងអស់ដើម្បីសងបំណុល ។

### សម្រង់ពាក្យសម្តីពីប្រជាពលរដ្ឋសហគមន៍

“ធនាគារអន្តរជាតិថាឱ្យមកជួយកម្ពុជា តែមិនមែនមកជួយកម្ពុជាទេ គេមកសម្លាប់យើងទៅវិញ”

“សូមផ្ញើព័ត៌មាននេះឱ្យទៅដល់ថ្នាក់ដឹកនាំមីក្រូហិរញ្ញវត្ថុផង អ៊ីចឹងគេអាចដោះស្រាយបញ្ហាបានហើយ ។ ខ្ញុំអត់ចង់តវ៉ាគេអីទេ ខ្ញុំគ្រាន់តែចង់ឱ្យគេជួយដោះស្រាយបញ្ហា និងមានយុត្តិធម៌”

“ពេលដែលគេ( មន្ត្រីឥណទាន )មក ខ្ញុំប្រាប់គាត់ថាខ្ញុំអត់ទាន់មានលុយទេ ហើយសុំគាត់ពន្យារពេលសង ។ ពួកគាត់អត់មាននិយាយអីសោះ ដល់អ៊ីចឹងខ្ញុំក៏ទៅខ្ចីពីអ្នកចងការឯកជន កុំឱ្យពួកគាត់រឹបអូសដី ហើយមកស្តី មកប្តឹងយើង ”

“ពិបាកណាស់ ខ្ញុំអត់ចង់លក់ដី ៥ហិកតា យកសងគេទេ តែខ្ញុំរកលុយអត់បាន ខ្ញុំអត់ដឹងថាធ្វើមិចរកលុយគ្រប់ទេ ទល់តែខ្ញុំលក់ដី ។ លុយអត់ច្រើនទេ តែអត់ដឹងប្រាប់( គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ) មិច គេអត់ស្តាប់យើងទេ គេដឹងតែចង់បានលុយគេ ”

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

ធ្វើកសិកម្ម • សាងសង់ផ្ទះ • ទិញដី • ការសិក្សាកូន • ចំណាយក្នុងគ្រួសារ • ចំណាកស្រុក • សងបំណុលផ្សេងទៀត

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

មន្ត្រីឥណទានទាមទារប័ណ្ណកម្មសិទ្ធិដីធ្លី និងចង់បានប័ណ្ណកម្មសិទ្ធិពីរ និងអ្នកធានាម្នាក់ • សម្រាប់កម្ចីជាក្រុម មន្ត្រីឥណទានមើលលើទ្រព្យសម្បត្តិ ទំហំដី និងមុខរបរ ។ល។

- ទោះបីជាកម្ចីជាក្រុមមិនតម្រូវឱ្យមានទ្រព្យដាក់ធានា មន្ត្រីឥណទាននៅតែសិក្សាលើទំហំ និងតម្លៃដីធ្លីរបស់អ្នកខ្ចី ។
- សមាជិកសហគមន៍ភាគច្រើនគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីទេ មានន័យថាពួកគាត់ភាគច្រើនមិនអាចទទួលបានកម្ចីផ្ទាល់ខ្លួនទេ ។

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទានបានចុះតាមផ្ទះរបស់អ្នកខ្ចី ដើម្បីស្នើផ្តល់កម្ចី ហើយប្រជាពលរដ្ឋចែករំលែកព័ត៌មានពីម្នាក់ទៅម្នាក់ទៀត ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និង គោលការណ៍នៃកម្ចីដែរឬទេ?

- ជាទូទៅ អ្នកទទួលបានកម្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចេះសរសេរ និងអានអក្សរ ។

> “អ្នកផ្សារខ្ចីពីមីក្រូហិរញ្ញវត្ថុទៅ ជីវភាពគេរៀងប្រសើរ តែសម្រាប់អ្នកស្រែ ខ្ចីទៅមិនឃើញមានប្រសើរឡើងអីទេ ”

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការប្រមូលឥណទានដោយរំលោភបំពាន

- មន្ត្រីឥណទានភាគច្រើនមានឥរិយាបថសមរម្យ ហើយមិនសូវមានការគំរាមកំហែង ឬការបំភិតបំភ័យនោះទេ ប៉ុន្តែអ្នកខ្ចីមួយចំនួន នៅតែរៀបរាប់ពីការគំរាមកំហែង និងការដាក់សម្ពាធយ៉ាងខ្លាំង នៅពេលយឺតក្នុងការបង់សង ។

### ផលវិបាកនៃបំណុល

ខ្ចីប្រាក់ពីអ្នកចងការឯកជន • កាត់បន្ថយអាហារបរិភោគ • លក់ទ្រព្យសម្បត្តិ • កាត់បន្ថយចំណាយលើការសិក្សាកូន

- គ្រួសារមួយចំនួន បានប្រាប់ឱ្យដឹងថា ការកាត់បន្ថយចំណាយពាក់កណ្តាលលើអាហារបរិភោគ ដើម្បីសន្សំទុកបង់សងបំណុល ។

### ការប៉ះពាល់ផ្លូវចិត្ត

ព្រួយបារម្ភណ៍

- អ្នកខ្ចីមួយចំនួនព្រួយបារម្ភ ដោយសារពួកគាត់បានលក់គោអស់ និងខ្លាចថា នឹងត្រូវលក់ដីនាពេលខាងមុខ ដើម្បីសងបំណុល ។
- អ្នកខ្ចីម្នាក់ទៀតព្រួយបារម្ភថា មន្ត្រីឥណទានអាចនឹងបង្ហោះសារលើបណ្តាញសង្គមហ្វេសប៊ុកអំពីការបង់សងយឺតរបស់គាត់ ។

> “ខ្ញុំយឺតបង់ បួនថ្ងៃ ហើយខ្ញុំសុំគេ ពីរថ្ងៃទៀត ។ ផុតពីរថ្ងៃហ្នឹង គេមកគ្នា ២ម៉ូតូ ៣នាក់ គេមកស្តីថាឱ្យខ្ញុំ រហូតដល់ប្តីខ្ញុំឡើងស្ទះខ្យល់ ។ ចំខ្ញុំរោគបេះដូង ថាឱ្យខ្ញុំ ខ្ញុំសន្លប់បាត់ដូចប្តីខ្ញុំដែលទៅ មិនវីរហើយ........អ៊ីចឹងហើយគេថាខ្ញុំកុហកទៀត”

## អំឡុងពេល ជំងឺកូវីដ១៩

### ការប្រែប្រួលនៃប្រាក់ចំណូល

ប្រាក់ចំណូលធ្លាក់ចុះ

- តម្លៃកសិផលធ្លាក់ថ្លៃអំឡុងពេលជំងឺកូវីដ១៩ ហើយវាពិតជាពិបាកក្នុងការធ្វើចំណាកស្រុក ខណៈដែលតម្លៃម្ហូបអាហារ និងទំនិញប្រើប្រាស់ប្រចាំថ្ងៃបានកើនឡើង ដែលបណ្តាលឱ្យជីវភាពគ្រួសារកាន់តែធ្លាក់ចុះធ្ងន់ធ្ងរ ។
- ទឹកជំនន់បានបំផ្លាញដំណាំ និងធ្វើឱ្យទិន្នផលធ្លាក់ចុះ ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានខ្លះបានជូនដំណឹងអ្នកខ្ចីពីការរៀបចំឥណទានឡើងវិញ

- មន្ត្រីឥណទានខ្លះបានបដិសេធសំណើរៀបចំឥណទានឡើងវិញរបស់អ្នកខ្ចី

### មតិយោបល់ផ្សេងៗ

- កម្រិតបំណុលក្នុងសហគមន៍គឺ “ច្រើនលើសលុប” ។ ជីវភាពប្រជាពលរដ្ឋថយចុះ កម្រិតបំណុលកើនឡើង ។

> “ឆ្នាំ២០២០ នេះ ពិបាករកលុយខ្លាំងណាស់ អត់មានអ្នកទិញទេ ។ ដល់អ៊ីចឹងស្អីក៏លក់អស់ដែរ ដើម្បីយកលុយទៅសងមីក្រូហិរញ្ញវត្ថុ”



# សហគមន៍បឹងប្រាំ

**១៩២** គ្រួសារ

វិវាទដីធ្លីកើតឡើងនៅឆ្នាំ **២០០៥**

ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ
(ប៉ាន់ប្រមាណ)

**៨០%**

ទំហំកម្ចីជាមធ្យម

**១ ០០០ ដុល្លារ**

គ្រឹះស្ថានដែលផ្តល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍

អេស៊ីលីដា • អេអឹមខេ • អម្រឹត • អិលអូអិលស៊ី • ប្រាសាក់ • ស្ថាបនា • ដាប់ប៊ែលយូប៊ី ហ្វាយនែន

## ព័ត៌មានអំពីសហគមន៍

សហគមន៍បឹងប្រាំ ស្ថិតនៅក្នុងខេត្តបាត់ដំបង ជាកន្លែងដែលសមាជិកសហគមន៍បានចាប់ផ្តើមចូលមករស់នៅ និងដាំដុះដំណាំតាំងពីទសវត្សរ៍ឆ្នាំ១៩៩០ ។ ពីមុនសហគមន៍នេះស្ថិតក្នុងឃុំអំពិលប្រាំដើមប៉ុន្តែបច្ចុប្បន្នស្ថិតនៅក្នុងឃុំបឹងប្រាំ ។ សមាជិកសហគមន៍ពឹងផ្អែកចម្បងលើ ការធ្វើកសិកម្ម និងការចំណាកស្រុក ដើម្បីចិញ្ចឹមជីវិត ហើយបញ្ហាពុំរ៉ែនៃគ្រោះរាំងស្ងួត និងបញ្ហាបំណុល បានធ្វើឱ្យប្រាក់ចំណូលរបស់ប្រជាពលរដ្ឋធ្លាក់ចុះយ៉ាងខ្លាំង ។

នៅឆ្នាំ២០០៥ ប្រជាពលរដ្ឋចំណូលថ្មីជាច្រើនគ្រួសារមកពីខេត្តផ្សេងៗ បានចូលមកតាំងទីលំនៅក្នុងតំបន់នេះដឹកនាំដោយបុរសម្នាក់ ដែលក្រោយមកក្លាយជាមេឃុំ ។ វិវាទដីធ្លីដែលកើតឡើងពីការចូលមករស់នៅនេះ បានបង្កឱ្យមានការប៉ះទង្គិចគ្នាដោយហិង្សាក្នុងឆ្នាំ២០១១ ជាពេលដែលដំណាំ និងផ្ទះសម្បែងរបស់សមាជិកសហគមន៍ត្រូវបានបំផ្លាញ ហើយមនុស្សជាច្រើនបានរងរបួស និងស្ត្រីម្នាក់បានបាត់បង់ជីវិត ។ នៅឆ្នាំ២០១២ ប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានផ្តល់ឱ្យគ្រួសារមួយចំនួន ប៉ុន្តែសមាជិកសហគមន៍ចំនួន ១៩២ នាក់នៅតែមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី និងសំណងសមរម្យនៅឡើយទេ ។ សហគមន៍បានបន្តដាក់ញត្តិទៅអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីស្វែងរកដំណោះស្រាយសមរម្យ បន្ទាប់ពីទទួលបានលិខិតមួយពីព្រឹទ្ធសភានៅឆ្នាំ២០១៤ សមាជិកសហគមន៍ជាច្រើនអាចបង្កបង្កើនផលលើដីរបស់ពួកគាត់ ប៉ុន្តែពួកគាត់រង់ចាំដំណោះស្រាយជាក់លាក់លើបញ្ហាដីធ្លីនេះ ។

## ប្រភពនៃប្រាក់ចំណូល

កសិកម្ម • កម្មករស៊ីឈ្នួល • ចិញ្ចឹមសត្វ • ចំណាកស្រុក

## ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

ភាពតានតឹងផ្លូវចិត្ត • ការធ្វើទុក្ខបុកម្នេញតាមផ្លូវច្បាប់ • បាត់បង់ផលដំណាំ • បាត់បង់ប្រាក់ចំណូល • បាត់បង់អាយុជីវិត • រងរបួស • ផ្ទះត្រូវបានដុត

## បញ្ហាដែលមិនទាន់បានដោះស្រាយ

ការផ្តល់សំណងមិនគ្រប់គ្រាន់ • គ្មានប័ណ្ណកម្មសិទ្ធិដីធ្លី

## បំណុលមីក្រូហិរញ្ញវត្ថុ

ប្រហែល ៨០% នៃគ្រួសារសរុបនៅក្នុងសហគមន៍បឹងប្រាំ ជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ ប៉ុន្តែភាគច្រើនកម្ចីទាំងនោះគឺជាកម្ចីជាក្រុម ។ គ្រួសារជាច្រើនមិនមានប័ណ្ណកម្មសិទ្ធិដីធ្លី ដោយសារបញ្ហាវិវាទដីធ្លីដូច្នេះវានាំឱ្យមានផលវិបាក ក្នុងការទទួលបានឥណទានជាលក្ខណៈបុគ្គល ។ ក្នុងករណីមួយ សមាជិកសហគមន៍ម្នាក់ត្រូវបានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបីផ្សេងគ្នាបដិសេធការស្នើសុំកម្ចីផ្ទាល់ខ្លួន ដោយសារគាត់គ្មានប័ណ្ណកម្មសិទ្ធិដីធ្លី ដូច្នេះគាត់អាចស្នើបានត្រឹមកម្ចីឥណទានជាក្រុមតែប៉ុណ្ណោះ ។ ប៉ុន្តែទោះជាបែបនេះ និងទោះជាមានទំហំកម្ចីតូចជាងសហគមន៍ផ្សេងៗទៀតនៅកម្ពុជា អ្នកខ្ចីប្រាក់នៅក្នុងសហគមន៍នេះនៅតែរាយការណ៍ អំពីការប្រឈមនឹងការគំរាមកំហែង ការលក់ដីដោយបង្ខំ ការកាត់បន្ថយការបរិភោគអាហារ និងចំណាកស្រុកដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ ។ កុមារជាច្រើនត្រូវបោះបង់ការសិក្សា និងបញ្ជូនឱ្យទៅធ្វើការទាំងនៅបណ្តាខេត្តផ្សេងៗ និងប្រទេសថៃ ដើម្បីរកប្រាក់បន្ថែមសម្រាប់សងបំណុល ហើយសមាជិកសហគមន៍ជាច្រើនបានរៀបរាប់ពីអារម្មណ៍អៀនខ្មាស កើតទុក្ខ និងភ័យខ្លាច ចំពោះកម្រិតនៃបំណុលមីក្រូហិរញ្ញវត្ថុរបស់ពួកគាត់ ។

### សម្រង់ពាក្យសម្តីពីប្រជាពលរដ្ឋសហគមន៍

"មុននឹងឱ្យយើងខ្ចី គេសួរអស់ មានគោ មានក្របី មានផ្ទះ មានដីប៉ុន្មាន?"

"ចំពោះខ្ញុំ ខ្ញុំខ្ចីអត់បាន ខ្ញុំអត់មានប្លង់ដី "

"កាលខ្ចីពីមុន ជីវភាពចេះតែរកបាន ធ្វើស្រូវបាន ដល់មករាំងស្ងួត ៣ឆ្នាំនេះទៅ ជីវភាពក៏កាន់តែដុនដាប ខ្លះកូនឈប់រៀនទៅថៃជួយម៉ែឪ បើចឹងយើងមិចមានអីបង់ការ "

"ខ្ញុំខ្ចីអង្គការ(មីក្រូហិរញ្ញវត្ថុ)អត់បានទេ ដោយសារខ្ញុំអត់មានប្លង់ដូចគេ គេអត់ឱ្យ ទើបខ្ញុំទៅរកឯកជន"

"ខ្ញុំលក់ស្រូវអស់ហើយ ដើម្បីសងគេ ខ្ញុំអត់មានសល់លុយអីទៀតទេ"

"បន្ទាប់ពីកូនខ្ញុំទៅថៃហើយ គេមកសួរយើងថា មានចង់ខ្ចីលុយអត់"

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

ធ្វើកសិកម្ម • ទិញដី • ព្យាបាលជំងឺ • ចំណាកស្រុក

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

អ្នកមានអាយុច្រើនជាង ៦០ឆ្នាំ មិនអាចទទួលបានកម្ចីទេ ទាល់តែពួកគាត់មានកូនទៅធ្វើការនៅប្រទេសថៃ • មន្ត្រីឥណទានទាមទារប្លង់កម្មសិទ្ធិដីធ្លីសម្រាប់កម្ចីផ្ទាល់ខ្លួន

- អ្នកខ្ចីម្នាក់ ត្រូវបានបដិសេធក្នុងការទទួលបានកម្ចី ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បីផ្សេងគ្នា ដោយសារគាត់គ្មានប័ណ្ណកម្មសិទ្ធិដីធ្លី ។
- អ្នកខ្ចីផ្សេងទៀតបានប្រាប់ថា ពិតជាពិបាកស្នើសុំកម្ចីណាស់ លុះត្រាតែអ្នកខ្ចីមានកូនយ៉ាងតិចម្នាក់ធ្វើការនៅប្រទេសថៃ ។

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទាន បានចុះតាមផ្ទះរបស់អ្នកខ្ចី ដើម្បីស្នើផ្តល់កម្ចី ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និងគោលការណ៍នៃកម្ចីដែរឬទេ?

- អ្នកខ្ចីភាគច្រើនចេះអាន និងសរសេរអក្សរ ហើយអ្នកដែលមិនចេះអក្សរ ជារឿយៗស្វែងរកសាក្សី ឱ្យជួយអានកិច្ចសន្យាសម្រាប់ពួកគាត់ ។

> “មន្ត្រីឥណទានមកសួរថា មានត្រូវការខ្ចីឬអត់ ខ្ញុំថាត្រូវការ ប៉ុន្តែគេសួរខ្ញុំថាមានប្លង់អត់ ហើយខ្ញុំឆ្លើយថាអត់មានទេ ។ ហើយគេនិយាយថាគេត្រូវការ "និយាយជាមួយមេគេសិន"”

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការប្រមូលឥណទានដោយរំលោភបំពាន • ការដាក់សម្ពាធឱ្យលក់ដី • ការគំរាមកំហែង

- ក្នុងករណីមួយ មន្ត្រីឥណទានម្នាក់បានដាក់ស្លាក "ផ្ទះលក់" នៅផ្ទះរបស់អ្នកខ្ចី ក្រោយពីគាត់បានយឺត ២ថ្ងៃក្នុងការបង់សង ។
- ករណីមួយទៀត អ្នកខ្ចីប្រាក់ចំនួនប្រហែល ៧៥០ដុល្លារ ម្នាក់បានយឺតក្នុងការបង់សងប្រាក់ ដោយសារការធ្វើស្រែចំការប្រព្រឹត្តទៅមិនបានល្អ ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានរឹបអូសយកដីរបស់គាត់ ដោយមិនបានអនុវត្តតាមប្រព័ន្ធតុលាការ ។

### ផលវិបាកនៃបំណុល

ខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ • ខ្ចីប្រាក់ពីអ្នកចងការឯកជន • ពលកម្មកុមារ • កុមារបោះបង់ការសិក្សា • កាត់បន្ថយអាហារបរិភោគ • ភាពតានតឹងក្នុងគ្រួសារ • លក់ដី • ចំណាកស្រុក • លក់ទ្រព្យសម្បត្តិ

- សមាជិកសហគមន៍ បានប្រាប់ឱ្យដឹងពីការកាត់បន្ថយអាហារបរិភោគ ដែលអ្នកខ្លះកាលពីមុនអាចមានលទ្ធភាពទិញត្រីសម្រាប់បរិភោគជាប្រចាំ ប៉ុន្តែឥឡូវអាចត្រឹមបរិភោគបាយជាមួយប្រហុកជាច្រើនថ្ងៃជាប់ៗគ្នា ។

### ការប៉ះពាល់ផ្លូវចិត្ត

ភ័យខ្លាច • កើតទុក្ខ • អៀនខ្មាស

- អ្នកខ្ចីម្នាក់ បានប្រាប់ឱ្យដឹងថា គាត់បានយំបន្ទាប់ពីមន្ត្រីឥណទានប្រាប់ថាគាត់មិនអាចទទួលបានការពន្យារពេល ឬរៀបចំឥណទានឡើងវិញ អំឡុងពេលរីករាលដាលជំងឺកូវីដ ១៩ ។

> “ដោយសារចំណូលធ្លាក់ចុះ បំណុលចេះតែកើនឡើង ”
>
> “ខ្ញុំចង់ឈប់ខ្ចីលុយពីមីក្រូហិរញ្ញវត្ថុ និងឈប់ដាំដំឡូងហើយ ។ ខ្លាចថាបើខ្ញុំធ្វើស្រែអត់បាន អត់អីលក់សងគេ ខ្ញុំដឹងតែត្រូវលក់ដីហើយ”

## អំឡុងពេល ជំងឺកូវីដ១៩

### ការប្រែប្រួលនៃប្រាក់ចំណូល

ប្រាក់ចំណូលធ្លាក់ចុះ

- ការធ្លាក់ចុះប្រាក់ចំណូលអំឡុងពេលរីករាលដាលនៃជំងឺកូវីដ១ ៩ បានកើតឡើងបន្ទាប់ពីមានគ្រោះរាំងស្ងួត ០៣ឆ្នាំ ដែលបានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កសិករ នៅក្នុងសហគមន៍។
- អំឡុពេលនៃការរីករាលដាលនៃជំងឺនេះ អ្នកចំណាកស្រុកជាច្រើនដែលធ្វើការនៅប្រទេសថៃ ត្រូវបានកាត់បន្ថយម៉ោងធ្វើការ ឬត្រូវ បង្ខំឱ្យត្រឡប់មកស្រុកកំណើតវិញ នាំឱ្យពួកគាត់បាត់បង់ប្រាក់ចំណូលបន្ថែមទៀត ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានស្នើផ្តល់រៀបចំឥណទានឡើងវិញ • មន្ត្រីឥណទានខ្លះបានបដិសេធសំណើរៀបចំឥណទានឡើងវិញរបស់អ្នកខ្ចី

- អ្នកខ្ចីម្នាក់ ពឹងផ្អែកលើប្រាក់ចំណូលរបស់សមាជិកគ្រួសារម្នាក់ដើម្បីបង់សងកម្ចី ។ សមាជិកគ្រួសារនេះជាពលករចំណាកស្រុកនៅប្រទេសថៃ ដែលត្រូវបានកាត់បន្ថយម៉ោងធ្វើការដោយសារការរីករាលដាលនៃជំងឺកូវីដ១៩ ។ មន្ត្រីឥណទាននៅតែបដិសេធការស្នើសុំរៀបចំឥណទានឡើងវិញរបស់អ្នកខ្ចី ។

### មតិយោបល់ផ្សេងៗ

- សមាជិកសហគមន៍ បានស្នើសុំគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឱ្យជួយផ្តល់ការរៀបចំឥណទានឡើងវិញ និងអនុវត្តតាមសារាចរណែនាំរបស់ធនាគារជាតិនៃកម្ពុជា អំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩ ដើម្បីជួយសម្រាលបន្ទុករបស់អ្នកខ្ចី ។
- អ្នកខ្ចីដែលពឹងផ្អែកលើការប្រមូលផលតែងមានបញ្ហាក្នុងការបង់សងប្រាក់ប្រចាំខែដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ព្រោះពួកគាត់មិនអាចរកប្រាក់ចំណូលបាន លុះត្រាតែប្រមូលផលរួច។




**ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ (ប៉ាន់ប្រមាណ)**

៩៥%

**ទំហំកម្ចីជាមធ្យម**

៥ ០០០ ដុល្លារ

**គ្រឹះស្ថានដែលផ្តល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍**

- អេស៊ីលីដា
- អេអឹមខេ
- អម្រឹត
- ប្រៃសណីយ៍កម្ពុជា
- អិលអូអិលស៊ី
- មហានគរ
- ហ្វីលីព
- ប្រាសាក់
- ស្ថាបនា
- ទ្រព្យខ្ញុំ
- ដាប់ប៊ែលយូប៊ី ហ្វាយនែន

## ព័ត៌មានអំពីសហគមន៍

សហគមន៍ខ្ញុំ ជាសហគមន៍កសិកម្មមួយ នៅខេត្តឧត្តរមានជ័យ ។ ប្រជាពលរដ្ឋពឹងផ្អែកលើកសិកម្មដាំដុះ ចិញ្ចឹមសត្វ និងការកើនឡើងនៃការធ្វើចំណាកស្រុក ដើម្បីចិញ្ចឹមជីវិត ។ ប្រហែលជា ៨០% នៃគ្រួសារសរុប មានសមាជិកគ្រួសារយ៉ាងតិចម្នាក់ជាពលករចំណាកស្រុក ដែលភាគច្រើនឆ្លងដែន ទៅធ្វើការនៅប្រទេសថៃ ។

ក្រុមហ៊ុន ស្ករអំពៅ ចំនួន០៣ ដែលជាបុត្រសម្ព័ន្ធក្រុមហ៊ុនស្ករដ៏ធំមួយនៅប្រទេសថៃ ឈ្មោះ មីត-ផុល បានទទួលដីសម្បទានសេដ្ឋកិច្ច និងចូលមកតំបន់នេះនៅឆ្នាំ២០០៧ និងបានចាប់ផ្តើមបណ្តេញប្រជាពលរដ្ឋចេញក្នុងឆ្នាំ២០០៩ ។ ប្រជាពលរដ្ឋបានបាត់បង់ដីធ្លីពី ២,៥ ទៅ ២០ហិកតា ក្នុងមួយគ្រួសារ ហើយគ្រួសារជាច្រើនត្រូវបានបង្ខំឱ្យទទួលយកសំណងមិនសមស្រប ដែលស្នើដោយមន្ត្រីរដ្ឋាភិបាលតំណាងឱ្យក្រុមហ៊ុន ។ បើមិនទទួលសំណងនេះ និងចាកចេញទេ ដីពួកគាត់ត្រូវរឹបអូស ។ ប្រជាពលរដ្ឋមួយចំនួន បានទទួលយកសំណងនេះ រីឯអ្នកផ្សេងទៀត មិនទទួលយក ប៉ុន្តែប្រជាពលរដ្ឋទាំងពីរក្រុមបានបន្តតស៊ូមតិ ដើម្បីទាមទារសំណងពេញលេញ និងយុត្តិធម៌ ។ ក្រុមហ៊ុនទាំងនោះ បានចាកចេញកាលពីឆ្នាំ២០១៤ ហើយប្រជាជនបានវិលត្រឡប់ទៅរស់នៅលើដីពួកគាត់វិញ ក្នុងឆ្នាំ២០១៥ ។ ដីសំណងដែលប្រជាពលរដ្ឋខ្លះទទួលបានដោយបង្ខំ ជាប្រភេទដីព្រៃ និងសម្បូរដោយយុទ្ធភណ្ឌមិនទាន់ផ្ទុះ(មីន) ហើយវិវាទដីធ្លីថ្មីបានកើតឡើងនៅពេលរដ្ឋាភិបាលផ្តល់ដីសម្បទានសង្គមកិច្ចដល់ប្រជាពលរដ្ឋមកពីខេត្តត្បូងឃ្មុំ ដែលផ្អែកខ្លះជាន់គ្នាលើដីសហគមន៍ខ្ញុំ ។

### ប្រភពនៃប្រាក់ចំណូល

កសិកម្មដាំដុះ • ការចិញ្ចឹមសត្វ • ការប្រមូលអនុផលព្រៃឈើ • ចំណាកស្រុក • កម្មករស៊ីឈ្នួល

### ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

ប្រាក់ចំណូលធ្លាក់ចុះ • បំណុល • ពលកម្មកុមារ • កុមារបោះបង់ការសិក្សា • មរណភាព • បញ្ហាសុខភាពផ្លូវចិត្ត • ភាពអត់ឃ្លាន • ការគំរាមកំហែងឬរឹតត្បិតពីអាជ្ញាធរ

### បញ្ហាដែលមិនទាន់មានដំណោះស្រាយ

មិនទាន់បានដីធ្លីរបស់ពួកគាត់ត្រឡប់មកវិញ • ខ្វះប័ណ្ណកម្មសិទ្ធិដីធ្លី • យុទ្ធភណ្ឌមិនទាន់ផ្ទុះ

## បំណុលមីក្រូហិរញ្ញវត្ថុ

ក្នុងចំណោមសមាជិកសហគមន៍ចំនួន ១៦២គ្រួសារ ប្រហែល ៩៥% នៃគ្រួសារសរុប ជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ ។ ពួកគាត់ជាច្រើនខ្ចីប្រាក់ដើម្បីធ្វើស្រែចំការ ចំណាកស្រុក ឬសម្អាតយុទ្ធភណ្ឌមិនទាន់ផ្ទុះ ។ ប្រជាពលរដ្ឋជាង ២០គ្រួសារ បានលក់ដី ដើម្បីសងបំណុល ខណៈដែលប្រជាពលរដ្ឋជាច្រើនទៀតបានរងនូវការគំរាមកំហែង ការបំភិតបំភ័យ និងសម្ពាធពីមន្ត្រីឥណទាន ។ បំណុលបានរុញច្រានឱ្យក្រុមគ្រួសារជាច្រើន ធ្លាក់ចូលទៅក្នុងស្ថានភាព ដែលពួកគាត់ត្រូវប្រឈមនឹង ការលក់ដីដោយបង្ខំ ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព ពលកម្មកុមារ និងភាពអត់ឃ្លាន ។ ក្រៅពីអ្នកខ្ចីប្រាក់សម្ពាធពីមន្ត្រីឥណទាន ក៏កើតមានចំពោះមនុស្សដែលត្រូវបានកំណត់ជាសាក្សីផងដែរ ។ មនុស្សមួយចំនួនដែលជាសាក្សីសម្រាប់កម្ចីមីក្រូហិរញ្ញវត្ថុ បានទទួលរងសម្ពាធពីមន្ត្រីឥណទានឱ្យលក់ដី ដើម្បីបង់សងបំណុលរបស់អ្នកខ្ចីប្រាក់ ។ កំរិតបំណុលនៅក្នុងសហគមន៍គឺស្ថិតនៅក្នុង "កំរិតអាសន្ន" ដែលរួមចំណែកដល់ការធ្លាក់ចុះនៃជីវភាពរស់នៅរបស់សមាជិកសហគមន៍ ។

### សម្រង់ពាក្យសម្តីពីប្រជាពលរដ្ឋសហគមន៍

"រកផ្សិតបាន មិនហ៊ានទុកហូបទេ សុខចិត្តលក់យកលុយសងបំណុល"

"ពីមុនធ្លាប់ហូបសាច់ជ្រូក សាច់គោ តែតាំងពីជំពាក់បំណុលធនាគារមក មិនដែលស្គាល់ជាតិសាច់គោ សាច់ជ្រូក ស្គាល់តែប្រហុក"

"បាត់បង់ដីស្រែទៅ ក៏ខាតបង់ប្រយោជន៍ ជំពាក់លុយធនាគារ ខ្ចីបំណុលគេរហូតហ្នឹង ។ ពីមួយថ្ងៃទៅមួយថ្ងៃ រកដោះទាល់រហូត "

"គេអត់មានប្រឹក្សារឿងហានិភ័យអីទេ ថាបើសិនពូឯងយកទៅធ្វើកសិកម្មអ៊ីចេះ អាចនឹងមានបញ្ហាអី ប្រមូលផលអត់បាន គិតដោះស្រាយយ៉ាងម៉េចអី មន្ត្រីឥណទានដូចជាអត់ឮនិយាយទេ "

"ឥឡូវនេះឃើញមានមន្ត្រីឥណទាន គេដើរចូលតាមផ្ទះរហូត ដើរទៅផ្សព្វផ្សាយ គ្នាគេពីរៗនាក់"

"មន្ត្រីទានមកផ្ទះខ្ញុំប៉ុន្មានដងហើយ ឱ្យខ្ញុំខ្ចីរហូត ។ ខ្ញុំថាអត់ទេ ខ្ញុំជំពាក់មួយស្ថាប័នហើយ គាត់និយាយថា "ខ្ចីពីរស្ថាប័នទៅ ខ្ញុំឱ្យបាន""

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

ធ្វើកសិកម្ម • សាងសង់ផ្ទះ • ទិញដី • ការសិក្សាកូន • សម្ភារដីដែលមានយុទ្ធកណ្ឌមិនទាន់ផ្ទះ • ព្យាបាលជំងឺ • ចំណាកស្រុក • សងបំណុលផ្សេង

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

មន្ត្រីឥណទានតម្រូវឱ្យដាក់ប័ណ្ណកម្មសិទ្ធិដីធ្លី • តម្លៃនៃទ្រព្យធានាលើសពីតម្លៃនៃកម្ចី • មន្ត្រីឥណទានសួរពីសមាជិកគ្រួសារជាពលករចំណាកស្រុក • មន្ត្រីឥណទានវាយតម្លៃលើប្រាក់ចំណូល

- អ្នកខ្ចីដែលមានអាយុច្រើនជាង ៥០ឆ្នាំ មិនអាចទទួលបានកម្ចីឡើយ លុះត្រាតែពួកគាត់មានសមាជិកគ្រួសារធ្វើការនៅប្រទេសថៃ ហើយជាធម្មតា មន្ត្រីឥណទាន តែងសួរថានៅក្នុងគ្រួសាររបស់អ្នកខ្ចីមានពលករចំណាកស្រុកប៉ុន្មាននាក់ ។

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទាន បានចុះតាមផ្ទះអ្នកខ្ចីដើម្បីស្នើផ្តល់កម្ចី និងបិទផ្សាយជាច្រើននៅផ្ទះរបស់ប្រជាពលរដ្ឋ ឬនៅតាមដងផ្លូវ ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និង គោលការណ៍នៃកម្ចីដែរឬទេ?

- អ្នកខ្ចីភាគច្រើន មិនអាចអាន ឬ សរសេរអក្សរទេ ដូច្នេះពួកគាត់ពឹងលើមន្ត្រីឥណទាន ឱ្យពន្យល់ពួកគាត់អំពី លក្ខខណ្ឌនៃកម្ចី ។

> “គេ(មន្ត្រីឥណទាន)សួរថាប្តីទៅថៃឬអត់ ប្រសិនបើប្តីមិនទៅថៃ គេមិនហ៊ានឱ្យខ្ចីច្រើនទេ”

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការប្រមូលឥណទានដោយរំលោភបំពាន • ការផ្តល់កម្ចីឥណទានបែបកេងចំណេញ • ការជំរុញឱ្យខ្ចីកម្ចីឯកជន • ការក្លែងបន្លំ • គំរាមកំហែង

- ពលរដ្ឋម្នាក់ ដែលបានផ្តិតមេដៃធ្វើជាសាក្សីលើឯកសារកម្ចីមួយ បានរៀបរាប់ថាពេលដែលអ្នកខ្ចីប្រាក់គ្មានលទ្ធភាពបង់សង មន្ត្រីឥណទានបានដាក់សម្ពាធឱ្យគាត់សងជំនួសព្រមទាំងបានកុហកគាត់ដោយព្យាយាមលេងល្បិចឱ្យគាត់ផ្តិតមេដៃ លើឯកសារមួយដើម្បីឯកភាពសងបំណុលជំនួសអ្នកខ្ចី ។ ក្រោយមកមន្ត្រីឥណទាន បានដាក់សម្ពាធឱ្យសាក្សី លក់ដីដើម្បីសងបំណុល ។
- មន្ត្រីឥណទានគំរាមកំហែង និងដាក់សម្ពាធ អ្នកផ្តិតមេដៃធ្វើជាសាក្សីនៃកម្ចី ឥណទាន ឱ្យលក់ដីដើម្បី សងបំណុល នៅពេលដែលអ្នកខ្ចីមិនអាចបង់សងបាន ។ យ៉ាងតិចណាស់សាក្សីចំនួន ០២នាក់ បានលក់ដី ដើម្បីសងបំណុលជំនួសអ្នកខ្ចីប្រាក់ ។
- មន្ត្រីឥណទាន បានគំរាមកំហែងអ្នកខ្ចីថា នឹងដាក់ឈ្មោះគាត់ក្នុងបញ្ជីខ្មៅ ប្រសិនបើគាត់បង់សងយឺតច្រើនថ្ងៃ ។

### ផលវិបាកនៃបំណុល

ខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ • ខ្ចីប្រាក់ពីអ្នកចងការឯកជន • ពលកម្មកុមារ • កុមារបោះបង់ការសិក្សា • កាត់បន្ថយអាហារបរិភោគ • ភាពតានតឹងក្នុងគ្រួសារ • លក់ដី • ចំណាកស្រុក • លក់ទ្រព្យសម្បត្តិ

- ការធ្វើចំណាកស្រុក ជាពិសេសការចំណាកស្រុកដោយគ្មានសុវត្ថិភាពតាមរយៈបណ្តាញក្រៅផ្លូវការ បានក្លាយជាបញ្ហាចម្បងដោយសារតែបញ្ហាបំណុល ។
- មានករណីជាច្រើន ដែលកុមារមិនទាន់គ្រប់អាយុ រហូតដល់១៣ ឆ្នាំ បានចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ ដើម្បី រកប្រាក់សងបំណុល ខ្នាតតូច ខណៈដែលក្មេងអាយុដល់ ១០ឆ្នាំ បានចំណាកស្រុកជាមួយឪពុកម្តាយ ដើម្បីស្វែងរកការងារធ្វើ ។
- គ្រួសារមួយបានលក់ដី បន្ទាប់ពីខ្ចីកម្ចីខ្នាតតូច ដើម្បីធ្វើចំណាកស្រុកតាមរយៈមេខ្យល់ តែត្រូវចាញ់បោកមេខ្យល់នោះ ។
- គ្រួសារមួយផ្សេងទៀត មានកូនប្រុសម្នាក់ដែលបានចំណាកស្រុកដើម្បីជួយ សងកម្ចីខ្នាតតូចមួយ តែក្រោយ មកបានបាត់ បង់ជីវិតក្នុងគ្រោះថ្នាក់នៅកន្លែងធ្វើការ ។

### ការប៉ះពាល់ផ្លូវចិត្ត

អៀនខ្មាស • កើតទុក្ខ • ព្រួយបារម្ភ

- អ្នកខ្ចីព្រួយបារម្ភថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនឹងរឹបអូស យកដីធ្លីពួកគាត់ បើពួកគាត់មិនអាចបង់សងកម្ចីឥណទានវិញទេ ។
- អ្នកខ្ចីជាច្រើនសម្រេចចិត្តលក់ដីព្រោះពួកគាត់មានអារម្មណ៍អៀនខ្មាស ដោយសារគ្មានលទ្ធភាពសងបំណុលឱ្យមន្ត្រីឥណទាន ។
- អ្នកខ្ចីមួយចំនួនដែលចំណាកស្រុក គឺមិន សប្បាយចិត្តនោះទេ ដែលត្រូវទុកកូនតូចៗនៅជាមួយជីដូនជីតា ។

## អំឡុងពេល ជំងឺកូវីដ១៩

### ប្រាក់ចំណូលប្រែប្រួល

ប្រាក់ចំណូលធ្លាក់ចុះ

- ប្រាក់ចំណូលគ្រួសារជាច្រើន ធ្លាក់ចុះដល់ ៩០% ដោយសារតម្លៃកសិផលធ្លាក់ចុះ និងពលករចំណាកស្រុកបានបាត់បង់ការងារ ឬត្រូវបានកាត់បន្ថយម៉ោងធ្វើការ ។ ថ្មីៗនេះ តម្លៃកសិផលកើនឡើង ប៉ុន្តែបញ្ហាទឹកជំនន់ធ្វើឱ្យទិន្នផលដំណាំធ្លាក់ចុះ ៧០% ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានមិនបានស្នើផ្តល់រៀបចំឥណទានឡើងវិញ • មន្ត្រីឥណទានខ្លះបានបដិសេធសំណើរៀបចំឥណទានឡើងវិញរបស់អ្នកខ្ចី

- អ្នកខ្ចីមួយចំនួនបានកត់សម្គាល់ថា ការរៀបចំឥណទានឡើងវិញដែលផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នឹងមិនអាចជួយពួកគាត់បានទេ ពីព្រោះពួកគាត់នឹងត្រូវសងបំណុលដែលត្រូវពន្យារពេលនោះនៅថ្ងៃក្រោយដដែល ។

### មតិយោបល់ផ្សេងៗ

- អត្រាការប្រាក់នៃកម្ចីខ្នាតតូច គួរតែត្រូវបានកាត់បន្ថយពាក់កណ្តាល ខណៈដែលមានផលប៉ះពាល់នៃជំងឺកូវីដ ១៩ ។
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគួរតែត្រូវបានគ្រប់គ្រងដោយស្ថាប័នរបស់រាជរដ្ឋាភិបាល ដើម្បីការពារការរំលោភបំពាន នៅពេលអ្នកខ្ចីបង់សងយឺត និងធ្វើឱ្យមានការប្រកួតប្រជែងតិចក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ការប្រកួតប្រជែងនាំឱ្យមាន សម្ពាធ លើអ្នកខ្ចីឱ្យខ្ចីបន្ថែម ។



# សហគមន៍ជោគជ័យ

៩១ គ្រួសារ

វិវាទដីធ្លីកើតឡើងនៅឆ្នាំ ២០១២

ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ
(ប៉ាន់ប្រមាណ)
**៩៥%**

ទំហំកម្ចីជាមធ្យម
**៥ ០០០ ដុល្លារ**

គ្រឹះស្ថានដែលផ្ដល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍

អេស៊ីលីដា • អេអឹមខេ • ហត្ថា • អិលអូអិលស៊ី • ប្រាសាក់ • អេស៊ីលីដា

## ព័ត៌មានអំពីសហគមន៍

សហគមន៍ជោគជ័យ ស្ថិតនៅក្នុងស្រុកឆែប ខេត្តព្រះវិហារ ជាសហគមន៍ជនបទមួយ ដែលពឹងផ្អែកប្រាក់ចំណូលលើកសិកម្ម និងការលក់អនុផលព្រៃឈើ ។ គ្រួសារមួយចំនួនមានសាច់ញាតិធ្វើការជាពលករចំណាកស្រុកនៅប្រទេសថៃ ឬធ្វើការនៅរោងចក្រក្នុងស្រុក ដើម្បីរកប្រាក់ចំណូល ។

ក្រុមហ៊ុនចំនួន ០៥ ដែលជាប់ពាក់ព័ន្ធនឹងម្ចាស់ជាជនជាតិចិន លោក រូយ ហ្វេង បានទទួលដីសម្បទានសេដ្ឋកិច្ចសរុបជាង ៤២.០០០ ហិកតា ក្នុងឆ្នាំ២០១១ ។ ព្រៃសហគមន៍ត្រូវបានក្រុមហ៊ុនឈូសឆាយ ដីស្រែចម្ការរបស់ប្រជាពលរដ្ឋចំនួន ១១០ ហិកតា ត្រូវបានរំលោភយកដោយគិតជាមធ្យម គ្រួសារនីមួយៗបាត់បង់ដីធ្លីពី ១ ទៅ ២ហិកតា ហើយអូរត្រូវបានចាក់ដីលុបអស់ ។ ការឈូសឆាយព្រៃសហគមន៍ពីសំណាក់ក្រុមហ៊ុនបានដាក់សម្ពាធឱ្យសមាជិកសហគមន៍ឱ្យកាប់ឆ្ការសម្អាតដីសម្រាប់ដាំដំណាំ និងបញ្ជាក់ពីភាពជាកម្មសិទ្ធិលើដីនោះផងដែរ ។ ហើយជាញឹកញាប់ កម្ចីមីក្រូហិរញ្ញវត្ថុត្រូវបានប្រើប្រាស់ ដើម្បីចំណាយលើការសម្អាតដី និងការដាំដុះ ។ កម្មកររបស់ក្រុមហ៊ុនបានជាប់ពាក់ព័ន្ធនឹងការប៉ះទង្គិចគ្នាបែបហិង្សាជាមួយសមាជិកសហគមន៍ ហើយអ្នកភូមិចំនួន ០៤នាក់ ត្រូវបានរងបណ្ដឹងបន្ទាប់ពីពួកគាត់បានដាំស្រូវលើដីវិវាទ ។ អាជ្ញាធរថ្នាក់ជាតិ មិនទាន់បានផ្ដល់សំណង ឬប័ណ្ណកម្មសិទ្ធិដីធ្លីដល់សមាជិកសហគមន៍នៅឡើយទេ ។ ថ្មីៗនេះក្រុមហ៊ុនទាំងនេះ ហាក់ដូចជាបានចាកចេញពីប្រទេសកម្ពុជាហើយនៅតែមានការដាំដុះស្រូវនៅលើដីសម្បទានដែលជាបញ្ហា ដោយសារវាធ្វើឱ្យតម្លៃស្រូវនៅក្នុងតំបន់ធ្លាក់ចុះ ។

## ប្រភពនៃប្រាក់ចំណូល

កសិកម្មដាំដុះ • ចិញ្ចឹមសត្វ • កម្មករស៊ីឈ្នួល • អនុផលព្រៃឈើ • ចំណាកស្រុក

## ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

ជួលដីដើម្បីធ្វើស្រែចម្ការ • ភាពតានតឹងនៅក្នុងសហគមន៍ • ចំណាកស្រុក • ការគំរាមកំហែងតាមផ្លូវច្បាប់ • បាត់បង់សេរីភាពជួបជុំគ្នា និងបញ្ចេញមតិ • ភាពតានតឹងផ្លូវចិត្ត • ប៉ះពាល់ដល់បរិស្ថាន • បាត់បង់ប្រាក់ចំណូល • បំណុលកើនឡើង

## បញ្ហាដែលមិនទាន់មានដំណោះស្រាយ

គ្មានសំណង • គ្មានប័ណ្ណកម្មសិទ្ធិដីធ្លី • ក្រុមហ៊ុនហាក់ដូចជាចាកចេញ • ដីព្រៃសហគមន៍មិនត្រូវបានទទួលស្គាល់

## បំណុលមីក្រូហិរញ្ញវត្ថុ

ប្រហែល ៩៥%នៃចំនួនគ្រួសារសរុប ជាប់ជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ ដោយ ៥%ទៀត គឺជាមនុស្សចាស់ជរា ឬអ្នកដែលគ្មានការងារធ្វើ ឬគ្មានដីធ្លី ។ ការខ្ចីប្រាក់របស់ប្រជាពលរដ្ឋពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានកើនឡើង ខណៈដែលប្រាក់ចំណូល និងជីវភាពរបស់ពួកគាត់ធ្លាក់ចុះ ដោយសារវិវាទដីធ្លី ។ ជាទូទៅ មូលហេតុនៃការខ្ចីប្រាក់គឺ ដើម្បីចំណាយលើការសម្អាតដីសម្រាប់ដាំដុះ ទិញសម្ភារៈកសិកម្ម ព្យាបាលជំងឺ និងសងបំណុលផ្សេងៗដែលមានស្រាប់ និងការចំណាយផ្សេងទៀត ។ ប្រជាពលរដ្ឋប្រហែល ០៧គ្រួសារ នៃ ៨៦គ្រួសារ ដែលបានខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានលក់ដីដើម្បីសងបំណុល ។ ការខ្វះប្រាក់ចំណូល គួបផ្សំនឹងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃជំងឺកូវីដ១៩ ប្រជាពលរដ្ឋជាច្រើនគ្មានលទ្ធភាពសងបំណុលវិញទេ ។ ជាលទ្ធផល ប្រជាពលរដ្ឋជាច្រើនកំពុងកាត់បន្ថយអាហារបរិភោគ ខ្ចីប្រាក់ពីប្រភពផ្សេងៗ លក់ដីនិងទ្រព្យសម្បត្តិ និងធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារធ្វើ ។ គ្មានអ្នកណាបានដឹង ឬទទួលបានការពន្យារពេល ឬរៀបចំឥណទានឡើងវិញឡើយ អំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩ រហូតដល់ខែកុម្ភៈ ឆ្នាំ២០២១ ហើយសមាជិកសហគមន៍យល់ថាការរៀបចំឥណទានឡើងវិញ នឹងធ្វើឱ្យបំណុលកាន់តែកើនឡើង ។

### សម្រង់ពាក្យសម្ដីពីប្រជាពលរដ្ឋសហគមន៍

"ខ្ញុំមានអារម្មណ៍ថា យើងជាកសិករខ្វះខាតដល់អ៊ីចឹងទៅយើងខំប្រឹងណាស់ ពុះពារ យើងរកកម្ចីនេះកម្ចីនោះ ដោយសារឃើញរោងចក្រគេធ្វើបានច្រើន ដំបូងខ្ចី១លាន ហើយ២លាន ឥឡូវចូលពាន់ហើយ"

"គាត់(មន្ត្រីឥណទាន) សួរ រឿងប្រាក់ចំណូល រឿងយកទៅធ្វើអីៗ តែរឿងថាយើងយកកម្ចីទៅមានហានិភ័យអី គាត់អត់បានប្រាប់ទេ"

"សុខចិត្តអត់ហូបអីទេ ហូបតែអំបិលប្រហុកហ្នឹង ដើម្បីទុកលុយសងគេ"

"ពេលយើងរកលុយសងគេមិនគ្រប់ សុខចិត្តលក់ស្រូវបង្គ្រប់លុយយកទៅបង់មីក្រូហិរញ្ញវត្ថុ អស់ស្រូវទុកហូបខ្លួនឯងតែទៅទិញគេវិញ"

"មានតែអ្នកអត់ប្លង់ទេ ទើបខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុអត់បាន"

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

ធ្វើកសិកម្ម • ទិញម៉ូតូ • ទិញដី • មង្គលការកូន • ឈូសឆាយដី • ព្យាបាលជំងឺ • ចំណាយក្នុងក្រុមគ្រួសារ • សងបំណុលផ្សេងទៀត

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

មន្ត្រីឥណទានតម្រូវឱ្យដាក់ប័ណ្ណកម្មសិទ្ធិដីធ្លី • វាយតម្លៃលើប្រាក់ចំណូល • វាយតម្លៃលើទំហំដី

- មន្ត្រីឥណទានបានសិក្សាលើប្រាក់ចំណូល នៅពេលស្នើផ្តល់ប្រាក់កម្ចី ប៉ុន្តែមិនបានប្រាប់អ្នកខ្ចី អំពីហានិភ័យ ឬ អ្វីដែលអាចនឹងកើតឡើងនៅពេលដែលអ្នកខ្ចីគ្មានលទ្ធភាពបង់សង ។

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទាន បានចុះតាមផ្ទះរបស់អ្នកខ្ចី ដើម្បីស្នើផ្តល់កម្ចី ហើយអ្នកដែលធ្លាប់ខ្ចីពីមុនបានចែករំលែកព័ត៌មាន ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និង គោលការណ៍នៃកម្ចីដែរឬទេ?

- អ្នកខ្ចីភាគច្រើន មិនអាចអាន ឬ សរសេរអក្សរទេ និងពឹងលើមន្ត្រីឥណទាន ឱ្យពន្យល់ពួកគាត់អំពី លក្ខខណ្ឌនៃកម្ចី ។
- អ្នកខ្ចីម្នាក់កត់សម្គាល់ថា ទោះបីជាអាចអានកិច្ចសន្យាបាន វានៅតែពិបាកយល់ពីអត្រាការប្រាក់ ឬពាក្យបច្ចេកទេសផ្សេងៗ ដូចជា "ហ៊ីប៉ូតែក" (ការព្រមព្រៀងផ្តល់ដីជាទ្រព្យធានា)ជាដើម ។

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការប្រមូលឥណទានដោយរំលោភបំពាន • ការផ្តល់កម្ចីឥណទានបែបកេងចំណេញ • ជំរុញឱ្យខ្ចីប្រាក់ពីអ្នកចងការឯកជន • រក្សាប្លង់ក្រោយបង់ផ្តាច់រួច

- ករណីមួយចំនួន មន្ត្រីឥណទានប្រាប់ទៅអ្នកខ្ចីឱ្យខ្ចី ឥណទានពីគ្រឹះស្ថានរបស់ខ្លួន ដើម្បីសងបំណុលគ្រឹះស្ថានមួយទៀត ។
- ករណីខ្លះ មន្ត្រីឥណទានបានឱ្យ "ប្រាក់កម្រៃ" ទៅអ្នកខ្ចីដែលបានបញ្ចុះបញ្ចូលអ្នកផ្សេងទៀតឱ្យទៅខ្ចីកម្ចីពីគ្រឹះស្ថានរបស់ខ្លួន ។
- ករណីខ្លះ មន្ត្រីឥណទានបានជំរុញឱ្យខ្ចីប្រាក់ពីអ្នកចងការឯកជន ដើម្បីសងបំណុលរបស់ខ្លួន ។
- ករណីយ៉ាងតិចពីរ ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរក្សាទុកជាច្រើនខែនូវប័ណ្ណកម្មសិទ្ធិដីធ្លី ដែលបានដាក់ជាទ្រព្យធានា បន្ទាប់ពីការបង់ផ្តាច់កម្ចីរួច ទោះជាអ្នកខ្ចីស្នើសុំប័ណ្ណកម្មសិទ្ធិវិញក៏ដោយ ។

### ផលវិបាកនៃបំណុល

ខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ • ខ្ចីប្រាក់ពីអ្នកចងការឯកជន • ពលកម្មកុមារ • កាត់បន្ថយអាហារបរិភោគ • លក់ដី • ចំណាកស្រុក • លក់ទ្រព្យសម្បត្តិផ្សេងៗ

- ប្រហែល ០៧ គ្រួសារនៅក្នុងសហគមន៍ បានលក់ដីធ្លីរបស់ពួកគាត់ ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ ។
- កុមារខ្លះ អាយុត្រឹម ១០ ឆ្នាំ ត្រូវបោះបង់ការសិក្សា ខណៈកុមារអាយុត្រឹម ១៥ឆ្នាំត្រូវធ្វើការដើម្បីសងបំណុល ។

### ការប៉ះពាល់ផ្លូវចិត្ត

ភ័យខ្លាច • សោកស្តាយ • កើតទុក្ខ • ព្រួយបារម្ភ

- ភាពភ័យខ្លាច កើតឡើងជុំវិញកង្វះការហូបចុក គ្មានលទ្ធភាពបង់សងបំណុលមីក្រូហិរញ្ញវត្ថុ គ្មានប្រាក់ផ្គត់ផ្គង់ការសិក្សាកូន និងការធ្លាក់ខ្លួនឈឺមិនអាចធ្វើការរកប្រាក់ដើម្បីសងបំណុល ។
- សមាជិកសហគមន៍ជាច្រើនបាននិយាយថា ពួកគាត់មានការសោកស្តាយក្នុងការយកប្រាក់កម្ចី ដែលបង្ខំឱ្យពួកគាត់លក់ទ្រព្យសម្បត្តិ និងសត្វចិញ្ចឹម ដើម្បីសងបំណុល ។

> "បើសិនជាស្រែខ្ញុំមិនសូវល្អ តម្លៃស្រូវថោក ច្រូតបានតិច ខ្ញុំខ្លាចតែអត់លុយសងគេគ្រប់ទៅ ខ្លាចគេរឹបអូសផ្ទះ រឹបអូសដី"

## អំឡុងពេល ជំងឺកូវីដ១៩

### ការប្រែប្រួលនៃប្រាក់ចំណូល

ប្រាក់ចំណូលធ្លាក់ចុះ

- ប្រាក់ឈ្នួលសម្រាប់កម្មករស៊ីឈ្នួល បានធ្លាក់ចុះប្រហែល៥០% ខណៈដែលទិន្នផលអនុផលព្រៃឈើ ក៏ធ្លាក់ចុះដូចគ្នាដែរ ។
- ភូមិត្រូវបានបិទខ្ទប់អស់ជាច្រើនខែអំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩ កាលពីឆ្នាំមុន មិនអាចចេញចូលបាននោះទេ ដែលនាំឱ្យរកប្រាក់ចំណូលបានតិច ប៉ុន្តែទំនិញឡើងថ្លៃខ្ពស់ ។
- ទិន្នផលស្រូវធ្លាក់ចុះដោយសារគ្រោះរាំងស្ងួត និងទឹកជំនន់ ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានមិនបានស្នើផ្តល់រៀបចំឥណទានឡើងវិញ

- គ្មាននរណាម្នាក់ បានដឹងអំពីជម្រើសរៀបចំឥណទានឡើងវិញ ឬស្នើសុំពន្យារពេលបង់សងកម្ចីមីក្រូហិរញ្ញវត្ថុឡើយ អំឡុងពេលរីករាលដាលនៃ ជំងឺកូវីដ ១៩ រហូតដល់ខែកុម្ភៈ ទើប សមាជិកមួយចំនួន ត្រូវបានស្នើផ្តល់រៀបចំឥណទានឡើងវិញ ។
- សមាជិកសហគមន៍យល់ឃើញថា ការរៀបចំឥណទានឡើងវិញ គឺធ្វើឱ្យបន្ទុកបំណុលរបស់ពួកគាត់កើនឡើង ។០៣គ្រួសារបានលក់ដីអំឡុងពេលកូវីដ ដើម្បីបង់សងកម្ចី ។
- គ្រួសារចំនួន ៣ បានលក់ដី អំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩ ដើម្បីបង់សងកម្ចីឥណទានខ្នាតតូច ។

### មតិយោបល់ផ្សេងៗ

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គួរតែយោគយល់ជាងនេះ អំឡុងពេលមានជំងឺកូវីដ ១៩ និងគួរបញ្ចុះអត្រាការប្រាក់ ឱ្យទាបជាងនេះ ។
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គួរពិចារណាឱ្យអ្នកខ្ចីបង់តែការប្រាក់ និងមិនគិតការប្រាក់លើប្រាក់ដើមដែលបានពន្យារពេល ។



# សហគមន៍កាំ និង ក្រេះ

៣៨៦ គ្រួសារ
វិវាទដីធ្លីកើតឡើងនៅឆ្នាំ ២០១១

ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ (ប៉ាន់ប្រមាណ)

**៧០% - ៩០%**

ទំហំកម្ចីជាមធ្យម

**១.០០០ ដុល្លារ**

គ្រឹះស្ថានដែលផ្តល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍

អេអឹមខេ
ហ្វីលីព
មហានគរ
ដាប់ប៊ែលយូប៊ី ហ្វាយនែន
អម្រឹត
អិលអូអិលស៊ី
ប្រាសាក់
ហត្ថា
លី ហួរ
ស្ថាបនា

## ព័ត៌មានអំពីសហគមន៍

សហគមន៍កាំ និងក្រេះ ជាសហគមន៍ពីរជាជនជាតិដើមភាគតិចនៅស្រុកអូរជុំ ខេត្តរតនគិរី ។ ប្រជាពលរដ្ឋភាគច្រើនជាកសិករ និងមិនមានកម្មករ កម្មការិនីរោងចក្រ ឬចំណាកស្រុកទៅប្រទេសក្រៅទេ ទោះបីជាមួយចំនួនបានផ្លាស់ទៅខេត្តជិតនោះ ដើម្បីធ្វើការ ។ ប្រជាពលរដ្ឋជាច្រើនដាំដុះដំណាំ ស្រូវ កៅស៊ូ ដំឡូង ស្វាយចន្ទីចេក និងសណ្តែក និងចិញ្ចឹមសត្វគោ ក្របី ជ្រូក មាន់ ទា ព្រមទាំងប្រមូលអនុផលព្រៃឈើ និងប្រកបការងារផ្សេងៗ នៅទីរួមខេត្ត ។ សហគមន៍ទាំងពីរមាន ដីសហគមន៍រួម ដែលសហគមន៍ក្រេះ បានទទួលប្លង់ដីសមូហភាពដោយទទួលស្គាល់ពីក្រសួងមហាផ្ទៃ ។

សហគមន៍ទាំងពីរ បានទទួលរងផលប៉ះពាល់ពីសំណាក់ក្រុមហ៊ុនចម្ការកៅស៊ូ ហ័ងអាញ់យ៉ាឡាយ ដែលក្នុងឆ្នាំ២០១១ចាប់ផ្តើមឈូសឆាយ និងរំលោភយកដីធ្លី ក្នុងនោះមានដីសហគមន៍ដែលមានដីព្រៃសហគមន៍ បឹង និងអូរ ទីកន្លែងសាសនា និង ភ្នំអារក្ស និងព្រៃអារក្ស ក៏ដូចជា ច្រប់និងប្រាប (កន្លែងដែលសហគមន៍ទៅរកបន្លែត្រី សាច់) ព្រៃបញ្ចុះសព និងទីសក្ការៈបូជានិងដីសមូហភាពរបស់សហគមន៍ផ្សេងទៀត ។ ក្រោយការឈូសឆាយទីកន្លែងគោរពបូជាដ៏សំខាន់មួយ អ្នកភូមិម្នាក់ត្រូវបានបាត់បង់ជីវិតដោយសាររន្ទះបាញ់ សាលារោងភូមិហើយអ្នកដឹកនាំសហគមន៍ម្នាក់បានបាត់បង់ជីវិតពេលកំពុងគេងសម្រាក និងអតីតអ្នកដឹកនាំកាលពីមុនបានវង្វេងបាត់បង់ស្មារតី ។ ដីធ្លីមួយចំនួនដែលបានបាត់បង់ទៅក្រុមហ៊ុនជាប្រភេទដីស្រែវិលជុំ ហើយប្រជាពលរដ្ឋព្រួយបារម្ភ បើពួកគាត់បាត់បង់ដីទាំងអស់ទៅឱ្យក្រុមហ៊ុន នោះពួកគាត់នឹងគ្មានដីសម្រាប់ចែកឱ្យកូនៗរបស់គាត់ឡើយ ។

### ប្រភពនៃប្រាក់ចំណូល

កសិកម្មដាំដុះ • ចិញ្ចឹមសត្វ • កម្មករស៊ីឈ្នួល • ចំណាកស្រុក • ប្រមូលអនុផលព្រៃឈើ • អ្នកលក់ដូរ

### ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

បាត់បង់ប្រាក់ចំណូល • ប៉ះពាល់បរិស្ថាន • បញ្ហាសុខភាពផ្លូវចិត្ត • បាត់បង់វប្បធម៌ ឬទីកន្លែងសាសនា • បាត់បង់ជីវិត

### បញ្ហាដែលមិនទាន់មានដំណោះស្រាយ

សំណងមិនគ្រប់គ្រាន់ • ការបំផ្លាញបរិស្ថាន

## បំណុលមីក្រូហិរញ្ញវត្ថុ

បំណុលមីក្រូហិរញ្ញវត្ថុ ជារឿងទូទៅនៅក្នុងសហគមន៍កាំ និងសហគមន៍ក្រេះ ដែលប្រហែលចន្លោះ ៧០% ទៅ ៩០% នៃគ្រួសារសរុបបានខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយភាគច្រើនដាក់ប្លង់កម្មសិទ្ធិដីធ្លីជាទ្រព្យធានា ។ នៅក្នុងសហគមន៍កាំ កម្ចីជាងពាក់កណ្តាលជាកម្ចីក្រុម ដោយសារមិនតម្រូវឱ្យមានប្លង់ជាទ្រព្យធានា ។ យ៉ាងតិចណាស់មានគ្រួសារចំនួន ៦ បានលក់ដី ដើម្បីសងបំណុល ហើយសមាជិកសហគមន៍សង្ស័យថា អាចនឹងមានច្រើនជាងនេះ ។ ការអនុវត្តប្រមូលឥណទានដោយរំលោភបំពានពីសំណាក់មន្ត្រីឥណទាន ដែលរួមមានការគំរាមកំហែងថានឹងហៅសមត្ថកិច្ចមកចាប់ខ្លួនអ្នកខ្ចីប្រាក់ ឬជំរុញឱ្យខ្ចីប្រាក់ពីអ្នកចងការឯកជន ប្រសិនបើអ្នកខ្ចីយឺត ៣ ទៅ៤ថ្ងៃ ក្នុងការបង់សង ។ សមាជិកសហគមន៍ជាច្រើនបានបង្ហាញពីភាពច្របូកច្របល់ និងខកចិត្តទៅលើតម្លៃសេវាដូចជា ថ្លៃបង់សងយឺត និងកង្វះការជួយសម្រាលបន្ទុកសម្រាប់អ្នកខ្ចីអំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩ ។

### សម្រង់ពាក្យសម្តីពីប្រជាពលរដ្ឋសហគមន៍

"បើអ្នកឯងអត់សងទេ អ្នកឯងនឹងឃើញឡានច្រើនមកដល់ផ្ទះហើយ ។ ដោយសារខ្ញុំឃើញគេអ្នកនៅជិតខ្ញុំហ្នឹង តាមទូរទស្សន៍ហ្នឹង គេនាំមនុស្សច្រើនមកមែន ហើយគេចាប់ឡើងឡាន ។ អ៊ីចឹងហើយទើបខ្ញុំខ្លាច"

"បើអ្នកខ្ចីគាត់អត់យល់ពីបញ្ហាទេ គឺគាត់អត់បាន ទៅស្តីតវ៉ាជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទេ"

"ពេលខ្ញុំបង់សងយឺត ៥ថ្ងៃ មន្ត្រីឥណទានមកដល់ផ្ទះខ្ញុំ ហើយនិយាយថា 'បើរកលុយសងអត់បានទេ ដឹងតែទៅដេកនៅប៉ុស្តិ៍ប៉ូលីសហើយ' ដល់អ៊ីចឹងខ្ញុំខ្លាចដោយសារកូនខ្ញុំទើបអាយុមួយឆ្នាំ"

"មន្ត្រីឥណទាននិយាយថា 'បើមានម៉ូតូលក់ម៉ូតូទៅ បើមានគោក្របី លក់គោក្របីទៅ ហើយបើមានដីលក់ដីទៅ ធ្វើមិចឱ្យតែមានលុយសងខ្ញុំ បើសិនអត់លក់ទេ ខ្ញុំហៅទៅជួបភូមិឃុំហើយ' "

"គាត់ខ្ចីលុយទៅធ្វើនេះធ្វើនោះ ហើយដល់ចុងក្រោយទៅ អត់បានផល អត់មានលុយសងគេ លក់ដី ដល់លក់ដីទៅអស់ហើយ មានអីទៀត ធ្វើអីក៏មិនកើតដែល"

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

កសិកម្ម • សាងសង់ផ្ទះ • ប្រកបអាជីវកម្ម • ទិញម៉ូតូ • ទិញដី • ការសិក្សាកូន • ព្យាបាលជំងឺ • ពិធីសាសនា • សងបំណុលផ្សេងទៀត

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

មន្ត្រីឥណទានតម្រូវឱ្យប័ណ្ណកម្មសិទ្ធិដីធ្លី • អ្នកមានអាយុច្រើនជាង ៥០ឆ្នាំ ពិបាកទទួលបានកម្ចីបើសិនគ្មានអ្នកធានា

- សមាជិកសហគមន៍បានប្រាប់ឱ្យដឹងថា ប្រសិនបើអ្នកចង់ខ្ចីកម្ចីផ្ទាល់ខ្លួន អ្នកត្រូវតែមានប័ណ្ណកម្មសិទ្ធិដីធ្លី ពុំនោះទេអ្នកខ្ចីបានតែកម្ចីក្រុមប៉ុណ្ណោះ ។

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទាន បានចុះតាមផ្ទះរបស់អ្នកខ្ចី ដើម្បីស្នើផ្តល់កម្ចី ។ អ្នកខ្ចីចែករំលែកព័ត៌មានជាមួយគ្នា ហើយមន្ត្រីឥណទានបិទខិត្តប័ណ្ណផ្សព្វផ្សាយនៅតាមផ្ទះ និងតាមផ្លូវ ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និង គោលការណ៍នៃកម្ចីដែរឬទេ?

- អ្នកខ្ចីភាគច្រើន មិនអាចអាន ឬ សរសេរអក្សរទេ និងពឹងលើមន្ត្រីឥណទាន ឱ្យពន្យល់ពួកគាត់អំពី លក្ខខណ្ឌនៃកម្ចី ។
- ករណីខ្លះមន្ត្រីឥណទាន ចំណាយក្រៅផ្លូវការលើអ្នកបកប្រែភាសាជនជាតិដើមភាគតិច ដើម្បីស្នើផ្តល់កម្ចី ។

> "បើសិនយើងមានប្លង់ យើងខ្ចីកម្ចីផ្ទាល់ខ្លួនបាន បើយើងអត់មានទេ យើងខ្ចីជាក្រុម"
>
> "ខ្ញុំអត់ដឹងថាថ្លៃសេវាគេប៉ុន្មានអីប៉ុន្មានទេ ខ្ញុំអត់យល់សោះម៉ង"

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការប្រមូលឥណទានដោយរំលោភបំពាន • ការផ្តល់កម្ចីឥណទានបែបកេងចំណេញ • ការជំរុញឱ្យខ្ចីប្រាក់ពីអ្នកចងការឯកជន • ការដាក់សម្ពាធឱ្យលក់ដី • ការគំរាមកំហែង

- សមាជិកសហគមន៍និយាយថា ការលក់ដីដោយបង្ខំ គឺជាការអនុវត្តទូទៅមួយពីសំណាក់មន្ត្រីឥណទាន នៅពេលអ្នកខ្ចីគ្មានលទ្ធភាពបង់សង ។
- អ្នកខ្ចីមួយចំនួនត្រូវបានមន្ត្រីឥណទានគំរាមកំហែងដោយបណ្តឹង ឬការចាប់ខ្លួនដោយអាជ្ញាធរ ។
- ពេលខ្លះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានផ្តល់កម្ចីដល់អ្នកខ្ចី ដើម្បីសងបំណុលនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយទៀត ។

### ផលវិបាកនៃបំណុល

ខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញ • ខ្ចីប្រាក់ពីអ្នកចងការឯកជន • ពលកម្មកុមារ • កាត់បន្ថយអាហារបរិភោគ • លក់ដី • ចំណាកស្រុក • លក់ទ្រព្យសម្បត្តិផ្សេងៗ • បញ្ចាំដំណេក

### ការប៉ះពាល់ផ្លូវចិត្ត

ភ័យខ្លាច • កើតទុក្ខ • ព្រួយបារម្ភ

- សមាជិកសហគមន៍បង្ហាញពីភាពភ័យខ្លាច ជុំវិញការបាត់បង់ដីធ្លីទាំងអស់របស់ពួកគាត់ និងគ្មានលទ្ធភាពចែកទ្រព្យសម្បត្តិអ្វីឱ្យកូនៗរបស់ពួកគាត់ ។
- មានការភ័យខ្លាច អំពីការជាប់ពន្ធនាគារផងដែរ ឬត្រូវធ្វើចំណាកស្រុក ដែលធ្វើឱ្យបាត់បង់ការផ្សារភ្ជាប់ទៅនឹងទិដ្ឋភាពខាងជំនឿសាសនា និងវប្បធម៌របស់សហគមន៍ ។

> "ប្រសិនបើមន្ត្រីឥណទានហ្នឹង ព្រមទទួលយកលុយដែលខ្ញុំមាន ១លាន ២លាន ហ្នឹងវាធូរខ្លះហើយ តែនេះគាត់អត់យក គាត់ថាធ្វើមិចឱ្យគ្រប់ការកំណត់របស់គេម៉ង ។ ដល់អ៊ីចឹងខ្ញុំខ្លាចគេប្តឹងខ្ញុំ"

## អំឡុងពេល ជំងឺកូវីដ១៩

### ការប្រែប្រួលនៃប្រាក់ចំណូល

ប្រាក់ចំណូលធ្លាក់ចុះ

- តម្លៃកសិផលធ្លាក់ចុះ និងអ្នកខ្ចីជាច្រើនគ្មានលទ្ធភាពសងប្រាក់កម្ចីពួកគាត់ទេ ដែលជំងឺកូវីដ១៩គឺជាហេតុផលមួយផងដែរ ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានមិនបានស្នើផ្តល់រៀបចំឥណទានឡើងវិញ • មន្ត្រីឥណទានបដិសេធសំណើរៀបចំឥណទានឡើងវិញរបស់អ្នកខ្ចី

- អ្នកខ្ចីម្នាក់ស្នើសុំមន្ត្រីឥណទាន ដើម្បីរៀបចំឥណទានឡើងវិញ ប៉ុន្តែមន្ត្រីឥណទានបានប្រាប់ថា មានតែអ្នកមានជំងឺកូវីដ១៩ ប៉ុណ្ណោះទើបអាចទទួលបានការរៀបចំឥណទានឡើងវិញ ។
- ពលរដ្ឋប្រហែលចំនួន ៧គ្រួសារ ក្នុងសហគមន៍កាំ បានលក់ដីសងបំណុលមីក្រូហិរញ្ញវត្ថុរបស់ពួកគាត់ អំឡុងពេលជំងឺកូវីដ ១៩ ។ ៣ គ្រួសារបានលក់ឱ្យអ្នកភូមិជនជាតិដើមដូចគ្នា និង៤គ្រួសារទៀត លក់ឱ្យជនជាតិខ្មែរដែលនៅក្រៅសហគមន៍ ។

### មតិយោបល់ផ្សេងៗ

- អត្រាការប្រាក់ខ្ពស់ពេក
- សមាជិកសហគមន៍ ក៏បានកត់សម្គាល់ឃើញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន មានជម្រើសអំពីធានារ៉ាប់រងដែលអាចទិញបាន ដូចនេះពេលអ្នកខ្ចីបាត់បង់ជីវិត មន្ត្រីឥណទាន នឹងមិនមកទារប្រាក់ពីគ្រួសាររបស់ពួកគាត់ឡើយ ។



# សហគមន៍តាឡាវ និង អ៊ីន

**២៦៨ គ្រួសារ**
**វិវាទដីធ្លីកើតឡើងនៅឆ្នាំ ២០១១**

**ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ (ប៉ាន់ប្រមាណ)**

**៩៥%**

**ទំហំកម្ចីជាមធ្យម**

**២.៥០០ ដុល្លារ**

**គ្រឹះស្ថានដែលផ្តល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍**

អេស៊ីលីដា • អេអឹមខេ • អម្រឹត • ហត្ថា • អិលអូអិលស៊ី • ប្រាសាក់ • ស្ថាបនា • ដាប់ប៊ែលយូប៊ី ហ្វាយនែន

## ព័ត៌មានអំពីសហគមន៍

សហគមន៍តាឡាវ និងសហគមន៍អ៊ីន ស្ថិតនៅឃុំតាឡាវ ខេត្តរតនគិរី ។ សហគមន៍ទាំងពីរជាជនជាតិដើមភាគតិច មានជាតិសាសន៍ និងសាសនាខុសៗគ្នាជាច្រើនរស់នៅរួមគ្នា ។ សហគមន៍ទាំងពីរ ពឹងផ្អែកចម្បងលើកសិកម្ម ដោយពុំមានកម្មករ កម្មការិនីរោងចក្រទេ និងមានចំណាកស្រុកតិចតួច ។ ប្រជាពលរដ្ឋ ដាំដុះដំណាំ ដំឡូង ស្វាយចន្ទី និងស្រូវ និងចិញ្ចឹមសត្វគោ ក្របី និងទា ព្រមទាំងប្រមូលអនុផលព្រៃដូចជា ផ្សិត និងជ័រទឹក ក៏ដូចជាធ្វើជាកម្មករស៊ីឈ្នួល ។ ជំនឿ និងដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច ដើរតួយ៉ាងសំខាន់សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ ។

សហគមន៍តាឡាវ និងសហគមន៍អ៊ីន បានរងផលប៉ះពាល់ពីក្រុមហ៊ុនចម្ការកៅស៊ូ ហ័ងអាញ់យ៉ាឡាយ ក្នុងឆ្នាំ២០១១ ដែលបានចាប់ផ្តើមឈូសឆាយ និងរំលោភយកដីប្រជាពលរដ្ឋ ក្នុងនោះមានដីសហគមន៍ដែលមានដីព្រៃសហគមន៍ បឹង និងអូរ ទីកន្លែងសាសនា និងអារក្ស ក៏ដូចជា ប្រប់និងប្រាប (កន្លែងដែលសហគមន៍ទៅរកបន្លែត្រីសាច់) និងទីសក្ការៈបូជា និងដីសមូហភាពសហគមន៍ផ្សេងទៀត ។ អ្នកភូមិជាច្រើន បានបាត់បង់ប្រភពចម្បងនៃប្រាក់ចំណូល និងទីគោរពបូជាបែបសាសនាសំខាន់ៗរបស់ពួកគាត់ ។ ក្រោយពីមានតស៊ូមតិអស់ជាច្រើនឆ្នាំ ក្រុមហ៊ុនបានយល់ព្រមចំណាយប្រាក់ជាច្រើនពាន់ដុល្លារឱ្យទៅសហគមន៍នីមួយៗ ដើម្បីទិញសត្វធ្វើពិធីសែនព្រេនសុំខមាទោសដល់អារក្ស ដែលត្រូវបានរំខានដោយសារសកម្មភាពក្រុមហ៊ុន ។ បច្ចុប្បន្ន អ្នកភូមិមិនទាន់ ទទួលបានដីសំណងមួយចំនួនត្រឡប់មកវិញជាផ្លូវការនៅឡើយទេ ហើយភាគច្រើនពួកគាត់ មិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីផងដែរ ។

### ប្រភពនៃប្រាក់ចំណូល

កសិកម្មដាំដុះ • ចិញ្ចឹមសត្វ • កម្មករស៊ីឈ្នួល • ប្រមូលអនុផលព្រៃឈើ

### ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

បាត់បង់ប្រាក់ចំណូល • ប៉ះពាល់បរិស្ថាន • បញ្ហាសុខភាពផ្លូវចិត្ត • បាត់បង់វប្បធម៌ និងទីសក្ការៈបូជា • បាត់បង់ជីវិត

- បន្ទាប់ពីក្រុមហ៊ុនឈូសឆាយភ្នំអារក្ស អ្នកភូមិឃើញដុំភ្លើងហោះចេញពីភ្នំទៅភូមិ ហើយពីរថ្ងៃក្រោយ អ្នកភូមិពីរនាក់បានស្លាប់ ។

### បញ្ហាដែលមិនទាន់មានដំណោះស្រាយ

គ្មានប័ណ្ណកម្មសិទ្ធិដីធ្លីលើដីសំណង

## បំណុលមីក្រូហិរញ្ញវត្ថុ

បំណុលមីក្រូហិរញ្ញវត្ថុ គឺជារឿងធម្មតានៅក្នុងសហគមន៍អ៊ីន និងតាឡាវ ដែលប្រហែល៩០% នៃគ្រួសារសរុបបានខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ប័ណ្ណកម្មសិទ្ធិដីធ្លី តែងតែត្រូវបានប្រើប្រាស់ជាទ្រព្យដាក់ធានា លើកលែងតែកម្ចីជាក្រុមប៉ុណ្ណោះ ។ តាមការប៉ាន់ប្រមាណប្រហែលជា ៩ គ្រួសារបានលក់ដីដែលជាភាគច្រើនជាដីស្រែចម្ការ ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ ។ អ្នកភូមិមួយចំនួនបានបង្ខំចិត្តចាកចេញពីភូមិ ដោយសារភាពអៀនខ្មាសពីការលក់ដី និងសម្ពាធពីមន្ត្រីឥណទាន ។ អ្នកភូមិមួយចំនួននៅសហគមន៍អ៊ីន គិតថាកម្រិតបំណុល គឺមិនទាន់ខ្ពស់ខ្លាំងពេកទេ ដោយសារអ្នកភូមិមួយចំនួនបានបដិសេធមិនយកកម្ចីលើសពី ៥ ០០០ ដុល្លារ ។ ប៉ុន្តែនៅសហគមន៍តាឡាវ ប្រជាពលរដ្ឋជាច្រើនបានប្រាប់ថាកម្រិតបំណុលគឺខ្ពស់ខ្លាំង ។ សមាជិកសហគមន៍អ៊ីន និងតាឡាវ បានទទួលរងសម្ពាធពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអ្នកចងការឯកជន ក៏ដូចជា ការអនុវត្តដោយរំលោភបំពានពីសំណាក់មន្ត្រីឥណទាន ។ ករណីមួយចំនួន មន្ត្រីឥណទាន បានតាមដានអ្នកខ្ចីប្រាក់ ដើម្បីប្រាកដថាពួកគាត់បានខ្ចីប្រាក់ពីអ្នកចងការឯកជន ឬគំរាមកំហែងដោយដាក់ស្លាក "សម្រាប់លក់" នៅមុខផ្ទះពួកគាត់ ។

### សម្រង់ពាក្យសម្តីពីប្រជាពលរដ្ឋសហគមន៍

"ជួនកាលដល់ខែសងប្រាក់ យើងទៅខ្ចីឯកជនទៅសងអង្គការ(គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) ហើយខ្ចីពីអង្គការទៅសងឯកជន "

"មន្ត្រីឥណទាននិយាយថា "បើសិនជាអត់សងមិនបានទេ ត្រូវលក់ដីលក់ទៅ ឬ ចង់ឱ្យខ្ញុំយក""

"បើមានគោ មានក្របីលក់ គេទុកដីឱ្យ តែអត់ទេ ដឹងតែគេលក់ដីហើយ យើងអត់មានលុយហូបសាច់ជ្រូក សាច់គោ ត្រូវទុកលុយសងគេ "

"ខ្ញុំអត់មានលុយសងគេ អញ្ចឹងហើយខ្ញុំលក់ដី.... ខ្ញុំខ្លាចថាបើខ្ញុំអត់សងគេ(គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) គេនឹងលក់ដីខ្ញុំ ។"

"មិនហ៊ានខ្ចីទៀតទេ ខ្លាចហើយ ខ្លាចអស់ដី អស់ធ្លី"

"មន្ត្រីឥណទានបានប្រាប់ខ្ញុំពីរ បីដងហើយឱ្យខ្ញុំទៅខ្ចីកម្ចីឯកជនដើម្បីសងបំណុលពួកគេ"

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

ធ្វើកសិកម្ម • សាងសង់ផ្ទះ • ទិញម៉ូតូ • ការសិក្សាកូន • មង្គលការកូន • ឈូសឆាយដី • ព្យាបាលជំងឺ • ជួសជុលផ្ទះ • សងបំណុលផ្សេងទៀត

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

មន្ត្រីឥណទានទាមទារឱ្យដាក់ប័ណ្ណកម្មសិទ្ធដីធ្លីទាំងអស់ • ការវាយតម្លៃប្រាក់ចំណូល • មន្ត្រីឥណទានខ្លះក្លែងបន្លំមូលហេតុនៃកម្ចី

- ករណីមួយ មន្ត្រីឥណទានបានដឹងថា អ្នកខ្ចីយកកម្ចីឥណទានដើម្បីព្យាបាលជំងឺ ទិញម៉ូតូ និងសម្រាប់ធ្វើអាជីវកម្មខ្លះ ប៉ុន្តែពួកគេបានសរសេរតែ"សម្រាប់ប្រកបអាជីវកម្ម" លើកិច្ចសន្យា។

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទាន បានចុះតាមផ្ទះរបស់អ្នកខ្ចី ដើម្បីស្នើផ្តល់កម្ចី ។ អ្នកខ្ចីចែករំលែកព័ត៌មានទៅវិញទៅមក ហើយមន្ត្រីឥណទានបិទខិត្តប័ណ្ណផ្សព្វផ្សាយនៅតាមផ្ទះ និងតាមផ្លូវ ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និង គោលការណ៍នៃកម្ចីដែរឬទេ?

- អ្នកខ្ចីភាគច្រើន មិនអាចអាន ឬសរសេរអក្សរទេ និងពឹងលើមន្ត្រីឥណទាន ឱ្យពន្យល់ពួកគាត់អំពី លក្ខខណ្ឌនៃកម្ចី ។
- ករណីខ្លះមន្ត្រីឥណទាន ចំណាយប្រាក់ក្រៅផ្លូវការលើអ្នកបកប្រែភាសាជនជាតិដើមភាគតិច ដើម្បីស្នើផ្តល់កម្ចី ។

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការប្រមូលឥណទានដោយរំលោភបំពាន • ការជំរុញឱ្យខ្ចីប្រាក់ពីអ្នកចងការឯកជន • ការរក្សាប័ណ្ណកម្មសិទ្ធិដីធ្លីក្រោយការបង់ផ្តាច់ • ការដាក់សម្ពាធឱ្យលក់ដី • ការគំរាមកំហែង

- ការបង្ខំឱ្យលក់ដី គឺជាការអនុវត្តជាធម្មតារបស់មន្ត្រីឥណទាន នៅក្នុងសហគមន៍ ។
- មន្ត្រីឥណទាន បានគំរាមដាក់ស្លាក "សម្រាប់លក់" នៅមុខផ្ទះរបស់អ្នកខ្ចី ដែលយឺតក្នុងការបង់សង ។
- មន្ត្រីឥណទានប្រាប់អ្នកខ្ចីឱ្យទៅខ្ចីប្រាក់បន្ថែម ពីអ្នកចងការឯកជន ដើម្បីសងប្រាក់កម្ចីរបស់ពួកគេ ហើយករណីខ្លះ ក៏បានផ្តល់ឈ្មោះ និងទីតាំងរបស់អ្នកចងការឯកជនឱ្យអ្នកខ្ចីទៀតផងដែរ ។

### ផលវិបាកនៃបំណុល

ធ្វើការបន្ថែម • ខ្ចីប្រាក់ពីអ្នកចងការឯកជន • កាត់បន្ថយអាហារបរិភោគ • លក់ដី • លក់ទ្រព្យសម្បត្តិផ្សេងៗ

- អ្នកខ្ចីប្រាក់ជាច្រើនបានលក់ទ្រព្យសម្បត្តិរបស់ខ្លួនដូចជា សត្វគោនិងក្របី ដើម្បីសងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាពិសេសអំឡុងពេលមានវិបត្តិសេដ្ឋកិច្ច បង្កឡើងដោយ ជំងឺកូវីដ១៩ ។

### ការប៉ះពាល់ផ្លូវចិត្ត

ភ័យខ្លាច • សម្ពាធ • ព្រួយបារម្ភ

- អ្នកខ្ចីជាច្រើនអាចបង់សងកម្ចីឥណទានរបស់ពួកគេទាន់ពេលវេលា និងមិនបានទទួលរងការបង្ខិតបង្ខំផ្ទាល់ពីមន្ត្រីឥណទានទេ ប៉ុន្តែពួកគាត់ដឹងពីផលវិបាកនៃបំណុល និងព្រួយបារម្ភថានឹងត្រូវការលក់ដីធ្លី នាពេលអនាគត។
- អ្នកដែលគ្មានលទ្ធភាពបង់សងទាន់ពេលវេលា បានប្រឈមនឹងការបង្ខិតបង្ខំដូចជា ការគំរាមកំហែងពីមន្ត្រីឥណទានថា ពួកគេនឹង លក់ដីរបស់អ្នកខ្ចីដោយមិនចាំបាច់មានការអនុញ្ញាត ការចោទប្រកាន់អ្នកខ្ចីថានិយាយកុហក និងដាក់សម្ពាធឱ្យខ្ចីប្រាក់ពីអ្នកចងការឯកជន ជាដើម ។

> "ដោយសារគាត់អត់ចេះថ្ងៃបង់ប្រាក់ គោលការណ៍ និងលក្ខខណ្ឌ គាត់ចេះតែព្រមៗតាមគេ ។ ដល់ថ្ងៃឡើងដើម មានលុយពីណា អត់ទាន់បានដកជំឡូងផង"
>
> "ខ្ញុំចង់ឱ្យមានការប្រជុំជាមួយមីក្រូហិរញ្ញវត្ថុ ចង់ស្នើសុំឱ្យមានការប្រាក់តិចជាងនេះ"

## អំឡុងពេល ជំងឺកូវីដ១៩

### ការប្រែប្រួលនៃប្រាក់ចំណូល

ប្រាក់ចំណូលធ្លាក់ចុះ

- តម្លៃកសិផលធ្លាក់ចុះ ហើយតម្រូវការអ្នកទិញក៏មានតិច ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានមិនបានស្នើផ្តល់រៀបចំឥណទានឡើងវិញ • មន្ត្រីឥណទានបដិសេធសំណើរៀបចំឥណទានឡើងវិញ

- គ្មានអ្នកណាបានដឹងអំពីការរៀបចំឥណទានឡើងវិញពីមន្ត្រីឥណទានទេ ហើយសមាជិកមួយចំនួនដែលបានដឹងព័ត៌មានពីប្រភពផ្សេង ត្រូវបានមន្ត្រីឥណទានប្រាប់ថា មិនអាចផ្តល់ឱ្យទេ ។

### មតិយោបល់ផ្សេងៗ

- សមាជិកសហគមន៍ បានស្នើសុំឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបញ្ចុះអត្រាការប្រាក់ ដោយសារអត្រាប្រាក់របស់ពួកគាត់ គឺខ្ពស់ពេក ។
- កម្រៃត្រូវបង់ ជាពិសេសថ្លៃសេវាគឺខ្ពស់ពេក ហើយបង្កឱ្យមានការភ័ន្តច្រឡំជាមួយអត្រាការប្រាក់ទូទៅ ។
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មិនគួរគិតថ្លៃសេវា ចំពោះអ្នកខ្ចីប្រាក់បង់សងផ្តាច់មុនកាលកំណត់នោះទេ ។
- ត្រូវមានការបត់បែនច្រើនជាងនេះ នៅពេលអ្នកខ្ចីគ្មានលទ្ធភាពសងទាន់ពេល កុំផាកពិន័យ ឬដាក់សម្ពាធឱ្យគាត់លក់ដីធ្លី ។



# សហគមន៍មានជ័យស្រ្តីអភិវឌ្ឍន៍

**៥៥ គ្រួសារ**
វិវាទដីធ្លីកើតឡើងនៅឆ្នាំ ២០១០

ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ (ប៉ាន់ប្រមាណ)

**៨៥%**

ទំហំកម្ចីជាមធ្យម

**៩ ០០០ ដុល្លារ**

គ្រឹះស្ថានដែលផ្តល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍

- អេអឹមខេ
- អម្រឹត
- ចម្រើន
- ហត្ថា
- អិលអូអិលស៊ី
- ស្ថាបនា
- ដាប់ប៊ែលយូប៊ី ហ្វាយនែន

## ព័ត៌មានអំពីសហគមន៍

មានជ័យស្រ្តីអភិវឌ្ឍន៍ ជាសហគមន៍មួយក្នុងចំណោមសហគមន៍ចំនួន ៨ ដែលស្ថិតនៅតាមបណ្តោយប្រឡាយស្ទឹងមានជ័យ ក្នុងសង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ ។ ប្រជាពលរដ្ឋបានចាប់ផ្តើមចូលមករស់នៅតាមប្រឡាយនេះ ពីដំបូងក្នុងឆ្នាំ ១៩៩៣ ជាពេលដែលទឹកនៅទីនោះស្អាត និងអំណោយផលសម្រាប់ការនេសាទ ។ ក្នុងឆ្នាំ ១៩៩៨ ប្រឡាយទឹកនេះបានចាប់ផ្តើមផ្លាស់ប្តូរទៅជាប្រឡាយទឹកស្អុយចម្បងមួយ ។ សហគមន៍បានកកើតឡើងនៅឆ្នាំ ២០១០ ក្រោយពីអ្នកភូមិបានទទួលលិខិតមួយពីអាជ្ញាធរមូលដ្ឋាន ដែលបានជូនដំណឹងឱ្យពួកគាត់ចាកចេញពីផ្ទះសម្បែងក្នុងរយៈពេល១៥ថ្ងៃ ដោយគ្មានសំណង ដើម្បីធ្វើការអភិវឌ្ឍតំបន់នោះ ។

នៅទសវត្សរ៍បន្ទាប់ សហគមន៍បានដាក់ញត្តិទៅ រាជរដ្ឋាភិបាល និងបានបង្កើត "ផែនការអភិវឌ្ឍន៍ជម្រើស" ដែលអនុញ្ញាតឱ្យមានទាំងការអភិវឌ្ឍ និងទាំងសហគមន៍បន្តរស់នៅក្នុងទីតាំងដដែល ។ ក្រោយមកគម្រោងនេះបានទទួលការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ហើយពេលនេះស្ទើរតែគ្រប់គ្រួសារទាំងអស់ បានទទួលលិខិតចុះបញ្ជីដីធ្លីសម្រាប់ទំហំដី ៤ម៉ែត្រ គុណនឹង ៦ម៉ែត្រ នៅនឹងកន្លែង ប៉ុន្តែពួកគាត់មិនទាន់ទទួលបានប្លង់រឹងនៅឡើយទេ ហើយគ្រួសារមួយចំនួនក៏មិនទាន់មានថវិកាដើម្បីសាងសង់ផ្ទះនៅលើដីនោះដែរ ។ លើសពីនេះ ការសន្យាជាច្រើនដូចជា ការធ្វើផ្លូវ តបណ្តាញទឹកភ្លើង ដាក់អំពូលភ្លើងបំភ្លឺផ្លូវ បានដំណើរការរួចរាល់ហើយ ប៉ុន្តែការសន្យាផ្សេងទៀតដូចជាសាងសង់សួនច្បារសហគមន៍ និងផ្តល់ទីតាំងសម្រាប់សង់មណ្ឌលសហគមន៍ មិនទាន់បានដំណើរការនៅឡើយទេ ។

### ប្រភពនៃប្រាក់ចំណូល

ទិញលក់អេតចាយ • កម្មករសំណង់ • លក់ទំនិញ • កម្មករ-កម្មការិនីកាត់ដេរ • រត់ម៉ូតូកង់បី • អ្នកធ្វើការតាមផ្ទះ

### ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

បាត់បង់ប្រាក់ចំណូល • ការប៉ះពាល់ផ្លូវចិត្ត

### បញ្ហាដែលមិនទាន់បានដោះស្រាយ

មិនទាន់ទទួលបានលិខិតចុះបញ្ជីដីធ្លីគ្រប់គ្រួសារ • ការសន្យាសាងសង់សួនច្បារសហគមន៍ និងមណ្ឌលសហគមន៍

## បំណុលមីក្រូហិរញ្ញវត្ថុ

បំណុលមីក្រូហិរញ្ញវត្ថុគឺជារឿងទូទៅ ដោយប្រហែល ៨៥%នៃគ្រួសារសរុប ជាប់ជំពាក់កម្ចីខ្នាតតូច ។ ប្រជាពលរដ្ឋភាគច្រើន ខ្ចីកម្ចីឥណទាន ដើម្បីសង់ផ្ទះ លើដីអភិវឌ្ឍន៍ដែលពួកគាត់ទទួលបានពីរាជរដ្ឋាភិបាល ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលយកលិខិតចុះបញ្ជីដីធ្លីធ្វើជាទ្រព្យធានា ហើយជារឿយៗ មន្រ្តីឥណទានផ្តល់កម្ចីឥណទានតាមដំណាក់កាល ដើម្បីធានាថា អ្នកខ្ចីប្រាក់ពិតជាកំពុងសាងសង់ផ្ទះ ដោយប្រើប្រាស់កម្ចីឥណទានទាំងនោះ ។ ប្រជាពលរដ្ឋភាគច្រើនបង់សងកម្ចីមីក្រូហិរញ្ញវត្ថុរបស់ពួកគេទាន់ពេលវេលា ដោយប្រើប្រាស់យន្តការស្រដៀងគ្នាមួយចំនួនដូចជា ការកាត់បន្ថយអាហារបរិភោគ ចំណាកស្រុក និងការខ្ចីប្រាក់ពីអ្នកចងការឯកជន ដើម្បីបង់សង ។

### សម្រង់ពាក្យសម្តីពីប្រជាពលរដ្ឋសហគមន៍

"គេសួរនាំ ដើម្បីពិនិត្យមើលលិខិតចុះបញ្ជីដីធ្លីសិន បន្ទាប់មកគេសួរថា ចង់ខ្ចីប៉ុន្មាន ហើយចំណូលយើងប៉ុន្មាន"

"ដំបូង ខ្ញុំខ្ចីពីស្ថាប័នមួយ ក្រោយមកឡើងពីមួយទៅពីរ ពីពីរទៅបី?"

"ពេលគ្មានអីសងធនាគារ យើងទៅរកអ្នកចងការ ។ ពេលគ្មានអីសងអ្នកចងការ យើងទៅរកធនាគារ?"

"បើអ្នកខ្ចីអត់អីសង ហើយរត់បាត់ គេមករឹតកអ្នកធានា"

"យើងខ្លាច កើតទុក្ខ ។ យើងត្រូវលក់អីដែលមាន ដាក់បញ្ចាំរបស់ប្រើប្រាស់ ឬខ្ចីពីអ្នកផ្សេង ។ យើងត្រូវតែរកលុយសងគេ "

"មិនត្រឹមតែខ្លាចគេមិនឱ្យខ្ចីលើកក្រោយទេ តែយើងខ្លាចបាត់បង់ទ្រព្យបញ្ចាំ "

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

សាងសង់ផ្ទះ • ធ្វើអាជីវកម្ម • ព្យាបាលជំងឺ • សងបំណុលផ្សេងទៀត

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

មន្ត្រីឥណទានទាមទារឱ្យមានប័ណ្ណកម្មសិទ្ធិដីធ្លី ឬលិខិតចុះបញ្ជីដីធ្លី • មន្ត្រីឥណទានផ្តល់ប្រាក់កម្ចីតាមដំណាក់កាលសម្រាប់កម្ចីគេហដ្ឋាន

- ចំណុចដំបូងដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធ្វើនៅពេលវាយតម្លៃអ្នកខ្ចី សម្រាប់ កម្ចីឥណទានថ្មី គឺការសួរអំពីលិខិតចុះបញ្ជីដីធ្លីរបស់ពួកគាត់ ហើយពួកគេ នឹងចុះទៅពិនិត្យដីនោះ ។
- នៅពេលអ្នកខ្ចីប្រាក់ យក ឥណទាន សម្រាប់សាងសង់ផ្ទះ មន្ត្រីឥណទានភាគច្រើននឹងផ្តល់ឥណទាននោះជាពីរ ទៅបីចំណែក ដើម្បីធានាថា អ្នកខ្ចីប្រាក់គឺពិតជាកំពុងសាងសង់ផ្ទះ មុនពេលផ្តល់ចំណែកឥណទានក្រោយទៀត ។

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទាន បានចុះតាមផ្ទះរបស់អ្នកខ្ចី ដើម្បីស្នើផ្តល់កម្ចី ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និង គោលការណ៍នៃកម្ចីដែរឬទេ?

- អ្នកខ្ចីភាគច្រើន ចេះអាន ឬសរសេរអក្សរ ។ អ្នកខ្លះពឹងលើមន្ត្រីឥណទាន ដើម្បីពន្យល់ពួកគាត់អំពីលក្ខខណ្ឌនៃកម្ចី ។

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការក្លែងបន្លំ

- ជាច្រើនដង មន្ត្រីឥណទាននិយាយជាធម្មតាជាមួយអ្នកខ្ចី ។ អ្នកខ្ចីភាគច្រើន មិនមានការយឺតយ៉ាវក្នុងការបង់សងទេ ដោយសារ ពួកគេខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬអ្នកចងការឯកជនផ្សេងទៀត ដើម្បីបង់សង ដូច្នេះពួកគាត់ជាច្រើនបាននិយាយថា មិនមានការដាក់សម្ពាធច្រើនពីសំណាក់មន្ត្រីឥណទានទេ ។
- ក្នុងករណីមួយចំនួន មន្ត្រី ឥណទានបានកុហកអំពីការបង់សងទៅថ្នាក់លើ របស់គាត់ និងគ្មានទំនួលខុសត្រូវនូវអ្វីដែលបានឯកភាពគ្នាជាមួយ អតិថិជន ហើយព្យាយាមដាក់បន្ទុកលើអតិថិជន ។ ករណីភាគច្រើន ត្រូវបានដោះស្រាយ នៅពេលអតិថិជនតវ៉ាទៅកាន់អ្នកគ្រប់គ្រងនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

### ផលវិបាកនៃបំណុល

ធ្វើការបន្ថែម • ខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ • ខ្ចីប្រាក់ពីអ្នកចងការឯកជន • ពលកម្មកុមារ • កុមារបោះបង់ការសិក្សា • កាត់បន្ថយអាហារបរិភោគ • ភាពតានតឹងក្នុងគ្រួសារ • ចំណាកស្រុក • លក់ទ្រព្យសម្បត្តិផ្សេងៗ

- សមាជិកសហគមន៍ខ្លះ ធ្វើការរហូតដល់ ១៦ម៉ោងក្នុងមួយថ្ងៃ ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុរបស់ពួកគេ ។

### អំឡុងពេល ជំងឺកូវីដ១៩

- យ៉ាងតិចណាស់ មានកុមារមិនទាន់គ្រប់អាយុចំនួន ២នាក់ បានចាប់ផ្តើមធ្វើការ ដើម្បីជួយឪពុកម្តាយ សងបំណុល បន្ទាប់ពីសាលាត្រូវបានបិទ អំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩ ។ ពួកគេមិនបានត្រឡប់មកសាលារៀនវិញទេ នៅពេលសាលារៀនបើកឡើងវិញ ។
- មានករណីជាច្រើននៃអំពើហិង្សាក្នុងគ្រួសារ និងការឈ្លោះប្រកែកគ្នាក្នុងគ្រួសារ ដោយសារបន្ទុកនៃបំណុល ។

### ការប៉ះពាល់ផ្លូវចិត្ត

ភ័យខ្លាច • កើតទុក្ខ • ព្រួយបារម្ភ

- ទោះបីជាមិនមាន សម្ពាធផ្ទាល់ពី មន្ត្រីឥណទាន អ្នកខ្ចីប្រាក់ភាគច្រើនបាននិយាយថា ពួកគេមានអារម្មណ៍ភ័យខ្លាច នៅពេលថ្ងៃបង់ប្រាក់ជិតចូល មកដល់ ។ ពួកគាត់ជាច្រើនបានលក់ទ្រព្យសម្បត្តិ ឬយក កម្ចីឥណទាន បន្ថែម ដើម្បីជៀសវាងការបង់សងយឺត សូម្បីតែមួយថ្ងៃ ។
- ភាគច្រើននៃការភ័យខ្លាច និងព្រួយបារម្ភ គឺដោយសារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានដាក់ដីធ្លី របស់ពួកគាត់ជាទ្រព្យធានា ដូច្នេះអ្នកខ្ចីប្រាក់ភ័យខ្លាចបាត់បង់ដីធ្លីនោះ ។

> "យើងត្រូវសងលុយគេវិញ តែយើងមិនត្រូវការគំរាមកំហែងទេ"
>
> "យើងមិនត្រឹមតែខ្លាចគេមិនឱ្យខ្ចីលើកក្រោយទេ តែយើងខ្លាចបាត់បង់ទ្រព្យបញ្ចាំ"

### ការប្រែប្រួលនៃប្រាក់ចំណូល

ប្រាក់ចំណូលធ្លាក់ចុះ

- តម្លៃសម្ភារៈកែច្នៃបានធ្លាក់ចុះ ដោយសារការរឹតត្បិតនាំចេញ ។
- កម្មករ កម្មការិនីកាត់ដេរ និងភោជនីយដ្ឋាន ប្រឈមនឹងការព្យួរការងារ រីឯអ្នករត់ម៉ូតូកង់បី ក៏គ្មានអតិថិជនធ្វើដំណើរ ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានខ្លះបានប្រាប់អ្នកខ្ចីប្រាក់ពីការរៀបចំឥណទានឡើងវិញ

- ករណីមួយ អ្នកខ្ចីទាក់ទងតាមទូរស័ព្ទទៅមន្ត្រីឥណទាន និងបានស្នើសុំបង់យឺតមួយខែ ដោយបង់តែការប្រាក់ និងមន្ត្រីឥណទានបានឯកភាព ។ ប៉ុន្តែក្រោយមក មន្ត្រីឥណទានបានបដិសេធការព្រមព្រៀងនេះ និងចោទប្រកាន់អ្នកខ្ចីថាបង់សងយឺតទៅវិញ ។
- ករណីភាគច្រើន អ្នកខ្ចីប្រាក់បានដឹងពីការរៀបចំឥណទានឡើងវិញ ពីប្រភពផ្សេង មិនមែនដឹងពីមន្ត្រីឥណទានទេ ។

### មតិយោបល់ផ្សេងៗ

- កម្រិតបំណុលគឺខ្ពស់ខ្លាំង នៅក្នុងសហគមន៍ ។
- សមាជិកសហគមន៍ស្នើសុំឱ្យរាជរដ្ឋាភិបាល បង្កើតកម្មវិធីប្រាក់កម្ចីសម្រាប់សហគមន៍ ដោយមានអត្រាការប្រាក់ទាបជាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូច្នេះសមាជិកសហគមន៍អាចទទួលបានកម្ចីធ្វើផ្ទះ ដែលសមល្មមតាមលទ្ធភាពរបស់ពួកគាត់ ។

> "អត់មានអ្នកណាប្រាប់យើងទេ [ការរៀបចំឥណទានឡើងវិញ] ទាល់តែយើងគេទៅសួរមន្ត្រីឥណទាន"



# សហគមន៍ភូមិ ១៧

១៥៣ គ្រួសារ
វិវាទដីធ្លីកើតឡើងនៅឆ្នាំ ២០១៤

ចំនួនគ្រួសារដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ
(ប៉ាន់ប្រមាណ)

១០០%

ទំហំកម្ចីជាមធ្យម

១០ ០០០ ដុល្លារ

គ្រឹះស្ថានដែលផ្តល់កម្ចីឥណទានខ្នាតតូចនៅក្នុងសហគមន៍

អេស៊ីលីដា • អម្រឹត • បាយ័ន • ហ្វូណន • ហត្ថា • អិលអូអិលស៊ី • មង្គល • ស្ថាបនា • ស្ថាយល៍ • ដាប់ប៊ែលយូប៊ី ហ្វាយនែន

## ព័ត៌មានអំពីសហគមន៍

សហគមន៍ភូមិ១៧ គឺជាសហគមន៍ក្នុងទីក្រុងមួយ ដែលត្រូវបានបង្កើតឡើង ជាប្រតិកម្មឆ្លើយតបទៅនឹងគម្រោងផ្លូវរថភ្លើងមួយ ដែលគាំទ្រថវិកាដោយ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងអនុវត្តដោយរាជរដ្ឋាភិបាល ។ ខ្សែផ្លូវរថភ្លើង ត្រូវបានកំណត់ឱ្យរត់ឆ្លងកាត់ ឬគៀកទៅនឹងផ្ទះរបស់សមាជិកសហគមន៍ជាច្រើន ។ក្រោយមក គម្រោងផ្លូវរត់ភ្លើង ត្រូវបានទុកចោល ប៉ុន្តែគម្រោងថ្មីមួយចំនួនក្នុងការពង្រីកផ្លូវធ្វើដំណើរធំៗ ឆ្លងកាត់សហគមន៍ បានធ្វើឱ្យសុវត្ថិភាពកម្មសិទ្ធិដីធ្លីសមាជិកសហគមន៍ប្រឈមនឹងហានិភ័យជាថ្មីម្តងទៀត ។ សមាជិកសហគមន៍ជាច្រើន គឺជាកម្មករសំណង់ អ្នករត់ម៉ូតូឌុប កម្មករ កម្មការិនីរោងចក្រ មន្ត្រីរាជការ អ្នករើសអេតចាយ ឬធ្វើការផ្នែកសម្អាតនៅសាលារៀនក្បែរនោះ ។

ចាប់តាំងពីឆ្នាំ ២០១៤ សហគមន៍បានដាក់ញត្តិទៅសាលារាជធានីភ្នំពេញ និងក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីទាមទារវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប្លង់រឹង) សម្រាប់ដីធ្លីរបស់ពួកគេ ក៏ដូចជាដាក់ញត្តិទៅធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីទាមទារសំណងដល់គ្រួសារដែលរងផលប៉ះពាល់ ។ ខណៈដែលគ្រួសារមួយចំនួនតូច បានទទួលប្លង់រឹងសម្រាប់ដីរបស់ពួកគាត់ គ្រួសារជាច្រើនផ្សេងទៀតមិនទាន់ទទួលបាននៅឡើយទេ ហើយពួកគាត់ភ័យខ្លាចថានឹងត្រូវតាំងទីលំនៅថ្មី ដោយគ្មានសំណងសមរម្យ ។

### ប្រភពនៃប្រាក់ចំណូល

កម្មករសំណង់ • អ្នករើសអេតចាយ • អ្នកបោកគក់ខោអាវ • អ្នករត់ម៉ូតូកង់បី • អ្នកធ្វើការតាមភោជនីយដ្ឋាន • លក់ទំនិញ • អ្នកសម្អាត• កម្មករ-កម្មការិនីកាត់ដេរ • មន្ត្រីរាជការ

### ផលប៉ះពាល់ចម្បងៗនៃវិវាទដីធ្លី

ប្រាក់ចំណូលធ្លាក់ចុះ • អត្តិភ័យ • ការប៉ះពាល់ផ្លូវចិត្ត

### បញ្ហាដែលមិនទាន់បានដោះស្រាយ

ការផ្តល់សំណង់មិនសមរម្យ

## បំណុលមីក្រូហិរញ្ញវត្ថុ

សមាជិកសហគមន៍បានខ្ចីប្រាក់ប្រមាណ ២០០០ ទៅ៣០០០ ដុល្លារ ក្នុងមួយកម្ចីដំបូង ប៉ុន្តែដោយសារគ្មានលទ្ធភាពសង ពួកគាត់ចាប់ផ្តើមខ្ចីកម្ចីឥណទានកាន់តែធំទៅៗ ដើម្បីបង់សងបំណុលចាស់ ។ កម្ចីទាំងនេះ បានដាក់ដីធ្លីធ្វើជាទ្រព្យធានា ហើយខណៈដែលប្រាក់មួយចំនួនត្រូវបានយកទៅគាំទ្រសកម្មភាពអាជីវកម្ម ការធ្លាក់ចុះនៃសេដ្ឋកិច្ចបង្កឡើងដោយវិបត្តិជំងឺកូវីដ១៩ បានធ្វើឱ្យអ្នកខ្ចីប្រាក់គ្មានលទ្ធភាពសងត្រឡប់ទៅវិញ ។ មានការដាក់សម្ពាធជាច្រើនពីសំណាក់អ្នកផ្តល់កម្ចីឥណទានខ្នាតតូច ទាំងនៅពេលផ្តល់កម្ចីទំហំធំ និងពេលដែលទាមទារការបង់សងត្រឡប់ទៅវិញ ។ សមាជិកសហគមន៍ជាច្រើនបាននិយាយថា ពួកគាត់មិនចូលចិត្តរបៀបលោភលន់របស់មន្ត្រីឥណទានទេ ជាពិសេសការចុះមកផ្ទះរបស់អ្នកខ្ចីប្រាក់ និងការគំរាមកំហែងរឹបអូសយកដីធ្លីជុំវិញឥណទានខ្នាតតូច ។

### សម្រង់ពាក្យសម្តីពីប្រជាពលរដ្ឋសហគមន៍

"រាល់ថ្ងៃ គេចង់ឱ្យយើងខ្ចីច្រើន ។ ខ្ញុំមិនដឹងថាមិចបានគេធ្វើចឹង ។ ប្រហែលមកពីគេចង់បានផ្ទះយើង ខ្ញុំគិតថាចឹង"

"ដំបូង គេសួរពីប្លង់ដី ។ បន្ទាប់មក គេសួរពីប្រាក់ខែតាមក្រោយ"

"យើងមានប្លង់ យើងអាចខ្ចីបានច្រើន លឿន ហើយស្រួលទៀត"

"បន្ទាប់ពីយើងបានលុយ គេអត់បានសួរនាំអីទៀតទេ ។ គេសួរតែពេលដំបូង ហើយបន្ទាប់ពីអ្នកខ្ចីបានលុយ គេអាចយកទៅធ្វើអីក៏បាន "

"គេមកទារលុយយើងដល់ផ្ទះ ហើយគេប្រាប់ឱ្យលក់អីដែលយើងមាន ។ គេអត់បានប្រាប់ឱ្យខំរកលុយទេ តែឱ្យលក់ដីតែម្តង"

## ការខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### មូលហេតុនៃការខ្ចីឥណទាន

ធ្វើអាជីវកម្ម • ទិញដី • ព្យាបាលជំងឺ • ជួសជុលផ្ទះ • សងបំណុលផ្សេងទៀត

### ដំណើរការនៃការវាយតម្លៃលើកម្ចីឥណទាន

មន្ត្រីឥណទានទាមទារឱ្យមានប័ណ្ណកម្មសិទ្ធិដីធ្លី • មន្ត្រីឥណទានខ្លះក្លែងបន្លំប្រភពនៃប្រាក់ចំណូល • មន្ត្រីឥណទានធ្វើការវាយតម្លៃប្រាក់ចំណូល

- អ្នកខ្ចីប្រាក់ជាច្រើន បានរាយការណ៍ថា មន្ត្រីឥណទានបានដាក់សម្ពាធអ្នកខ្ចីប្រាក់ ឱ្យយក កម្ចីឥណទានទំហំធំ និងកុហកពីប្រភពនៃប្រាក់ចំណូលទៅលើ ឯកសារ ឥណទាន ដើម្បី អនុម័តទៅលើកម្ចីក្នុងទំហំធំនោះ ។
- ប័ណ្ណកម្មសិទ្ធិដីធ្លី គឺជា ឯកសារសំខាន់បំផុតក្នុងការ ទទួលបានកម្ចីឥណទាន ។ ប្រសិនបើគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីទេ អ្នកខ្ចីប្រាក់មិនអាចទទួលបានកម្ចីឥណទានទេ ។

### តើប្រជាពលរដ្ឋ ដឹងអំពីការផ្តល់កម្ចីឥណទានដោយរបៀបណា?

- មន្ត្រីឥណទាន បានចុះតាមផ្ទះរបស់អ្នកខ្ចី ដើម្បីស្នើផ្តល់កម្ចី ។

### តើអ្នកខ្ចីបានដឹងអំពីលក្ខខណ្ឌ និង គោលការណ៍នៃកម្ចីដែរឬទេ?

- អ្នកខ្ចីភាគច្រើន ចេះអាន ឬសរសេរអក្សរ ហើយមន្ត្រីឥណទានផ្តល់ និងពន្យល់អំពីកិច្ចសន្យា និងឆ្លើយសំណួរ ប្រសិនបើអ្នកខ្ចីប្រាក់មានចម្ងល់ផ្សេងៗ ។

"ឧទាហរណ៍ថា យើងចង់ខ្ចី ២០ ០០០ ដុល្លារ ប៉ុន្តែយើងអត់មានលទ្ធភាពសង ។ អ៊ីចឹង មន្ត្រីឥណទានប្រាប់យើងឱ្យគិតពីប្រភពផ្សេងនៃប្រាក់ចំណូល ។ បើអត់មានទេ គេដាក់ថាយើងមានផ្ទះជួលឱ្យគេ ឬដាក់កាតគ្រីឡាន ម៉ូតូ នរណាម្នាក់ដែលគេស្គាល់ ដើម្បីឱ្យមេគេឃើញប្រភពប្រាក់ចំណូលច្រើន ដែលមើលទៅដូចយើងមានឡានជួលឱ្យគេដែរ ដោយសារគេចង់ឱ្យយើងយកកម្ចី"

## ការបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ

### ឥរិយាបថគ្មានក្រមសីលធម៌របស់មន្ត្រីឥណទាន

ការប្រមូលឥណទានដោយរំលោភបំពាន • ការផ្តល់កម្ចីឥណទានបែបកេងចំណេញ • ការក្លែងបន្លំ • ការដាក់សម្ពាធឱ្យលក់ដី • ការគំរាមកំហែង

- មានករណីមួយដែលអ្នកខ្ចីប្រាក់បានយឺតក្នុងការ បង់សង រយៈពេល ៧ថ្ងៃ ដូច្នេះបុគ្គលិក ៤ ទៅ ៥នាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានមកទារប្រាក់ និងប្រាប់នាងឱ្យលក់ទ្រព្យសម្បត្តិ ។ ពួកគេធ្វើដូចគ្នានៅថ្ងៃបន្ទាប់ ដោយរង់ចាំនៅផ្ទះរបស់អ្នកខ្ចីរយៈពេល ៤ម៉ោង ។ ចុងក្រោយ ពួកគេព្យាយាមបង្ខំឱ្យនាងលក់ដី ។

### ផលវិបាកនៃបំណុល

ខ្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ • ខ្ចីប្រាក់ពីអ្នកចងការឯកជន • ពលកម្មកុមារ • កុមារបោះបង់ការសិក្សា • កាត់បន្ថយអាហារបរិភោគ • ការលក់ដី • ចំណាកស្រុក • លក់ទ្រព្យសម្បត្តិផ្សេងៗ • បញ្ហាជំណោក

- សមាជិកសហគមន៍ជាច្រើន បានកាត់បន្ថយប្រាក់ចំណាយលើការបរិភោគអាហារ ប្រមាណ ៥០% ដើម្បីសងបំណុលពួកគេ ។
- ក្មេងអាយុរហូតដល់ ១៤ឆ្នាំ បានបោះបង់ការសិក្សា និងធ្វើការនៅក្នុងភោជនីយដ្ឋាន ដើម្បីជួយគ្រួសាររបស់ពួកគេសងបំណុលមីក្រូហិរញ្ញវត្ថុ ។

### ការប៉ះពាល់ផ្លូវចិត្ត

ភ័យខ្លាច • កើតទុក្ខ • ព្រួយបារម្ភ

- សមាជិកសហគមន៍ភាគច្រើនភ័យខ្លាចថា នឹងបាត់បង់ដីធ្លី ឬដីធ្លីរបស់ពួកគាត់ត្រូវរឹបអូសដោយមន្ត្រីឥណទាន ប្រសិនបើពួកគាត់គ្មានលទ្ធភាពសងប្រាក់ដែលបានខ្ចីត្រឡប់ទៅវិញទេ ។

## អំឡុងពេល ជំងឺកូវីដ១៩

### ការប្រែប្រួលនៃប្រាក់ចំណូល

ប្រាក់ចំណូលធ្លាក់ចុះ

- សកម្មភាពសេដ្ឋកិច្ចបានធ្លាក់ចុះ អំឡុងពេលរីករាលដាលជំងឺកូវីដ១៩ ដោយសាលារៀនត្រូវបានបិទ កម្មករ កម្មការិនីកាត់ដេរ និងសំណង់ប្រឈមនឹងការព្យួរការងារ ហើយអ្នកបើកបរម៉ឺកកង់បីបាត់បង់ ២ភាគ៣ នៃប្រាក់ចំណូលរបស់ពួកគាត់ ។

### ការពន្យារពេល ឬ ការរៀបចំឥណទានឡើងវិញ

មន្ត្រីឥណទានខ្លះបានប្រាប់អ្នកខ្ចីប្រាក់ពីការរៀបចំឥណទានឡើងវិញ

- មានករណីមួយដែលអ្នកខ្ចីប្រាក់បានស្នើទៅ មន្ត្រីឥណទាននូវជម្រើសរៀបចំ ឥណទានឡើងវិញ ហើយ មន្ត្រីឥណទានបានសុំទោសដែលមិនបានប្រាប់ពីជម្រើសរៀបចំ ឥណទានឡើងវិញឱ្យបានឆាប់ និងបានយល់ព្រមលើសំណើ ។
- អ្នកខ្ចីប្រាក់ខ្លះ បង្ហាញពីភាពភ័ណ្ឌច្រឡំ និងការខកចិត្ត ចំពោះដំណើរការរៀបចំឥណទានឡើងវិញ ដោយកត់សម្គាល់ឃើញថា ការប្រាក់ និងការប្រាក់បង្គរ នៅតែត្រូវបានគណនា ។ "តើជួយបានយ៉ាងមិច?" ជាសំណួររបស់អ្នកខ្ចីប្រាក់ម្នាក់ដែលបានទទួលការរៀបចំឥណទានឡើងវិញ ។

### មតិយោបល់ផ្សេងៗ

- កម្រិតបំណុលនៅក្នុងសហគមន៍ គឺខ្ពស់ខ្លាំង ។
- សមាជិក សហគមន៍ស្នើឱ្យ មន្ត្រីឥណទានគួរ អនុញ្ញាតអ្នកខ្ចីប្រាក់ពន្យារពេលនៃការបង់សងទាំងប្រាក់ដើម និងការប្រាក់ នៅពេលពួកគាត់គ្មាន លទ្ធភាព ។ ពួកគាត់ក៏ស្នើសុំ ផងដែរថា ប្រសិនបើអ្នកខ្ចីប្រាក់យឺតត្រឹមតែប៉ុន្មានថ្ងៃ មន្ត្រី ឥណទានមិនគួរ មកផ្ទះរបស់ពួកគាត់ទេ និងគួរ រកដំណោះស្រាយដែលអាចទទួល យកបាន ទៅលើបញ្ហា ជាជាងការដាក់សម្ពាធទៅលើអ្នកខ្ចីប្រាក់ ។




សម្រាប់ព័ត៌មានបន្ថែម៖

WWW.MFICAMBODIA.COM